ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០២១

លេខៈ ១៦

ឆ្នាំ២០២៣

# អារម្ភកថា

សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២១ ត្រូវបានវាយតម្លៃថាមានកំណើនក្នុងអត្រា **៣,០%** ទាបជាងការព្យាករក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចបន្តិចក្នុងអត្រា **៣,៥%**។ កំណើនសេដ្ឋកិច្ចទាបជាងការរំពឹងទុកធៀបនឹងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ ដោយសារការផ្ទុះឡើងនៃព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ២០២១ គួបផ្សំនឹងការលេចចេញនូវវីរុសបំប្លែងខ្លួនប្រភេទថ្មី ដូចជា អូមីក្រុងជាដើម ទាំងក្នុងបរិការណ៍សកល តំបន់ និងក្នុងស្រុក ដែលធ្វើឱ្យប៉ះពាល់ជាពិសេសលើអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងវិស័យគាំទ្រទេសចរណ៍ផ្សេងៗទៀត។ វិស័យកសិកម្មជារួមសម្រេចបានកំណើនល្អប្រសើរក្នុងរង្វង់១,១% ដោយសារកំណើនល្អប្រសើរនៃអនុវិស័យដំណាំនិងអនុវិស័យចិញ្ចឹមសត្វ វិស័យឧស្សាហកម្មបានងើបឡើងវិញក្នុងល្បឿនលឿនជាងការរំពឹងទុក ពោលក្នុងអត្រាកំណើន៨,៦% ដោយសារការកើនឡើងវិញនៃអនុវិស័យកាត់ដេរ និងកំណើនរឹងមាំនៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងវិស័យសេវាកម្មមានកំណើនអវិជ្ជមានក្នុងអត្រា-១,៩% ដោយសារការធ្លាក់ចុះនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន បើទោះបីអនុវិស័យលក់ដុំ-លក់រាយ និងអចលនទ្រព្យបានងើបឡើងវិញបន្តិចក្តី។ ផ.ស.ស សម្រាប់មនុស្សម្នាក់ៗ កើនឡើងពី **១ ៦០៥** ដុល្លារអាមេរិកក្នុងឆ្នាំ២០២០ ទៅ **១ ៦៥៩** ដុល្លារអាមេរិកក្នុងឆ្នាំ២០២១។ ទន្ទឹមនឹងនេះ អត្រាអតិផរណាស្ថិតក្នុងរង្វង់**២,៩%** ដូចគ្នាទៅនឹងឆ្នាំ២០២០ និងអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំស្ថិតក្នុងកម្រិត **៤ ០៦៨**រៀល ក្នុងមួយដុល្លារអាមេរិក រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវគោលនយោបាយសំខាន់ៗ ព្រមជាមួយនឹងគោលនយោបាយវិត្តារកម្មថវិកា រួមមាន៖ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២-បន្តរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ចក្នុងបរិការណ៍នៃការរាតត្បាតនៃជំងឺកូវីដ-១៩ និងទប់ទល់ផលប៉ះពាល់នៃជំងឺដ៏កាចសាហាវនេះ តាមរយៈការជំរុញការនាំចេញឱ្យអស់ពីសក្តានុពល និងងាកពីការពឹងផ្អែកទាំងស្រុងលើតម្រូវការខាងក្រៅ មកពឹងផ្អែកមួយចំនួនលើតម្រូវការក្នុងស្រុក ៣-បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន ៤-បន្តអនុវត្តក្របខ័ណ្ឌចំណាយអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាចំពោះមុខ និងហានិភ័យនានាប្រកបដោយប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការ ៥-គាំទ្រដល់ការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២១-២០២៣ ៦-ជំរុញការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ ៧-គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយរួមបញ្ចូលនូវការបង្កើនប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការជំរុញអនុវត្តដោយម៉ត់ចត់នូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ កម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ៨-ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការនៃគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ តាមរយៈការបន្តគាំទ្រការ

អភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូច និងមធ្យម ជាមួយនឹងវិធានការជាក់លាក់ ក៏ដូចជាតាមរយៈការបន្តវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូនថាមពល និងឌីជីថល ៩-បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គម ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ ១០-ជំរុញការធ្វើពិពិធកម្មផលិតកម្ម គោលដៅ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និង១១-បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្មដោយផ្តោតលើការបង្កើនផលិតភាព ពិពិធកម្ម ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម។

ជាក់ស្តែង នៅក្នុងឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ បានខិតខំប្រឹងប្រែងអនុវត្តវិធានការប្រមូលចំណូលដែលនាំឱ្យចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០២១ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៣,៩% ហើយបានថយចុះតែ ៤,៥% ធៀបនឹងការអនុវត្តឆ្នាំ២០២០ ដោយចំណូលសារពើពន្ធឆ្នាំ២០២១ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុតែ ៥,៦% ហើយបានថយចុះតែ ៤,៣% ធៀបនឹងការអនុវត្តឆ្នាំ២០២០ ទោះបីជារងនូវផលប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ លើស្ថានភាពសេដ្ឋកិច្ចកម្ពុជា និងសកលលោកក៏ដោយ។ សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងដោយតស៊ូមោះមុតប្រកបដោយការទទួលខុសត្រូវខ្ពស់ពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ពិសេសអគ្គនាយកដ្ឋានពន្ធដារបានចាត់វិធានការកែលម្អគោលនយោបាយសារពើពន្ធ និងពង្រឹងរដ្ឋបាលសារពើពន្ធសំខាន់ៗ និងអភិបាលកិច្ចល្អក្នុងការប្រមូលចំណូល។

ចំពោះចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០២១ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៣២,២% ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០២១ អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៣,៤% និងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៥,១%។

រីឯចំណាយថវិការដ្ឋឆ្នាំ២០២១ (ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ) អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ**១,៩%** គឺដោយសាររាជរដ្ឋាភិបាលបានសម្រេចធ្វើវិចារណកម្មចំណាយថវិកាឆ្នាំ២០២១ តាមរយៈការបន្ថយឥណទានថវិកាលើមុខសញ្ញាចំណាយមួយចំនួនដែលមិនអាច និងមិនអំណោយផលអនុវត្តបានអំឡុងពេលបិទប្រទេស ដើម្បីសន្សំថវិកាបន្ថែមមួយចំនួនយកទៅបម្រើឱ្យមុខសញ្ញាចំណាយចាំបាច់បំផុត និងឆ្លើយតបនឹងតម្រូវការបន្ទាន់ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ព្រមទាំងទប់ទល់ផលប៉ះពាល់អវិជ្ជមានមកលើសង្គម និងសេដ្ឋកិច្ចកម្ពុជា។

លទ្ធផលទាំងនេះ បានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយមោះមុតឈ្លាសវៃ និងភ្លឺស្វាងរបស់រាជរដ្ឋាភិបាលដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជារដ្ឋបុរស ជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម**នៃព្រះរាជាណាចក្រកម្ពុជា និងដោយសារតែរាជរដ្ឋាភិបាលមានច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមអាទិភាពគោលនយោបាយសំខាន់ៗ។

ចំពោះចំណាយថវិការាជធានី ខេត្ត អនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ២៦,៩% ចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៥,៧% និងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ក៏អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ២១,៣% ដែរ។

ការគ្រប់គ្រងថវិកាឆ្នាំ២០២១ គោរពបានទាំងកាលវសាន ទាំងខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានបង្ហាញឱ្យឃើញថា ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកល និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច កំពុងវិវត្តឆាប់រហ័ស និងចល័តយ៉ាងលឿនពិបាកប៉ាន់ប្រមាណឱ្យបានច្បាស់លាស់ ដោយសារផលប៉ះពាល់ធ្ងន់ធ្ងរនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលបានបន្តធ្វើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជន៍ថវិកាតាមរយៈការកំណត់លំដាប់អាទិភាព និងធ្វើវិចារណកម្មលើមុខចំណាយលែងចាំបាច់នានា។ ថវិកាឆ្នាំ២០២១ ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យនានា ទាំងក្នុង និងក្រៅ សំដៅធានាលំនឹងសង្គមសេដ្ឋកិច្ចកម្ពុជា និងការពារអាយុជីវិតប្រជាជនពីការរាតត្បាតនៃជំងឺកូវីដ-១៩ ព្រមទាំងគាំទ្រដល់ការស្តារសេដ្ឋកិច្ចកម្ពុជាឱ្យត្រឡប់ទៅកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានបន្តប្តេជ្ញាជំរុញវឌ្ឍនភាពក្នុងការដ្ឋានកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ព្រមជាមួយនឹងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងវិស័យអាទិភាពផ្សេងទៀត ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ពិសេសដើម្បីគោលដៅនៃការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវ**កម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣** របស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិ និងការកសាងជាតិមួយដ៏រស់រវើក មានអនាគតដ៏រុងរឿងភ្លឺស្វាងត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួនតាមគោលការណ៍ប្រជាធិបតេយ្យនិងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យ។

សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាព ឯករាជ្យជាតិ និងអធិបតេយ្យភាព ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

សរុបមក ថវិកាឆ្នាំ២០២១ ត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុង និងក្រៅប្រទេស ហើយត្រូវបានប្រសិទ្ធនាមថា ជា "**ថវិកាប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម សេដ្ឋកិច្ច និង**

**ជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលស្រាកស្រាន្តពីវិបត្តិនៃជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព ស្ថិរភាពសង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជាជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន"។**

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះ ជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០២១ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណៈជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យ

សវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់ដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា តាមការធ្វើសវនកម្មនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រលាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ អង្គារ ៨រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០២៣

**អគ្គសវនករ**



**សោម គីមសួគ៌**

# មាតិកា

**ទំព័រ**


សេចក្តីសង្ខេប ..... ១
១. សេចក្តីផ្តើម ..... ៦
១.១.លក្ខណៈទូទៅ ..... ៦
១.២.ការអនុវត្ត និងដែនកំណត់សវនកម្ម ..... ៦
១.៣.គោលបំណងនៃការផ្សព្វផ្សាយ ..... ៧
២. ការគ្រប់គ្រងថវិកា ..... ៧
២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា ..... ៧
២.២.កិច្ចប្រតិបត្តិការថវិកា ..... ៧
៣. លទ្ធផលសវនកម្ម ..... ១២
៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ ..... ១២
៣.១.១.ការប្រកាសពន្ធ និងអាករក្នុងនាមសហគ្រាសដើមមួយចំនួនតូចដោយគ្មានការទទួលស្គាល់ ..... ១២
៣.១.២.ការពុំបានកាត់ទុកជាមុននូវប្រាក់អាករលើតម្លៃបន្ថែម ..... ១៣
៣.១.៣.ការប្រកាសបរិមាណទំនិញនិងតម្លៃទំនិញនាំចូលមួយចំនួននៅមានកម្រិត ..... ១៤
៣.១.៤.ការអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈមិនទាន់បានពេញលេញ ..... ១៥
៣.១.៥.កង្វះខាតក្នុងការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារ ..... ១៦
៣.១.៦.ភាពយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួលជួលដីទំនេរ ..... ១៧
៣.១.៧.ចំណូលផ្សេងៗ និងបង្វែររង់ចាំដំណោះស្រាយ ..... ១៨
៣.១.៨.ការគ្រោងថវិកាចំណូលសេវាសាធារណៈពុំទាន់បានសមស្រប ..... ១៩
៣.១.៩.ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ ..... ១៩
៣.១.១០.ភាពយឺតយ៉ាវក្នុងការបង់ចំណូលបែងចែកថវិកាជាតិ៥% និង៥១% ..... ២១
៣.១.១១.ការកាន់កាប់កិច្ចបញ្ជិកាបេឡាចំពោះប្រាក់បេសកកម្មមិនទាន់ពេញលេញ ..... ២១
៣.១.១២.ការយកសក្ខីបត្រឆ្នាំចាស់មកទូទាត់ក្នុងឆ្នាំថ្មី ..... ២២
៣.១.១៣.ការពុំបានអនុវត្តពិន័យលើក្រុមហ៊ុនដែលប្រគល់ទំនិញយឺតយ៉ាវ ..... ២៤
៣.១.១៤.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈមិនអនុលោមតាមគោលការណ៍លទ្ធកម្ម សាធារណៈ ..... ២៤
៣.១.១៥.ការអនុវត្តគម្រោងលទ្ធកម្មដែលមិនបានកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ..... ២៧
៣.១.១៦.ការអនុវត្តកិច្ចលទ្ធកម្មសំណង់មិនទាន់សមស្របទៅនឹងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យា ..... ២៨
៣.១.១៧.ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃ និងក្រុមហ៊ុនទទួលការពុំស្របនឹងកម្មវត្ថុដែលត្រូវដេញថ្លៃ ..... ២៩

៣.១.១៨.ការចំណាយមុនគោលការណ៍យល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និង
ហិរញ្ញវត្ថុ........................................................................................................................................២៩
៣.១.១៩.ការចំណាយ និងការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃ
មាតិកាថវិការបស់រដ្ឋ ..................................................................................................................៣១
៣.១.២០.ភាពខ្វះចន្លោះក្នុងការរៀបចំរបាយការណ៍តាមដានការអនុវត្តចំណាយថវិការដ្ឋប្រចាំឆ្នាំ៣៣
៣.១.២១.កង្វះខាតក្នុងការរៀបចំរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្មរបស់អង្គ
ភាពថវិកា........................................................................................................................................៣៤
៣.១.២២.ការអនុវត្តថវិកាកម្មវិធីពុំទាន់បានពេញលេញ.......................................................................៣៥
៣.១.២៣.កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ..........................................................៣៦
៣.១.២៤.ការអនុវត្តចំណាយថវិការដ្ឋទេយ្យបុរេប្រទានពុំទាន់ត្រឹមត្រូវតាមនីតិវិធី...................................៣៦
៣.១.២៥.ការប្រគល់ទទួលសំណង់មុនកាលបរិច្ឆេទគណៈកម្មការអន្តរក្រសួងចូលរួម .........៣៧
៣.១.២៦.ការពុំទាន់បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ .......................................................................៣៩
៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ................................................................................៣៩
៣.២.១.កង្វះខាតក្នុងការគ្រប់គ្រងចំណូល និងបំណុលភាស៊ី ផ្សារ ចំណត កំពង់ដ កំពង់ផែ..៣៩
៣.២.២.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព ..............................៤១
៣.២.៣.កង្វះខាតក្នុងការចុះអធិការកិច្ចត្រួតពិនិត្យគុណភាព សុវត្ថិភាព និងទប់ស្កាត់សំណង់
មិនប្រក្រតីខុសបច្ចេកទេស .............................................................................................................៤២
៣.២.៤.កង្វះខាតក្នុងការសម្រេចតែងតាំងសមាសភាពគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យ
សម្បត្តិរដ្ឋខេត្ត ................................................................................................................................៤៣
៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម.................................................................៤៦
៤.១.ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២១ .........................................................................៤៦
៤.២.ក្រុមហ៊ុនសហគ្រាសមួយចំនួនតូចមិនបានមកធ្វើបច្ចុប្បន្នភាព ..........................................................៤៦
៤.៣.ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម...............................................៤៧
៤.៤.ការប្រមូលពន្ធប៉ាតង់ ....................................................................................................................៤៨
៤.៥.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន..............៤៨
៤.៦.ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន.............................................៤៩
៤.៧.ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ.........................................៤៩
៤.៨.របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ .................................................................................៥០
៤.៩.ការប្រើប្រាស់វិក្កយបត្រ ................................................................................................................៥១
៤.១០.ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ .........................................................................................៥១
៤.១១.ការជម្រះបញ្ជីប្រាក់កក់ដែលបាននាំចូលតាមរបបប្រវេសន៍កាលិក...........................................៥២
៤.១២.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ.....................................................៥៣

៤.១៣.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ....................................................៥៤
៤.១៤.ការកត់ត្រាប្រាក់ពន្ធតែមប្រើសារពើពន្ធ.........................................................................៥៥
៤.១៥.ការប្រមូលពន្ធអចលនទ្រព្យ ......................................................................................៥៥
៤.១៦.ក្រសួងស្ថាប័នមួយចំនួនពុំបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ ...................៥៦
៤.១៧.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ .........................................................៥៧
៤.១៨.ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈនៅមានកម្រិត.......................................៥៨
៤.១៩.ការបំបែកគម្រោងចំណាយដើម្បីតម្រូវតាមសិទ្ធិសម្រេច ................................................៦០
៤.២០.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២១.......................៦១
៤.២១.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ .......................................................... ៦២
៥. សេចក្ដីសន្និដ្ឋាន............................................................................................................៦៣

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២១

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០២១ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័នរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **២៦ ៩០៨ ៩៨៣,៥លានរៀល** ស្មើនឹង **២៤,៣៥%** នៃផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **២,៥%** ហើយថយចុះ **៥,៦%** ធៀបនឹងការអនុវត្តឆ្នាំ២០២០។ ចំណូលថវិកានេះ គឺជាលទ្ធផលនៃកិច្ចប្រឹងប្រែងយូរឆ្នាំរបស់រាជរដ្ឋាភិបាលលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរួមចំណែកពីសកម្មភាពសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ការអនុវត្តចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អប្រសើរតាមរយៈយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ យុទ្ធសាស្ត្រកំណែទម្រង់ និងទំនើបកម្មគយ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដូចជា៖ ការពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេស និងការអនុវត្តនីតិវិធីគយ ការពង្រឹងអនុលោមភាព និងប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ ការពង្រឹងយន្តការគ្រប់គ្រងហានិភ័យនិងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ការពង្រឹងវប្បធម៌អនុលោមភាពរបស់វិស័យឯកជន ការពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធបញ្ជរតែមួយ និងការពង្រឹងអភិបាលកិច្ចអង្គភាពគយ និងការអភិវឌ្ឍស្ថាប័ន។

ការប្រមូលចំណូលពន្ធអាករបានលទ្ធផលដ៏ល្អប្រសើរនេះអាចសម្រេចទៅបានដោយសារអគ្គនាយកដ្ឋានពន្ធដារគ្រប់គ្រងចំណូលពន្ធមានកំណើនខ្ពស់ជាបន្តបន្ទាប់។ ក្នុងន័យនេះ វាបានឆ្លុះបញ្ចាំងពីការចូលរួមយ៉ាងសកម្មនូវកំណែទម្រង់មុតស្រួច និងស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យពិសេសកំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការអភិវឌ្ឍន៍ ការកសាងសមត្ថភាពស្ថាប័ន ការបញ្ចូលបច្ចេកទេសព័ត៌មានវិទ្យា កំណែទម្រង់រដ្ឋបាលសារពើពន្ធ ដើម្បីឱ្យក្លាយជារដ្ឋបាល

សារពើពន្ធទំនើប។ សមិទ្ធផលទាំងនេះសរបញ្ជាក់ពីភាពត្រឹមត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងផ្លែផ្កានៃកំណែទម្រង់មុតស្រួច និងស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដោយឡែក ចំណូលមិនមែនសារពើពន្ធ ឆ្លងកាត់វិបត្តិនៃជំងឺកូវីដ-១៩ អស់រយៈពេល២ឆ្នាំ មូលដ្ឋាននៃចំណូលមិនមែនសារពើពន្ធក្នុងឆ្នាំ២០២១ ត្រូវបានផ្លាស់ប្តូរពីការពឹងផ្អែកខ្លាំងលើប្រភពចំណូលដែលពាក់ព័ន្ធទៅនឹងវិស័យទេសចរណ៍ មកពឹងផ្អែកលើមូលដ្ឋានប្រភពចំណូលពីវិស័យទូរគមនាគមន៍ វិស័យរ៉ែ និងប្រាក់ចំណេញពីសហគ្រាសសាធារណៈវិញ។ ជាក់ស្តែង ក្នុងឆ្នាំ២០២១ ចំណូលពីផលទុនពីវិស័យទូរគមនាគមន៍ មានកំណើនខ្ពស់ ដែលជាសមិទ្ធផលនៃការកែទម្រង់ និងកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នដែលទទួលបន្ទុកក្នុងការជំរុញ និងដាក់ចេញនូវវិធានការតឹងរឹងក្នុងការគ្រប់គ្រងលើអនុលោមភាពរបស់ប្រតិបត្តិករ និងការតឹងទារបំណុល។

តាមលទ្ធផលនៃការធ្វើសវនកម្មលើចំណូលបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតមានជាអាទិ៍៖ ការប្រកាសពន្ធ និងអាករក្នុងនាមសហគ្រាសដើមមួយចំនួនតូចដោយគ្មានការទទួលស្គាល់, ការប្រកាសបរិមាណទំនិញនិងតម្លៃទំនិញនាំចូលមួយចំនួននៅមានកម្រិត, ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២១, ក្រុមហ៊ុនសហគ្រាសមិនបានមកធ្វើបច្ចុប្បន្នភាព, ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម, ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមបណ្តាក្រសួងស្ថាប័ន, ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ, ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ, ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់មានរបាយការណ៍សវនកម្មពីសវនករឯករាជ្យ, ការប្រើប្រាស់វិក្កយបត្រ, ការត្រួតពិនិត្យលិខិតប្រកាសពន្ធ, ការជម្រះបញ្ជីប្រាក់កក់ដែលបាននាំចូលតាមរបបប្រវេសន៍កាលិក, ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ, ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ, ការអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈមិនទាន់បានពេញលេញ, កង្វះខាតក្នុងការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារ, ភាពយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួលជួលដីទំនេរ, ចំណូលផ្សេងៗនិងបង្វែររង់ចាំដំណោះស្រាយ, ការគ្រោងថវិកាចំណូលសេវាសាធារណៈពុំទាន់បានសមស្រប, ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ, និងភាពយឺតយ៉ាវក្នុងការបង់ចំណូលបែងចែកថវិកាជាតិ ៥% និង៥១%។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **៣១ ៩៨៤ ៣៧៩,៧** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៨,៣%** ហើយស្មើនឹង**២៨,៩៤%** នៃផ.ស.ស គឺមានការកើនឡើង**៨,៤%** ធៀបនឹងការអនុវត្តឆ្នាំ២០២០។ ចំណាយថវិកាមានការកើនឡើងខ្ពស់នៃចំណាយអន្តរាគមន៍ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលមិនធ្លាប់មានពីមុនមក ដើម្បីរក្សាលំនឹងជីវភាពប្រជាជន ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងអ្នកបាត់បង់ការងារ និងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ក្នុងបរិការណ៍កម្ពុជាបានប្រឈមនូវការឆ្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍។ បន្ថែមលើនេះ បើទោះបីជាតម្រូវការចំណាយផ្នែកសុខាភិបាលក្នុងឆ្នាំ២០២១ មានកម្រិតខ្ពស់ ចំណាយថវិកាជារួមនៅតែអាចផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាលក្នុងការអនុវត្ត

គោលនយោបាយអាទិភាពនានា ដូចជាការបន្តអនុវត្តគោលនយោបាយគាំពារសង្គម និងកម្មវិធីកែទម្រង់ជារចនាសម្ព័ន្ធនានា ការពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ ការវិនិយោគលើធនធានមនុស្ស ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងភាពប្រកួតប្រជែង។ រាជរដ្ឋាភិបាលបានបន្តធ្វើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា តាមរយៈការកំណត់លំដាប់អាទិភាព និងធ្វើវិចារណកម្មលើមុខចំណាយលែងចាំបាច់នានា សំដៅបង្វែរថវិកាសម្រាប់ជួយទ្រទ្រង់ការដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍។ កញ្ចប់ថវិកានេះបានដើរតួជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់ ដែលបានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីអន្តរាគមន៍សង្គមសេដ្ឋកិច្ចមុតស្រួច ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព រួមមាន ការផ្តល់វ៉ាក់សាំងបង្ការ និងការព្យាបាលជំងឺកូវីដ-១៩ កម្មវិធីឧបត្ថម្ភប្រាក់ឈ្នួល និងការបណ្តុះបណ្តាលសម្រាប់និយោជិតដែលបានព្យួរការងារ កម្មវិធីសាច់ប្រាក់ពលកម្ម កម្មវិធីឧបត្ថម្ភសាច់ប្រាក់ កម្មវិធីឧបត្ថម្ភស្បៀងក្នុងពេលបិទខ្ទប់ និងការផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម។ រាជរដ្ឋាភិបាលបានបន្តធ្វើវិចារណកម្មចំណាយថវិកាដោយសារមានការកើនឡើងបន្ទុកចំណាយយ៉ាងគំហុកលើផ្នែកសុខាភិបាល សំដៅគាំទ្រដល់ការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំង និងការគ្រប់គ្រងបាននៃជំងឺកូវីដ-១៩ ដើម្បីឈានទៅសម្រេចឱ្យបាននូវ "ភាពស៊ាំសហគមន៍" ដែលជាកត្តាស្នូលសម្រាប់ជំរុញកិច្ចដំណើរការសង្គមសេដ្ឋកិច្ច ឆ្ពោះទៅរកប្រក្រតីភាពថ្មីនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលត្រូវបានអនុញ្ញាតឱ្យធ្វើនិយ័តភាពវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលសម្រេចបានលទ្ធផលដូចតទៅ៖ (១)-ការអនុវត្តកម្មវិធីជំនួយសង្គមជួយជនក្រីក្រ និងងាយរងគ្រោះ (២)-ការទិញមន្ទីរពេទ្យស្រ្តី នគរទេព ដោយប្រើប្រភពចំណូលសប្បុរសជន (៣)- ការផ្តល់ឱ្យអគ្គិសនីកម្ពុជាខ្ចីក្នុងគោលដៅដោះស្រាយតម្រូវការថាមពលអគ្គិសនីរយៈពេលវែង (៤)-ការបង្វិលសងអាករលើតម្លៃបន្ថែម (៥)-ការអនុវត្តកម្មវិធីប្រយុទ្ធ និងទប់ស្កាត់ការរីករាតត្បាតជំងឺកូវីដ-១៩ និង(៦)-ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

សរុបមក ថវិកាឆ្នាំ២០២១ ជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដែលផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យនានា ទាំងក្នុង និងក្រៅ សំដៅធានាលំនឹងសង្គម សេដ្ឋកិច្ចកម្ពុជា និងការពារអាយុជីវិតប្រជាជនពីការរាតត្បាតនៃជំងឺកូវីដ-១៩ ព្រមទាំងគាំទ្រដល់ការស្តារសេដ្ឋកិច្ចកម្ពុជាឱ្យត្រឡប់ទៅកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏នឹងបន្តប្តេជ្ញាជំរុញវឌ្ឍនភាពក្នុងការដ្ឋានកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ព្រមជាមួយនឹងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងវិស័យអាទិភាពផ្សេងទៀត ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច។

បន្ថែមលើនេះ ការអនុវត្តចំណាយឆ្នាំ២០២១ នៅតែអាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពតាមរយៈការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍សំខាន់ៗមួយចំនួន ដូចជា៖ (១)-វិភាជន៍ថវិកាតាមលំដាប់អាទិភាព ដែលក្នុងនោះ បន្តផ្តល់ថវិកាចំពោះមុខចំណាយដែលចាំបាច់ ខណៈរឹតបន្តឹងខ្លាំងក្នុងការផ្តល់ថវិកាសម្រាប់មុខចំណាយមិនសូវចាំបាច់ និងមិនផ្តល់ថវិកាដល់ចំណាយមិនចាំបាច់ និង

ចំណាយលែងចាំបាច់ (២)-បន្តអនុវត្តគោលនយោបាយនៃការមិនដំឡើងប្រាក់បៀវត្សក្នុងឆ្នាំ២០២១ និងអនុញ្ញាតឱ្យជ្រើសរើសក្របខ័ណ្ឌមន្ត្រីថ្មី ត្រឹមស្មើនឹងចំនួនដែលត្រូវទទួលបានក្នុងឆ្នាំ២០២០ (៣)-គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយរួមបញ្ចូលនូវការបង្កើនប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការជំរុញអនុវត្តដោយហ្មត់ចត់នូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និង(៤)-បន្តពង្រឹងសមត្ថភាព និងតួនាទីរបស់សវនកម្ម រួមទាំងការងារអធិការកិច្ច ដើម្បីរួមចំណែកទប់ស្កាត់កំហុសឆ្គង និងពង្រឹងអភិបាលកិច្ចនៅក្នុងការគ្រប់គ្រង និងការអនុវត្តហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាដើម្បីបង្កើននូវប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រសួង ស្ថាប័ននានា។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា៖ ការកាន់កាប់កិច្ចបញ្ជិកាបេឡាចំពោះប្រាក់បេសកកម្មមិនទាន់ពេញលេញ, ការយកសក្ខីបត្រឆ្នាំចាស់មកទូទាត់ក្នុងឆ្នាំថ្មី, ការពុំបានអនុវត្តពិន័យលើក្រុមហ៊ុនដែលប្រគល់ទំនិញយឺត, ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈមិនអនុលោមតាមគោលការណ៍លទ្ធកម្មសាធារណៈ, ការអនុវត្តគម្រោងលទ្ធកម្មដែលមិនបានកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ, ការអនុវត្តកិច្ចលទ្ធកម្មសំណង់មិនទាន់សមស្របទៅនឹងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យា, ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃ និងក្រុមហ៊ុនទទួលការពុំស្របនឹងកម្មវត្ថុដែលត្រូវដេញថ្លៃ, ការចំណាយមុនគោលការណ៍យល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការចំណាយនិងការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ, ភាពខ្វះចន្លោះក្នុងការរៀបចំរបាយការណ៍តាមដានការអនុវត្តចំណាយថវិការដ្ឋប្រចាំឆ្នាំ, កង្វះខាតក្នុងការរៀបចំរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្មរបស់អង្គភាពថវិកា, ការអនុវត្តថវិកាកម្មវិធីពុំទាន់បានពេញលេញ, កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ, ការអនុវត្តចំណាយថវិការជួទេយ្យបុរេប្រទានពុំទាន់ត្រឹមត្រូវតាមនីតិវិធី, ការប្រគល់ទទួលសំណង់មុនកាលបរិច្ឆេទគណៈកម្មការអន្តរក្រសួងចូលរួម, ការពុំទាន់បានអនុវត្តកិច្ចលទ្ធកម្ម, ក្រសួងស្ថាប័នមួយចំនួនពុំបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ, ការទូទាត់និងការកត់ត្រាចំណាយ, ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់, ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២១, និងការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន**៥ ៣១៣ ៥៧៦,៧** លានរៀល ស្មើនឹង**៩៧,២%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន**៥ ៤៦៥ ៦៥០,០** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន**១៥២ ០៧៣,៣** លានរៀល។

## ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**២ ៩៤៣ ៨០៦,៩** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**៣២,២%** និងចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្តអនុវត្តបានចំនួន**២ ៨២៤ ៩៩២,៦** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**២៦,៩%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន**៥០៩ ៨៦៧,៤** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៣,៤%** និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន**៤៩៧ ៤៤៩,៤** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៥,៧%**។ រីឯចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានចំនួន**៩៥០ ២៧៤,១** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ**៥,១%** និងចំណាយថវិការបស់រដ្ឋបាលឃុំសង្កាត់ អនុវត្តបានចំនួន**៧១១ ៤៧៨,៧**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**២១,៣%**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ ការប្រមូលពន្ធប៉ាតង់, ការកត់ត្រាប្រាក់ពន្ធតែមប្រើសារពើពន្ធ, ការប្រមូលពន្ធអចលនទ្រព្យ, កង្វះខាតក្នុងការគ្រប់គ្រងចំណូល និងបំណុលភាស៊ីផ្សារ ចំណត កំពង់ដ កំពង់ផែ, ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព, ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនៅមានកម្រិត, ការបំបែកគម្រោងចំណាយដើម្បីតម្រូវតាមសិទ្ធិសម្រេច, កង្វះខាតក្នុងការចុះអធិការកិច្ចត្រួតពិនិត្យគុណភាព សុវត្ថិភាព និងទប់ស្កាត់សំណង់មិនប្រក្រតីខុសបច្ចេកទេស, និងកង្វះខាតក្នុងការសម្រេចតែងតាំងសមាសភាពគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋខេត្ត។

## ១. សេចក្ដីផ្ដើម

### ១.១. លក្ខណៈទូទៅ

ច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជិកាគណនេយ្យ គណនីប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្ដាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្ដាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្ដល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

### ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០២២ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្ដាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០២១ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបចំនួន៩៧ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្ដង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងស្ដង់ដារសវនកម្មទូទៅដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្ដលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្ដុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្ដីសន្និដ្ឋាន និងផ្ដល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈមានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្ដល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០២១ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០
- ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស២ចុះថ្ងៃទី ០១៧/០៥០៨/រកម/៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

### ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០២១ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

## ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២១ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូល** | **២៦ ២៥០ ៣៣៦,០** | **២៦ ៩០៨ ៩៨៣,៥** | **១០២,៥%** |
| -ចំណូលចរន្ត | ១៩ ៧០៥ ៩៨៣,០ | ២០ ៤៦៧ ០៨៦,០ | ១០៣,៩% |
| -ចំណូលមូលធន | ១ ០៧៨ ៧០៣,០ | ១ ១២៨ ៣២០,៨ | ១០៤,៦% |
| +ចំណូលមូលធនក្នុងប្រទេស | ២២១ ២០៣,០ | ៥៦ ៨៨១,៩ | ២៥,៧% |
| +ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ៨៥៧ ៥០០,០ | ១ ០៧១ ៤៣៨,៩ | ១២៤,៩% |
| -ចំណូលមូលធនសម្រាប់គម្រោងដោយ ហិរញ្ញប្បទានក្រៅប្រទេស | ៥ ៤៦៥ ៦៥០,០ | ៥ ៣១៣ ៥៧៦,៧ | ៩៧,២% |
| **II. សរុបចំណាយ** | **៣៤ ៨៦៩ ៣០៨,៥*** | **៣១ ៩៨៤ ៣៧៩,៧** | **៩១,៧%** |
| -ចំណាយចរន្ត | ២១ ៣២២ ២៣១,២* | ១៩ ៤៩៤ ១៦៧,២ | ៩១,៤% |
| -ចំណាយមូលធន | ៨ ០៨១ ៤២៧,២ | ៧ ១៧៦ ៦៣៥,៨ | ៨៨,៨% |
| +វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្នុងប្រទេស | ៦ ៨៩៦ ២៣៧,២ | ៥ ៩៩២ ៨០២,៤ | ៨៦,៩% |
| +ការទូទាត់ការខ្ចី | ១ ១៨៥ ១៩០,០ | ១ ១៨៣ ៨៣៣,៤ | ៩៩,៩% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយ ហិរញ្ញប្បទានក្រៅប្រទេស | ៥ ៤៦៥ ៦៥០,០ | ៥ ៣១៣ ៥៧៦,៧ | ៩៧,២% |

**កំណត់សំគាល់:** កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២១ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

---

(*)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន ៤ ៦៧៩ ៦៣២,២២លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

## ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២១ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **២ ២២៦ ១០៨,៩** | **២ ៩៤៣ ៨០៦,៩** | **១៣២,២%** |
| -ចំណូលចរន្ត | ១ ២៦៤ ៨៥០,០ | ២ ០៤៧ ៥៩៤,៥ | ១៦១,៩% |
| •ចំណូលសារពើពន្ធ | ១ ០៥០ ៣២៣,០ | ១ ៧៩០ ៥៥១,០ | ១៧០,៥% |
| •ចំណូលពុំមែនសារពើពន្ធ | ២១៤ ៥២៧,០ | ២៥៧ ០៤៣,៤ | ១១៩,៨% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៧២៥ ៧៣០,៥* | ៦៦៣ ២០៨,២ | ៩១,៤% |
| - ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ២៣៥ ៥២៨,៤ | ២៣៣ ០០៤,២ | ៩៨,៩% |
| **II. សរុបចំណាយថវិកា** | **២ ២២៦ ១០៨,៩*** ** | **២ ៨២៤ ៩៩២,៦** | **១២៦,៩%** |
| -ចំណាយចរន្ត | ១ ៩៧៦ ១២៧,៩ | ២ ៤៣៦ ៥១៣,៥ | ១២៣,៣% |
| -ចំណាយមូលធន | ២៤៩ ៩៨១,០ | ៣៨៨ ៤៧៩,១ | ១៥៥,៤% |

***កំណត់សំគាល់:*** កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២១ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

* តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមដល់រដ្ឋបាលរាជធានី ខេត្តចំនួន ៤ ៤៥៣លានរៀល ក្នុងនោះ៖(១)-ឥណទានថវិកាចំនួន ២ ៦៥៥លានរៀល ផ្តល់ជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ), (២)-ឥណទានថវិកាចំនួន ៤៩៨លានរៀល ផ្តល់ជូនរដ្ឋបាលខណ្ឌសម្រាប់ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិកនៃការិយាល័យជំនាញដែលធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ (៣)-ឥណទានថវិកាចំនួន ១ ៣០០លានរៀល ផ្តល់ជូនមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនចំនួន ៥កន្លែងនៃ៤ខេត្ត និងបូកបញ្ចូលឥណទានថវិកាចំនួន ១៨ ០៧៦,៩លានរៀល ដើម្បីបើកប្រាក់បៀវត្សជូនមន្ត្រីរាជការសម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ របស់មន្ទីរសុខាភិបាលទាំង២០រាជធានី ខេត្តដែលរាជរដ្ឋាភិបាលបានបញ្ចូលក្របខណ្ឌក្នុងឆ្នាំ២០២១។

*** តួលេខនេះបូកបញ្ចូលឥណទានថវិកាបន្ថែមដល់រាជធានី ខេត្តចំនួន២២ ៥២៩,៩លានរៀល ក្នុងនោះ៖(១)-ឥណទានថវិកាចំនួន ២ ៦៥៥លានរៀលផ្តល់ជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ), (២)-ឥណទានថវិកាចំនួន ៤៩៨លានរៀល ផ្តល់ជូនរដ្ឋបាលខណ្ឌសម្រាប់ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិកនៃការិយាល័យជំនាញដែលធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ (៣)-ឥណទានថវិកាចំនួន ១ ៣០០លានរៀល ផ្តល់ជូនមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនចំនួន ៥កន្លែងនៃ៤ខេត្ត និង(៤)-ប្រកាសបន្ថែមឥណទានថវិកា ចំនួន១៨ ០៧៦,៩លានរៀល ដើម្បីបើក ប្រាក់បៀវត្សជូនមន្ត្រីរាជការសម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ របស់មន្ទីរសុខាភិបាលទាំង២០រាជធានី ខេត្តដែលរាជរដ្ឋាភិបាលបានបញ្ចូលក្របខណ្ឌក្នុងឆ្នាំ២០២១។

## ខ.២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២១ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៥២៧ ៦៨៩,៩** | **៥០៩ ៨៦៧,៤** | **៩៦,៦%** |
| -ចំណូលចរន្ត (មិនមែនសារពើពន្ធ) | ៣០ ២១៣,៣* | ២៧ ៨២៣,១ | ៩២,១% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៤៩១ ២៥១,៣** | ៤៧៧ ១៩៣,៣ | ៩៧,១% |
| **II. សរុបចំណាយថវិកា** | **៥២៧ ៦៨៩,៩** | **៤៩៧ ៤៤៩,៤** | **៩៤,៣%** |
| -ចំណាយចរន្ត | ៥២៧ ៦៨៩,៩*** | ៤៩៧ ៤៤៩,៤ | ៩៤,៣% |

<u>**កំណត់សំគាល់:**</u> កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២១ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

(*) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន ១៨ ៤១១,០លានរៀល ក្នុងនោះ៖ (១)- ថវិកាចំនួន ១៧១,០លានរៀល សម្រាប់ចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញ-ចូលតែមួយសម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត,(២)-បន្ថែមឥណទានថវិកាសេវាអនាម័យបរិស្ថានចំនួន៨ ០០០,០លានរៀល, (៣)-ឥណទានចំណូលសារពើពន្ធចែកលំលែកពីរដ្ឋបាលខេត្តចំនួន៤% ជូនរដ្ឋបាលក្រុង ស្រុកចំនួន៩ ៨៣០,០លានរៀល និង(៤)-ថវិកាចំនួន៤១០,០លានរៀល ប្រកាសបន្ថែមឥណទានថវិកាពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ចំណាយអភិវឌ្ឍន៍។

(**)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែម ចំនួន ១៩ ៣៨៤,០លានរៀល ក្នុងនោះ៖ (១)- ថវិកាចំនួន ៨ ០៣១,០លានរៀល ប្រកាសបន្ថែមឥណទានការិយាល័យជំនាញ ២០វិស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុក និង(២)-ថវិកាចំនួន១១ ៣៥៣,០លានរៀល ប្រកាសបន្ថែមឥណទានថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ចំណាយអភិវឌ្ឍន៍។ និងតួលេខនេះបូកបន្ថែមថវិកាចំនួន៨៤,៩លានរៀល សម្រាប់ការផ្ទេរមុខងារអប់រំនៅខេត្តបាត់ដំបង។

(***) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែម ចំនួន៣៧ ៨៧៩,៩លានរៀល ក្នុងនោះ៖ (១)-ចំណូលសារពើពន្ធចែកលំលែកពីរដ្ឋបាលខេត្តចំនួន៤% ជូនរដ្ឋបាលក្រុង ស្រុកចំនួន៩ ៨៣០,០លានរៀល,(២)-ថវិកាសេវាអនាម័យបរិស្ថានចំនួន៨ ០០០,០លានរៀល,(៣)-ថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន១១ ៣៥៣,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍, (៤)-ថវិកាពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទចំនួន៤១០,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍,(៥)- ថវិកាការិយាល័យជំនាញ ២០វិស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុក ចំនួន ៨ ០៣១,០លានរៀល,(៦)-ថវិកាសម្រាប់ការផ្ទេរមុខងារអប់រំនៅខេត្តបាត់ដំបង ចំនួន ៨៤,៩លានរៀល និង(៧)-ថវិកាចំនួន ១៧១,០លានរៀល សម្រាប់ចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញ-ចូលតែមួយសម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត។

## ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២១ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៩០៤ ០៤៧,៧** | **៩៥០ ២៧៤,១** | **១០៥,១%** |
| -ចំណូលមិនមែនសារពើពន្ធ | 0 | ៤៦ ២២៦,៤ | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិ | ៧០៩ ៥៤៨,0 | ៧០៩ ៥៤៨,0 | ១00,0% |
| -អតិរេកឆ្នាំ២០២០ | ១៩៤ ៤៩៩,៧(*) | ១៩៤ ៤៩៩,៧ | ១00,0% |
| **II. សរុបចំណាយថវិកា** | **៩០៤ ០៤៧,៧** | **៧១១ ៤៧៨,៧** | **៧៨,៧%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ៤៧ ៦៤២,៦ | ៣២ ៤៨៧,៦ | ៦៨,២% |
| - ចំណាយសង្កាត់ចំណុះក្រុង | ៧៦ ៥៥៤,៦ | ៥៦ ៣៣៤,៩ | ៧៣,៦% |
| -ចំណាយឃុំ | ៧៧៩ ៨៥០,៦ | ៦២២ ៦៥៦,២ | ៧៩,៨% |

<u>**កំណត់សំគាល់:**</u> កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២១ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន១៩៤ ៤៩៩,៧លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

# ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងចំណូលថ្នាក់ជាតិ

### ៣.១.១. ការប្រកាសពន្ធ និងអាករក្នុងនាមសហគ្រាសដើមមួយចំនួនតូចដោយគ្មានការទទួលស្គាល់

ដើម្បីប្រមូលប្រាក់ពន្ធ និងអាករលើវិស័យផលិតស្រាបៀរ និងអាជីវកម្មលក់ស្រាបៀរបន្តឱ្យមានប្រសិទ្ធភាព និងតម្លាភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ៥៩៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៨ ស្តីពីការទទួលស្គាល់ និងកាតព្វកិច្ចពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់ទំនិញ ឬសេវាក្នុងនាមសហគ្រាសដើម។ អ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំដែលបានបំពេញគ្រប់លក្ខខណ្ឌតម្រូវដោយអគ្គនាយកដ្ឋានពន្ធដារនឹងទទួលបានលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញ ឬសេវាក្នុងនាមសហគ្រាសដើមដែលមានកាតព្វកិច្ចប្រមូលពន្ធ និងអាករនានាជំនួសមុខឱ្យសហគ្រាសដើម។ បន្ថែមលើសពីនេះ ភ្នាក់ងារមានកាតព្វកិច្ចបង់ប្រាក់អាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលពីប្រាក់កម្រៃដែលភ្នាក់ងារទទួលបានពីការផ្គត់ផ្គង់ទំនិញ ឬសេវាក្នុងនាមសហគ្រាសដើមជូនរដ្ឋបាលសារពើពន្ធ។

តាមការពិនិត្យលិខិតប្រកាសពន្ធប្រចាំខែរបស់សហគ្រាសចែកចាយស្រាបៀរនៅតាមសាខាពន្ធដារខេត្តចំនួន៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សហគ្រាសមួយចំនួនតូចបានប្រកាសចំណូល និងបង់អាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលពីប្រាក់កម្រៃពីការលក់ទំនិញក្នុងនាមសហគ្រាសដើម ខណៈដែលសហគ្រាសទាំងនោះមិនទាន់បានទទួលលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញ ឬសេវាក្នុងនាមសហគ្រាសដើមដែលទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារនៅឡើយទេ។ ទោះជាយ៉ាងនេះក្តី អង្គភាពពន្ធដារព្រមទទួលនូវការប្រកាសពន្ធរបស់សហគ្រាសខាងលើ ក្នុងនាមសហគ្រាសដើមដោយសារក្នុងឆ្នាំ២០២១ មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធពិបាកនឹងជួបគ្នាដោយសារហានិភ័យនៃការឆ្លងកូវីដ-១៩។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារបានជំរុញភ្នាក់ងារទាំងនោះឱ្យចុះបញ្ជីជាបណ្តើរៗ និងស្នើរោងចក្រ (សហគ្រាសដើម) ផ្តល់ទិន្នន័យភ្នាក់ងាររបស់ខ្លួនមកអគ្គនាយកដ្ឋានពន្ធដារ។ ជាងនេះទៀត អគ្គនាយកដ្ឋានពន្ធដារបានដាក់នាឡិការវាស់ស្ទើរតែ ១០០%នៃរោងចក្រទាំងអស់។ ការប្រកាសពន្ធ និងអាករក្នុងនាមសហគ្រាសដើម ដែលមិនទាន់ទទួលបានលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញ ឬសេវាក្នុងនាមសហគ្រាសដើមចេញដោយអគ្គនាយដ្ឋានពន្ធដារ នាំឱ្យការប្រកាសពន្ធ និងអាករពុំទាន់ត្រឹមត្រូវ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំឱ្យអគ្គនាយកដ្ឋានពន្ធដារពិនិត្យភាពត្រឹមត្រូវនៃការប្រកាសចំណូលក្នុងនាមសហគ្រាសដើមរបស់សហគ្រាសខាងលើ ព្រមទាំងជំរុញឱ្យក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជនចូលរួមសហការអនុវត្តឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានពន្ធដារបានខិតខំជំរុញទាំងភ្នាក់ងារចែកចាយបន្ត និងសហការជាមួយសហគ្រាសផ្គត់ផ្គង់ឱ្យមកចុះបញ្ជីពន្ធដារ។ ជាក់ស្តែង អគ្គនាយកដ្ឋានពន្ធដារបានបំពាក់ឧបករណ៍វាស់ចំណុះ (Flow Meter) នៅតាមរោងចក្រស្រាបៀរមួយចំនួន ដើម្បីជំរុញអភិបាលកិច្ចល្អ និងមានតម្លាភាព។ លើសពីនេះ អគ្គនាយកដ្ឋានពន្ធដារបានកំពុងរៀបចំ និងពិភាក្សាកែសម្រួលបទប្បញ្ញត្តិនានាទាក់ទិនការប្រកាសពន្ធក្នុងនាមសហគ្រាសដើម ដើម្បីប្រមូលពន្ធពីភ្នាក់ងារចែកចាយបន្ត និងសហគ្រាសផ្គត់ផ្គង់ឱ្យកាន់តែមានភាពសាមញ្ញ និងមានប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិសូមទទួលយកមតិបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិសូមលើកទឹកចិត្តក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាអគ្គនាយកដ្ឋានពន្ធដារពន្លឿនដំណើរការកែសម្រួលបទប្បញ្ញត្តិនានាទាក់ទិនការប្រកាសពន្ធក្នុងនាមសហគ្រាសដើម ដើម្បីប្រមូលចំណូលពន្ធ និងអាករឱ្យបានគ្រប់ជ្រុងជ្រោយ។

**៣.១.២.ការពុំបានកាត់ទុកជាមុននូវប្រាក់អាករលើតម្លៃបន្ថែម**

ដើម្បីជ្រុំជ្រែងដល់ការប្រមូលប្រាក់អាករលើតម្លៃបន្ថែមឱ្យបានពេញលេញ និងទាន់ពេលវេលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១៦១ សហវ.ពដ.ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៥ ស្តីពីកាតព្វកិច្ចសារពើពន្ធនៃកិច្ចលទ្ធកម្ម ត្រង់ប្រការ២ កថាខណ្ឌ១ បានចែងថា "អ្នកជាប់ពន្ធតាមរបបពិតដែលបានចុះកិច្ចសន្យាលទ្ធកម្មសាធារណៈទូទៅ និងកិច្ចសន្យាលទ្ធកម្មនៃគម្រោងថវិកាវិនិយោគឃុំ សង្កាត់ ត្រូវធ្វើការបង់ប្រាក់អាករលើតម្លៃបន្ថែមតាមរូបមន្តដូចមានចែងក្នុងប្រការ១ កថាខណ្ឌ ក ខាងលើ តាមវិធីកាត់ទុកជាមុនពីអាណត្តិកិច្ចទូទាត់ដោយរតនាគារជាតិ អង្គភាពគ្រប់គ្រង រូបិយប័ណ្ណ ឬរតនាគារ ខេត្ត ក្រុង"។ តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់ចំនួន៥៤៨របស់ក្រសួងមួយចំនួននៅអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានរតនាគារជាតិបានយល់ព្រមធ្វើការទូទាត់អាណត្តិបើកប្រាក់មួយចំនួនតូច ដោយពុំបានធ្វើការកាត់ទុកនូវទឹកប្រាក់អាករលើតម្លៃបន្ថែមចំនួន១០% នៃតម្លៃកិច្ចសន្យាទេ។ ការខកខានក្នុងការកាត់ទុកនូវទឹកប្រាក់អាករលើតម្លៃបន្ថែមនេះ នាំឱ្យការអនុវត្តកាតព្វកិច្ចសារពើពន្ធនៃអាណត្តិលទ្ធកម្មពុំទាន់បានត្រឹមត្រូវ និងអាចផ្តល់ឱកាសឱ្យអ្នកផ្គត់ផ្គង់គេចវេសកាតព្វកិច្ចពន្ធ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំឱ្យអគ្គនាយកដ្ឋានរតនាគារជាតិអនុវត្តការកាត់ទុកនូវទឹកប្រាក់អាករលើតម្លៃបន្ថែមឱ្យខានតែបាន ដើម្បីចូលរួមប្រមូលអាករលើតម្លៃបន្ថែមពីការកាត់ទុកនៃអាណត្តិលទ្ធកម្មឱ្យបានទាន់ពេលវេលា។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺថា ករណីដែលមិនបានកាត់ពន្ធទុកជាមុននូវប្រាក់អាករលើតម្លៃបន្ថែម មិនដូចករណីអាណត្តិលទ្ធកម្មទូទៅដែលទូទាត់ត្រង់ទៅក្រុមហ៊ុនទេ គឺដោយសារតែការទូទាត់នោះពាក់ព័ន្ធនឹងថវិកាបុរេ

ប្រទាន ដែលក្រសួងបានទទួលចំនួន៦០%នៃគម្រោងចំណាយក្នុងការអភិវឌ្ឍសម្ភារបរិក្ខារបច្ចេកទេស សម្ភារបង្រៀន និងការកែលម្អបរិស្ថាន។ ដូច្នេះ ទើបធ្វើឱ្យអគ្គនាយកដ្ឋានរតនាគារជាតិមានផលលំបាកមិនអាចធ្វើការកាត់ពន្ធទុកជាមុនបាន ដោយការទូទាត់នោះមានទាំងការទូទាត់ជម្រះបញ្ជីបុរេប្រទាន៦០% និងទាំងការទូទាត់បង្គ្រប់៤០% លើគម្រោងចំណាយដែលមានមុខសញ្ញាច្រើនបញ្ចូលគ្នា ហើយក្នុងនោះមានទាំងការងារអនុវត្តដោយអង្គភាពក្រោមឱវាទក្រសួងផ្ទាល់ និងការងារដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនដែលត្រូវជាប់កាតព្វកិច្ចបង់ពន្ធ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏អគ្គនាយកដ្ឋានរតនាគារជាតិជំរុញឱ្យក្រុមហ៊ុនផ្គត់ផ្គង់បង់ពន្ធ និងបញ្ជាក់អំពីការបានបង់ពន្ធ ហើយក្រុមហ៊ុនបានភ្ជាប់នូវឯកសារមួយចំនួនដែលបញ្ជាក់អំពីការបង់ពន្ធផងដែរ។

ករណីដែលមានការទូទាត់ពាក់ព័ន្ធនឹងបុរេប្រទានដែលមានសកម្មភាពច្រើន ហើយក្នុងនោះមានកិច្ចសន្យាជាមួយក្រុមហ៊ុនដែលជាប់កាតព្វកិច្ចពន្ធ អគ្គនាយកដ្ឋានរតនាគារជាតិនឹងមានវិធានការសហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ និងក្រសួង ស្ថាប័នសាមី ដើម្បីញែកបំបែកអាណត្តិបើកប្រាក់ទូទាត់ត្រង់ជូនក្រុមហ៊ុនតែម្តង ដើម្បីមានមូលដ្ឋានអាចកាត់ពន្ធទុកជាមុនបានលើអាណត្តិបើកប្រាក់ទូទាត់បង្គ្រប់នូវទឹកប្រាក់ពន្ធ១០%នៃតម្លៃកិច្ចសន្យា។ ក្នុងករណីក្រុមហ៊ុនបញ្ជាក់ថាបានបង់ពន្ធរួចរាល់ ឬករណីមិនអាចកាត់ពន្ធទុកជាមុនលើអាណត្តិទូទាត់បាន គឺត្រូវតែភ្ជាប់ឯកសារបញ្ជាក់អំពីការបង់ពន្ធឱ្យបានច្បាស់លាស់។ ករណីមិនមានឯកសារបញ្ជាក់ច្បាស់លាស់ទេ អគ្គនាយកដ្ឋានរតនាគារជាតិនឹងជូនដំណឹងអំពីករណីមិនបានកាត់ពន្ធទុកជាមុននេះទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីមានវិធានការបន្ត។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិស្នើឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងអគ្គនាយកដ្ឋានរតនាគារជាតិអនុវត្តការកាត់ទុកនូវទឹកប្រាក់អាករលើតម្លៃបន្ថែមចំពោះកិច្ចលទ្ធកម្មឱ្យបានគត់មុត ដើម្បីបង្ការ និងការពារនូវការគេចវេសពន្ធជាយថាហេតុ។

### ៣.១.៣.ការប្រកាសបរិមាណទំនិញនិងតម្លៃទំនិញនាំចូលមួយចំនួននៅមានកម្រិត

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដោយបានចែងថា នាយកដ្ឋានផែនការ និងបច្ចេកទេសមានតួនាទី និងភារកិច្ចដូចជា៖ ស្រាវជ្រាវ និងចងក្រងនូវទិន្នន័យតម្លៃគិតពន្ធគយលើទំនិញនាំចេញ-នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់ឱ្យបានសមស្របតាមភាពជាក់ស្តែង សម្រាប់ជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានចេញលិខិតស្តីពីការកែសម្រួលតារាងទិន្នន័យតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញនាំចូល នាំចេញមួយចំនួន បានបញ្ជាក់ថា តារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណានេះនឹងត្រូវដាក់ឱ្យអនុវត្តចំពោះទំនិញដែលចូលមកបំពេញបែបបទផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនេះតទៅរហូតដល់មានការសម្រេចជាថ្មី។

តាមការធ្វើសវនកម្មនៅអង្គភាពមូលដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ការប្រកាសបរិមាណ និងតម្លៃទំនិញនាំចូលដែកសរសៃកង ឬដើម នៅមានកម្រិតទាបជាងតម្លៃចម្លងការដែលបានចេញសម្រាប់អនុវត្តឆ្នាំ២០២១។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមករណីការប្រកាសតម្លៃដែកទាបជាងតម្លៃគិតពន្ធគយសម្រាប់ជាមូលដ្ឋានពិចារណា និងករណីខ្លះប្រកាសបរិមាណខុសៗគ្នាក្នុងជើងដឹកជញ្ជូនផ្សេងគ្នា ដូចជា៖ តាមបទប្បញ្ញត្តិជាធរមាន តម្លៃគិតពន្ធគយគឺជាតម្លៃចម្លងការ (ពោលគឺ "ថ្លៃទិញ-លក់ពិត") តារាងតម្លៃគិតពន្ធគយសម្រាប់ជាមូលដ្ឋានពិចារណា ដែលចេញដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាគឺប្រើប្រាស់តែជាមូលដ្ឋានសម្រាប់ឱ្យមន្ត្រីគយមានសមត្ថកិច្ចធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតហានិភ័យនៃការប្រកាសតម្លៃរបស់អ្នកនាំចូលប៉ុណ្ណោះ តម្លៃគិតពន្ធគយដែលអ្នកនាំចូលប្រកាសជាក់ស្តែងអាចប្រហាក់ប្រហែល ឬអាចខ្ពស់ជាង ឬអាចទាបជាងតារាងតម្លៃគិតពន្ធគយសម្រាប់ជាមូលដ្ឋានពិចារណា ដែលមិនឆ្លុះបញ្ចាំងថាករណីនេះមិនអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។ ជាមួយគ្នានេះ ការប្រកាសទម្ងន់សរុបខុសគ្នាក្នុងជើងដឹកជញ្ជូនផ្សេងគ្នាក៏មិនឆ្លុះបញ្ចាំងថាមិនសមស្របដែរ ដែលករណីនេះអាចបណ្តាលមកពីហេតុផលផ្សេងៗ ដូចជា ការបញ្ជាទិញសម្រាប់តែបរិមាណនោះ ឬក៏បរិមាណដែកផ្គត់ផ្គង់ពីបរទេសមិនមានស្តុកគ្រប់គ្រាន់ជាដើម។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពបន្តទៀត។

### ៣.១.៤.ការអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈមិនទាន់បានពេញលេញ

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់មាត្រា៦ បានចែងថា "ក្រសួង-ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធ បំពេញភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធដូចតទៅ៖ ១.រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំសម្រាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ២.ដឹកនាំនិងគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ៣.អនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន... "។ និងប្រកាសរួមលេខ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ត្រង់ប្រការ១ បានចែងថា "អនុញ្ញាតឱ្យក្រសួងព័ត៌មានអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ" និងតាមតារាងឧបសម្ព័ន្ធជាប់នឹងប្រកាសរួមលេខ១០០៣ សហវ.ប្រកចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព័ត៌មានបានកំណត់ពីការគ្រប់គ្រង និងប្រមូលចំណូលពី៖ ១.ប្រមូលចំណូលពីការផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ ២.ផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ ៣. អាជីវកម្ម គ្រឹះស្ថានបោះពុម្ពផ្សាយ ៤. អាជីវកម្មរោងពុម្ព..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មានមិនទាន់បានអនុវត្តការប្រមូលចំណូលពីកម្រៃផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ អាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ និងអាជីវកម្មរោងពុម្ពឱ្យបានពេញលេញ ដើម្បីបង់ចូលថវិកាជាតិនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មាន គួរធ្វើការណែនាំដល់អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ឱ្យធ្វើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈខាងលើឱ្យមានប្រសិទ្ធភាព និងពេញលេញ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងព័ត៌មានសូមធ្វើការបញ្ជាក់ថា អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍បានបំភ្លឺថា ការពុំទាន់បានប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ ពាណិជ្ជកម្មតាមអាហ្វីស និងតាមភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម ដោយសារតែអតិថិជន និងអាជ្ញាធរមានសមត្ថកិច្ចនៅពុំទាន់មានការយល់ដឹងពីនីតិវិធី និងលិខិតបទដ្ឋានដែលចូលជាធរមាន ដែលកំពុងតែធ្វើការកែទម្រង់ជាញឹកញាប់របស់ក្រសួង ស្ថាប័ន និងសមត្ថកិច្ចពាក់ព័ន្ធ។ រដ្ឋទេយ្យករចំណូលរងបានធ្វើរបាយការណ៍បញ្ជីបេឡាជាប្រចាំថ្ងៃ និងបានប្រើប្រាស់ប័ណ្ណចំណូលពីការប្រមូលសេវាសាធារណៈ និងសេវាសោតទស្សន៍ ប័ណ្ណចំណាយក៏បានប្រើប្រាស់ជាប្រចាំថ្ងៃផងដែរ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងព័ត៌មាន និងធ្វើការណែនាំដល់អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ឱ្យធ្វើការខិតខំពង្រឹង និងប្រមូលចំណូលពីសេវាសាធារណៈរបស់ខ្លួនឱ្យបានពេញលេញ និងមានប្រសិទ្ធភាពខ្ពស់។

**៣.១.៥.កង្វះខាតក្នុងការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារ**

សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ ស្ដីពីកិច្ចបញ្ជីកាគណនេយ្យរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ចំណុច ៣.១ បានបញ្ជាក់ថា បញ្ជីបេឡាសាច់ប្រាក់ប្រើសម្រាប់កត់ត្រានូវចំនួនទឹកប្រាក់រដ្ឋទេយ្យចំណូល ដែលបានទទួលពីអតិថិជន និងចំនួនទឹកប្រាក់ដែលបានចំណាយ និងចំនួនទឹកប្រាក់ដែលនៅសល់។ បញ្ជីបេឡាសាច់ប្រាក់រួមមាន បញ្ជីបេឡាសាច់ប្រាក់នៅធានាគារ(គំរូ០១) និងបញ្ជីបេឡាសាច់ប្រាក់នៅក្នុងដៃ (គំរូ០២) និងចំណុចទី៩ បរិបទនៃកិច្ចបញ្ជិកាគណនេយ្យរបស់រដ្ឋទេយ្យករចំណូល គ្រេទី៦កំណត់ថា រដ្ឋទេយ្យករចំណូលត្រូវបង្កើតបញ្ជីបេឡាសាច់ប្រាក់នៅក្នុងដៃ និងបញ្ជីសាច់ប្រាក់នៅធនាគារដាច់ដោយឡែកពីគ្នា និងគ្រេទី៩កំណត់ថាបញ្ជីបេឡាសាច់ប្រាក់នៅធនាគារត្រូវបូកសរុបនៅដំណាច់ខែនីមួយៗ ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា៖

- ក្នុងឆ្នាំ២០២១រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងរបស់ក្រសួងព័ត៌មានបានរៀបចំបញ្ជីបេឡាសម្រាប់តាមដានសាច់ប្រាក់ចំណូលនៅក្នុងដៃ ប៉ុន្តែពុំទាន់បានរៀបចំបញ្ជីបេឡាសម្រាប់តាមដានសាច់ប្រាក់ចំណូលនៅធនាគារនៅឡើយទេ។

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានប្រមូលចំណូលចំនួន ៣ ៧៥១ ៤០៤ ៣៣៣រៀល ពីការជួលដី និងអគារមានចំនួន២៦ទីតាំង ដោយចំណូលទាំងនោះត្រូវបង្វែរចូលទៅក្នុងគណនីរបស់ក្រសួងនៅធនាគារជាតិ។ នៅពេលកត់ត្រាចំណូលក្នុងបញ្ជីរាយការណ៍បេឡា រដ្ឋទេយ្យករ ចំណូល ពុំបានធ្វើបញ្ជីបេឡាសាច់ប្រាក់នៅក្នុងដៃ និងបញ្ជីសាច់ប្រាក់នៅធនាគារដាច់ដោយឡែកពីគ្នានោះទេ គឺកត់ត្រាបញ្ចូលគ្នាតែមួយរវាងចំណូលជាសាច់ប្រាក់ក្នុងដៃ និងចំណូលបង្វែតាមគណនីធនាគារ ។

អាស្រ័យហេតុនេះក្រសួងព័ត៌មាន គួរធ្វើការរៀបចំបញ្ជីបេឡាសាច់ប្រាក់នៅធនាគារឱ្យបានត្រឹមត្រូវស្របតាមសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងបេឡាសាច់ប្រាក់នៅធនាគារ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍គួរធ្វើបញ្ជីបេឡាសាច់ប្រាក់ក្នុងដៃ និងបញ្ជីបេឡាសាច់ប្រាក់នៅធនាគារឱ្យបានដាច់ដោយឡែកពីគ្នា និងស្របតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងព័ត៌មានបានបញ្ជាក់ថាការបង់ចំណូលរបស់រដ្ឋទេយ្យករចំណូលក្រសួងព័ត៌មាន គឺបង់ចូលគណនីរបស់រតនាគារជាតិដោយផ្ទាល់ ដូចនេះរដ្ឋទេយ្យករចំណូលពុំមានបេឡាសាច់ប្រាក់នៅធានាគារឡើយ។ ចំណែកឯក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នឹងធ្វើការកែរលម្អ ព្រមទាំងជំរុញបន្ថែមនូវការងារអនុវត្តកន្លងមកដែលមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយឱ្យបានប្រសើរឡើងវិញ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៦.ភាពយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួលជួលដីទំនេរ**

ឧបសម្ព័ន្ធចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីបច្ចុប្បន្នភាពកិច្ចសន្យាជួលទីតាំងសាលមហោស្រពទន្លេបាសាក់បំពេញបន្ថែមលើខ្លឹមសារកិច្ចព្រមព្រៀងចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ រវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាមួយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប ត្រង់ចំណុចទី॥ ប្រការ៥ ចំណុច៦.២ ត្រេទី២ បានចែងថា "ពីឆ្នាំទី១៦ ដល់ឆ្នាំទី២០ គិតចាប់ពីខែមីនា ឆ្នាំ២០២១ ដល់ខែកុម្ភៈ ឆ្នាំ២០២៦ ត្រូវបង់ថ្លៃឈ្នួលចំនួន ២៨៩ ៣៥៥ (ពីររយប៉ែតសិបប្រាំបួនពាន់បីរយហាសិបប្រាំ) ដុល្លារអាម៉េរិក"។

តាមការពិនិត្យរបាយការណ៍ចំណូលថ្លៃជួលរោងចក្រ សហគ្រាស និងអចលនវត្ថុប្រចាំឆ្នាំ ២០២១ របស់ក្រសួងវប្បធ៌ម និងវិចិត្រសិល្បៈ បង្កាន់ដៃបង់ប្រាក់ថ្លៃឈ្នួល លិខិតស្នើសុំនានា និងកិច្ចសន្យាជួល ព្រមទាំងឧបសម្ព័ន្ធស្តីពីបច្ចុប្បន្នភាពកិច្ចសន្យាជួលទីតាំងដីទំនេរ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានដាក់លិខិតសំណើសុំទូទាត់ថ្លៃឈ្នួលជួលទីតាំងអតីតសាលមហោស្រពទន្លេបាសាក់ចំនួន ៣៦១ ៨៥៥,៦៦ ដុល្លារអាម៉េរិក (ចាប់ពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០២១ ចំនួន ៧៥ ៧២៦,៥០ ដុល្លារអាម៉េរិក និងចាប់ពីខែមីនា ដល់ខែធ្នូ ឆ្នាំ២០២១ ចំនួន ២៤១ ១២៩,១៦ដុល្លារអាម៉េរិក )នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២។ បន្ទាប់មក ភាគីក្រុមហ៊ុនបានដាក់លិខិតសុំបញ្ចុះថ្លៃឈ្នួលទីតាំង

ខាងលើចំនួន៥០% ប៉ុន្តែរហូតមកដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ ក្រសួងពុំទាន់មានការឆ្លើយតបចំពោះការស្នើសុំរបស់ភាគីក្រុមហ៊ុនទេ ហើយថ្លៃឈ្នួលខាងលើ ភាគីក្រុមហ៊ុនក៏ពុំទាន់បានបង់ដែរ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរបន្តជំរុញឱ្យភាគីក្រុមហ៊ុនបង់ថ្លៃឈ្នួលខាងលើឱ្យបានគ្រប់ចំនួនស្របតាមកិច្ចសន្យា។

ត្រង់ចំណុចនេះ ក្រសួងឆ្លើយបំភ្លឺថា ក្រសួងបានធ្វើលិខិតទារបំណុល (ចំនួន ៣១៦ ៨៥៥,៦៦ ដុល្លារអាម៉េរិក ចាប់ពីខែមករា-ធ្នូ ឆ្នាំ២០២១) ក្នុងនោះរួមមាន លិខិតទារបំណុលលេខ៥០ សណ-គហ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លិខិតស្នើសុំបញ្ចុះថ្លៃឈ្នួល៥០% *លេខ០៣០៦/២២* ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២របស់ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប លិខិតស្នើសុំសេចក្តីសម្រេចលេខ១១៩ ឆ.ត ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលិខិតយល់ព្រមបញ្ចុះតម្លៃ១០% លេខ៥៦៣៣ សហវ-អទច ចុះថ្ងៃទី២២ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រសួងសូមជូនភ្ជាប់បណ្ណបង់ប្រាក់របស់ធនាគារជាតិលេខ 001OCL1222070014 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបស្តីពីការទូទាត់បំណុល ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.៧.ចំណូលផ្សេងៗ និងបង្វែររង់ចាំដំណោះស្រាយ

ដើម្បីកត់ត្រាទទួលស្គាល់ចំណូលថវិកាឱ្យបានត្រឹមត្រូវតាមការិយបរិច្ឆេទ ឬឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ ត្រង់ឧបសម្ព័ន្ធទី២ ចំណុច១៣៤ "គណនីចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ"អំពីគណនីលេខ៤៧០៦ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬចំនួនទឹកប្រាក់ ដែលត្រូវបង្វែរទៅគណនីអកម្មផ្សេងទៀត (គណនីចំណូលថវិកា) នៅដំណាច់ឆ្នាំ។ តាមការពិនិត្យតារាងតុល្យភាពបណ្តោះអាសន្នគណនីថវិកាថ្នាក់កណ្តាលប្រចាំឆ្នាំ២០២១ នៅអគ្គនាយកដ្ឋានរតនាគារជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយមាននៅសល់សមតុល្យមួយចំនួន ពុំទាន់បានដោះស្រាយ និងជម្រះ/ផ្ទេរចូលគណនីចំណូលថវិកានៅឡើយ។ ភាពយឺតយ៉ាវក្នុងការដោះស្រាយ និងជម្រះ/ផ្ទេរចូលគណនីចំណូលថវិកាធ្វើឱ្យតួលេខចំណូលថវិកាពុំទាន់ត្រូវបានបង្ហាញត្រឹមត្រូវតាមការិយបរិច្ឆេទ ឬធ្វើឱ្យរបាយការណ៍ចំណូលថវិកាមានកំហុសនូវទឹកប្រាក់មួយចំនួន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរជំរុញឱ្យអគ្គនាយកដ្ឋានរតនាគារជាតិមាននិយាមជាក់លាក់ ធ្វើការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយ និងជម្រះ/ផ្ទេរចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយចូលគណនីចំណូលថវិកាឱ្យបានទាន់ការិយបរិច្ឆេទ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺថា ក្នុងតួលេខចំណូលរបស់ក្រសួងមួយ ដែលពុំទាន់បានដោះស្រាយដោយរង់ចាំនូវនីតិវិធី និងការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងាររបស់ក្រសួងនោះ ដើម្បីគោរពស្នើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាល។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តជំរុញដោះស្រាយចំណូលផ្សេងៗ រង់ចាំដោះស្រាយដើម្បីកត់ត្រាចំណូលទាន់ពេលវេលា។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិសូមលើកទឹកចិត្តក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាអគ្គនាយកដ្ឋានរតនាគារជាតិ ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធរួមគ្នាដោះស្រាយបញ្ហាខាងលើឱ្យបានគត់មុត។

**៣.១.៨.ការគ្រោងថវិកាចំណូលសេវាសាធារណៈពុំទាន់បានសមស្រប**

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិន មែនសារពើពន្ធ ត្រង់ជំពូកទី៤ មាត្រា៣៣ កឋាខណ្ឌទី២ បានចែងថា "ការគ្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ ត្រូវមានមូលដ្ឋានគ្រោងគិតចំណូលទៅតាមមុខចំណូលនីមួយៗឱ្យបានច្បាស់លាស់ ដោយផ្អែកលើបញ្ជីស្ថិតិបច្ចុប្បន្ន បញ្ជីសម្រង់ទិន្នន័យ និងស្ថានភាពនៃការអនុវត្តចំណូល..."។

តាមការពិនិត្យរបាយការណ៍ចំណូលរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងបានប្រមូលចំណូលពីផលទុននៃសកម្មភាពវប្បធម៌បានត្រឹមតែ៩០ ៩៥៥ ៣៧៧ រៀល ស្មើនឹង១,៩៥%ប៉ុណ្ណោះ បើធៀបទៅនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលមានចំនួនទឹកប្រាក់ ៤ ៦៥៨ ០០០ ០០០ រៀល។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរធ្វើការគ្រោងថវិកាចំណូលខាងលើឱ្យបានច្បាស់លាស់ ដើម្បីកុំឱ្យមានគម្លាតគ្នាឆ្ងាយខ្លាំងពេករវាងច្បាប់ហិរញ្ញវត្ថុ និងការអនុវត្តប្រមូលចំណូលជាក់ស្តែង។

ចំពោះចំណុចខាងលើ ក្រសួងបានបញ្ជាក់ថា ការគ្រោងចំណូលសម្រាប់ឆ្នាំN+1 (២០២១) ក្រសួងបានប្រជុំពិភាក្សាជាមួយនាយកដ្ឋានដែលប្រមូលចំណូលផ្ទាល់ ដោយផ្អែកលើការអនុវត្តជាក់ស្តែង៦ខែក្នុងឆ្នាំN (២០២០) ជាទូទៅការគ្រោងចំណូលប្រចាំឆ្នាំរបស់ក្រសួងគឺស្ថិតនៅចន្លោះ (+/-៥%) ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងឆ្នាំ២០២១ ពុំបានសម្រេចដូចការគ្រោងប្រចាំឆ្នាំ ដោយសារការរាលដាលជំងឺកូវីដ-១៩។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៩.ភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយ**

ប្រកាសលេខ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ត្រង់ប្រការ៤ បានកំណត់ថា "ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់"។

តាមការពិនិត្យទៅលើប្រព័ន្ធគ្រប់គ្រងប្រមូលចំណូលរបស់អង្គភាពប្រមូលចំណូល និងការពិនិត្យលើយន្តការនៃការប្រមូលចំណូលរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈពុំទាន់រៀបចំបង្កើតទីតាំងច្រកចេញ-ចូលតែមួយ ក្នុងការផ្តល់សេវាសាធារណៈលើវិស័យសិល្បៈ វប្បធម៌ និងភាពយន្តជូនអតិថិជនឱ្យស្របទៅនឹងប្រកាសខាងលើនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួររៀបចំទីតាំងដែលមានភាពសមរម្យមួយដើម្បីបង្កើតជាច្រកចេញ-ចូលតែមួយក្នុងការផ្តល់សេវាសាធារណៈលើវិស័យវប្បធម៌សិល្បៈ និងភាពយន្តជូនដល់អ្នកស្នើសុំសេវាសាធារណៈមានភាពងាយស្រួល និងឆាប់រហ័ស។

ត្រង់ចំណុចខាងលើនេះ ក្រសួងបានបំភ្លឺថា ចំពោះភាពយឺតយ៉ាវក្នុងការបង្កើតច្រកចេញចូលតែមួយផ្អែកតាមទិសដៅការងារ និងចំណារឯកភាពរបស់ **លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ដោយបានធ្វើការបែងចែកជាដំណាក់កាល៖

- ដំណាក់កាលទី១ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ និងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំអំពីបែបបទ និងនីតិវិធីសម្រាប់ការផ្តល់សេវាសាធារណៈរបស់ច្រកចេញចូលតែមួយនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវបានឯកភាព និងរង់ចាំចុះហត្ថលេខារបស់ **លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** នៅពេលបញ្ចប់នីតិវិធីជាមួយនាយកដ្ឋានពាក់ព័ន្ធ
- ដំណាក់កាលទី២ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មការនីតិកម្មបានប្រជុំត្រួតពិនិត្យ និងពិភាក្សាជាមួយនាយកដ្ឋានពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈលើទម្រង់បែបបទសំណុំឯកសារភ្ជាប់ និងនីតិវិធីនៃការស្នើសុំសេវានិងផ្តល់លទ្ធផលសម្រេចជូនប្រជាពលរដ្ឋ
- ដំណាក់កាលទី៣ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានស្នើសុំកញ្ចប់ថវិកាឆ្នាំ ២០២៣ សម្រាប់រៀបចំទីតាំងបំពាក់សម្ភារបរិក្ខារ និងរៀបចំបណ្តាញព័ត៌មានវិទ្យាសម្រាប់យន្តការច្រកចេញចូលតែមួយឱ្យបានសមស្របសម្រាប់ប្រជាពលរដ្ឋមកស្នើសុំសេវាសាធារណៈ
- ដំណាក់កាលទី៤ រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីដែលបម្រើការងារនៅច្រកចេញចូលតែមួយ និងផ្សព្វផ្សាយខ្លឹមសារនៃលិខិតបទដ្ឋានទាំងនេះដល់ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការថ្នាក់ជាតិ និងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ។ ហេតុដូចនេះទើបធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការបង្កើតយន្តការច្រកចេញចូលតែមួយរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១០.ភាពយឺតយ៉ាវក្នុងការបង់ចំណូលបែងចែកថវិកាជាតិ៥% និង៥១%

អនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ស្តីពីវិសោធនកម្ម មាត្រា៧ និងមាត្រា២០ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពី ការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈ ត្រង់មាត្រា២០ថ្មី បានចែងថា "ចំពោះច្បាប់ថវិកាឆ្នាំ២០០៥ ទូរគមនាគមន៍កម្ពុជាត្រូវផ្តល់ចំណូលដុលចំនួន ៥១% នៃសេវា ទូរគមនាគមន៍អន្តរជាតិ និង៥% នៃសេវាទូរគមនាគមន៍ក្នុងប្រទេសចូលថវិកាជាតិ។ សម្រាប់ បណ្តាឆ្នាំបន្តបន្ទាប់ យន្តការបែងចែកប្រាក់ចំណូលនឹ ត្រូវកំណត់តាមការផ្តល់អនុសាសន៍របស់ ជំនួយបច្ចេកទេសដែលផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី។ អនុសាសន៍នៃការបែងចែក នេះនឹងត្រូវពិភាក្សាដោយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានដល់ការឯកភាពគ្នាលើទម្រង់បែងចែកប្រាក់ចំណូលពី ទូរគមនាគមន៍កម្ពុជា..."។

សម្រាប់ការិយបរិច្ឆេទ ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ទូរគមនាគមន៍ កម្ពុជាពុំទាន់បានបង់ចំណូលបែងចែកថវិកាជាតិសម្រាប់ឆ្នាំ២០២១ ចំនួន ៣១៧ ៧៦៩,៥៨ ដុល្លារអាមេរិច នៅឡើយ។

អាស្រ័យហេតុនេះ ដើម្បីងាយស្រួលក្នុងការអនុវត្ត ទូរគមនាគមន៍កម្ពុជាគួរអនុវត្ត តាមអនុក្រឹត្យខាងលើ។

ឆ្លើយតបនឹងការលើកឡើង ទូរគមនាគមន៍កម្ពុជា សូមទទួលយកការពិនិត្យឃើញ របស់អាជ្ញាធរសវនកម្មជាតិ។

### ៣.១.១១.ការកាន់កាប់កិច្ចបញ្ជិកាបេឡាចំពោះប្រាក់បេសកកម្មមិនទាន់ពេញលេញ

ប្រកាសលេខ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានបញ្ជាក់ថា "រជ្ជទេយ្យករ/រជ្ជទេយ្យកររង ត្រូវរក្សាទុកនូវសាច់ប្រាក់ដែលខ្លួនបានទទួលពីគណនេយ្យករសាធារណៈ ព្រមទាំងទុក ដាក់ថែរក្សាលិខិតយុត្តិការ កាន់កាប់បញ្ជីការបេឡាដោយឡែកសម្រាប់តាមដានចំណូល- ចំណាយ និងប្រាក់បេសកកម្មនៅសល់"។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាក្រោម ឱវាទរបស់ក្រសួងសុខាភិបាល រួមមាន៖ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក ដ្ឋានបច្ចេកទេស មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សាលា មធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង សាលាមធ្យមសិក្សាសុខាភិបាល ភូមិភាគស្ទឹង ត្រែង និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមមាន៖ អគ្គនាយកដ្ឋានបច្ចេកទេស និងអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ មិនបានរៀបចំបញ្ជីបេឡាសម្រាប់កត់ត្រាការចំណាយប្រាក់បេសកកម្មនោះ ឡើយ។

ដើម្បីធានាឱ្យការកាន់កាប់កិច្ចបញ្ជិកាប្រាក់បេសកកម្មបានត្រឹមត្រូវ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរធ្វើការណែនាំដល់មន្ត្រីហិរញ្ញវត្ថុនៃអង្គភាពថវិកាក្រោមឱវាទក្រសួងអនុវត្តការងារ **ឱ្យស្របតាម**ប្រកាសខាងលើ។

ក្រសួងសុខាភិបាល សូមទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងបន្តយកចិត្តទុកដាក់ក្នុងការរៀបចំបញ្ជីបេឡាសម្រាប់ការកត់ត្រានៃការចំណាយប្រាក់បេសកកម្មឱ្យបានត្រឹមត្រូវ។

ចំណែកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការបំភ្លឺថា ចំពោះបេសកកម្មដែលអង្គភាពមិនចុះបញ្ចូលក្នុងបញ្ជីបេឡាជាប្រចាំ គឺមូលហេតុដោយប្រាក់បេសកកម្មត្រូវបើកជូនសាមីខ្លួនផ្ទាល់តែម្តង ដោយមិនរក្សាទុកក្នុងបញ្ជីបេឡារបស់អង្គភាពថវិកា។ ករណីនេះ ក្រសួងនឹងអនុវត្តតាមការផ្តល់អនុសាសន៍របស់សវនកម្មចាប់ពីពេលនេះតទៅ។

អាជ្ញាធរសវនកម្មជាតិបានឃើញនូវការឆ្លើយបំភ្លឺរបស់ក្រសួងទាំងពីរខាងលើ និងបន្តតាមដានលើការអនុវត្តតាមអនុសាសន៍សវនកម្មបន្តទៀត។

### ៣.១.១២.ការយកសក្ខីបត្រឆ្នាំចាស់មកទូទាត់ក្នុងឆ្នាំថ្មី

ប្រកាសលេខ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ជំពូកទី៤ ផ្នែកទី២ ត្រង់ប្រការ២៦ កឋាខណ្ឌទី I កំណត់ថា "រាល់កិច្ចប្រជុំផ្សេងៗ ដែលបានអនុវត្តនៅក្នុងត្រីមាសទី៤នៃឆ្នាំមុនមិនទាន់ទូទាត់ ត្រូវបានអនុញ្ញាតឱ្យទូទាត់ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹមត្រីមាសទី១នៃឆ្នាំបន្ទាប់..."។ និង កឋាខណ្ឌទី II បានចែងថា "រាល់កិច្ចប្រជុំផ្សេងៗ ដែលបានអនុវត្តនៅក្នុងបីត្រីមាសដំបូងនៃឆ្នាំមុន និងបណ្តាឆ្នាំកន្លងទៅ មិនត្រូវបានអនុញ្ញាតឱ្យទូទាត់នៅឆ្នាំបន្ទាប់ឡើយ" និងប្រកាសលេខ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ប្រការ២៤ "រាល់ប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេស ដែលបានអនុវត្តនៅក្នុងត្រីមាសទី៤នៃឆ្នាំមុនមិនទាន់បានទូទាត់ ត្រូវបានអនុញ្ញាតឱ្យទូទាត់ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹមត្រីមាសទី១នៃឆ្នាំបន្ទាប់ ដោយអនុវត្តនីតិវិធីនៃការទូទាត់ត្រង់ និងប្រើប្រាស់ប្រាក់ឥណទានថវិកានៃឆ្នាំបន្ទាប់។ ហួសកំណត់នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមាននិត្យានុកូលភាពគ្រប់គ្រាន់ក្នុងការបដិសេធការទូទាត់ប្រាក់បេសកកម្ម លើកលែងតែមានការពន្យល់ច្បាស់លាស់ពីមូលហេតុនៃការយឺតយ៉ាវ។ រាល់ប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេស ដែលបានអនុវត្តនៅក្នុងបីត្រីមាសដំបូងនៃឆ្នាំមុន និងបណ្តាឆ្នាំកន្លងទៅ មិនត្រូវអនុញ្ញាតឱ្យទូទាត់នៅឆ្នាំបន្ទាប់ឡើយ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា៖

- អង្គភាពថវិកាទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលនៃក្រសួងសុខាភិបាល បានយកសក្ខីបត្រចំណាយប្រាក់បេសកកម្មនៅក្នុងខែកញ្ញា នៃឆ្នាំ២០២០ មកធ្វើការបោះផ្សាយអាណត្តិស្នើសុំទូទាត់នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

- អង្គភាពថវិកាតាមកម្មវិធីទី៣ និងទី៥របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តនីតិវិធីចំណាយ ដែលមានទឹកប្រាក់សរុបចំនួន **៨៧ ៧៦០ ០០០ រៀល** យកមកទូទាត់ ដោយប្រើប្រាស់ថវិកាឆ្នាំ២០២១ តាមរយៈការអនុវត្តចំណាយតាមនីតិវិធីទូទាត់ត្រង់ឆ្លងឆ្នាំទៅលើប្រតិបត្តិការចំនួន១១នៃការប្រជុំផ្សេងៗនៅក្នុងឆ្នាំ២០២០។

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងបរិស្ថាន បានយកឥណទានថវិកាឆ្នាំ២០២១ មកធ្វើការទូទាត់ប្រាក់បេសកកម្មនៅត្រីមាសទី១ ទី២ និងទី៣នៃឆ្នាំ២០២០ ដែលមានទឹកប្រាក់ចំនួន៦៨៧ ៣៤៣ ៤០០រៀល ។

អាស្រ័យហេតុនេះ ក្រសួងសុខាភិបាល គួរធ្វើការណែនាំដល់អង្គភាពថវិកាទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលអនុវត្តការចំណាយឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិខាងលើ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរអនុវត្តនីតិវិធីចំណាយលើការប្រជុំផ្សេងៗឱ្យស្របតាមប្រកាសខាងលើ ហើយក្រសួងបរិស្ថានគួរណែនាំដល់អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានទាំងបីខាងលើ ឱ្យធ្វើការកែលម្អចំពោះការទូទាត់ប្រាក់បេសកកម្មបានត្រឹមត្រូវ និងស្របតាមបទប្បញ្ញត្តិ។

ចំពោះចំណុចនេះ ក្រសួងសុខាភិបាលសូមទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងជំរុញឱ្យទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលយកចិត្តទុកដាក់ក្នុងការកត់ត្រាចំណាយឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានគតិយុត្តជាធរមាន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលយកនូវអនុសាសន៍ខាងលើ ខិតខំពង្រឹង និងណែនាំដល់អង្គភាពក្រោមឱវាទអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារប្រកាសខាងលើ។ ចំណែកក្រសួងបរិស្ថានបានឆ្លើយតបនូវការលើកឡើងខាងលើថា សម្រាប់ប្រាក់បេសកកម្មក្នុងប្រទេសក្នុងត្រីមាសទី១ ទី២ និងទី៣ ដែលពុំបានត្រឹមត្រូវតាមប្រកាស០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីនៃការចំណាយប្រាក់បេសកកម្មក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ប្រការ២៤នេះ ដោយសារការអនុវត្តបេសកកម្មបានរួចរាល់ហើយ ក្នុងឆ្នាំ២០២០ទើបទទួលបានប្រកាសកែសម្រួលថ្មីដែលធ្វើឱ្យមានបំណុលត្រូវស្នើសុំគោលការណ៍ធានាចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយសារគោលការណ៍ឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ទើបធ្វើការបោះផ្សាយអាណត្តិទូទាត់សម្រាប់បេសកកម្មក្នុងត្រីមាសទី១ ទី២ និងទី៣។ ម្យ៉ាងវិញទៀត ដោយសារតែប្រាក់បេសកកម្មក្នុងប្រទេសឆ្នាំ២០២០ ប្រមាណ៥០% ត្រូវបានទូទាត់បំណុលបេសកកម្មក្នុងប្រទេសឆ្នាំ២០១៩។ នៅក្នុងឆ្នាំ២០២០ ដោយស្ថានភាពកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់ក្របខណ្ឌច្បាប់ថវិកាឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០០៣ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយលើកទី២ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានធ្វើវិចារណកម្មកញ្ចប់ថវិកាតាមក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល។ ត្រង់ចំណុចទី១ កាត់សន្សំចំណាយបេសកកម្មក្នុងប្រទេស៥០% ចំពោះក្រសួង ស្ថាប័នទាំងអស់។ ក្នុងករណីទាំង២ ដែលបានជម្រាបជូនខាងលើនេះ ធ្វើឱ្យប្រាក់បេសកកម្មក្នុងប្រទេសឆ្នាំ២០២០ ពុំមានលទ្ធភាពទូទាត់សម្រាប់ត្រីមាសទី១ ទី២ និងទី៣ ឆ្នាំ២០២០បាន។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.១៣.ការពុំបានអនុវត្តពិន័យលើក្រុមហ៊ុនដែលប្រគល់ទំនិញយឺតយ៉ាវ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០០២ សហវ.អលសរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី១៩ បានចែងថា ការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារត្រូវប្រព្រឹត្តទៅតាមទីកន្លែង ពេលវេលា បរិមាណ ទំហំ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានចែងក្នុងកិច្ចសន្យា។ ការប្រគល់ទទួល ឬវាយតម្លៃលទ្ធផលការងារខ្សល (គ្មានទំនិញ សំណង់ ឬសេវា) ឬបរិមាណទំនិញ ទំហំការងារ ឬសេវាមិនគ្រប់ចំនួន ឬមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស គឺជាអំពើឃុបឃិតដែលត្រូវជៀសវាងឱ្យបានដាច់ខាត។

តាមការចុះធ្វើសវនកម្មនៅអង្គភាពលទ្ធកម្មនៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀបនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ការិយបរិច្ឆេទ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មរបស់វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប ពុំបានពិន័យលើក្រុមហ៊ុនដែលពុំបានគោរពទៅតាមពេលវេលាកំណត់៤៥ថ្ងៃ ដូចមានចែងក្នុងកិច្ចសន្យាលើការប្រគល់ទទួលទំនិញសម្ភារផ្គត់ផ្គង់ថែទាំដែលមានទឹកប្រាក់ចំនួន៨៧ ៧៥០ ០០០រៀល។

ដើម្បីឱ្យការអនុវត្តកិច្ចលទ្ធកម្មបានត្រឹមត្រូវ និងស្របតាមបទប្បញ្ញត្តិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរណែនាំដល់វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប ឱ្យធ្វើការកែលម្អឱ្យបានត្រឹមត្រូវតាមសារាចរណែនាំខាងលើ។

ឆ្លើយតបនូវការលើកឡើងខាងលើ តាមការបំភ្លឺរបស់វិទ្យាស្ថានជាតិកសិកម្មព្រែកលាបក្នុងរបាយការណ៍របស់អាជ្ញាធរសវនកម្មជាតិបានបញ្ជាក់ថា ការប្រគល់ ទទួលទំនិញសម្ភារផ្គត់ផ្គង់ថែទាំមិនស្របតាមពេលកំណត់បន្ទាប់ពីកិច្ចសន្យាចូលជាធរមាន។ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀបបានក្រើនរំលឹកដែរ ប៉ុន្តែការបញ្ជាទិញ និងការរៀបចំរបស់ក្រុមហ៊ុនជួបការលំបាកដោយសារជំងឺកូវីដ-១៩។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

**៣.១.១៤.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈមិនអនុលោមតាមគោលការណ៍លទ្ធកម្មសាធារណៈ**

អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ត្រង់មាត្រា១៣ បានបញ្ជាក់ថា "អង្គភាពលទ្ធកម្មបំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម ដោយមានភារកិច្ចជាសារវន្តដូចជា៖ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និង/ឬ

ផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់ រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗផ្អែកតាមគំរូឯកសារដេញថ្លៃដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ... រហូតដល់រៀបចំរបាយការណ៍ស្តីពីការអនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ...″ និងប្រកាសលេខ៥៨៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច និងការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា ត្រង់មាត្រា១៧ ចំណុចត្រទី២ បានកំណត់ថា ″ចំណាយតម្រូវឱ្យអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសាធារណៈ៖ ជាប្រភេទចំណាយតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈមុនបោះផ្សាយអាណត្តិទូទាត់។ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវរៀបចំដោយគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់ក្រសួងស្ថាប័នដោយត្រូវអនុលោមតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន″ ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គម្រោងលទ្ធកម្មក្នុងឆ្នាំ២០២១ ចំនួន០៣ នៃក្រសួងអប់រំ យុវជន និងកីឡា គឺ ១)គម្រោងលទ្ធកម្មលើការបោះពុម្ពសៀវភៅដែលមានទឹកប្រាក់ចំនួន ៣៦ ០០០ ០០០រៀល របស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ ២) គម្រោងលទ្ធកម្មលើការទិញប្រេងសាំង ម៉ាស៊ូត ចំណីសត្វ ពូជ និងកូនរុក្ខជាតិ ផលិតផលការពាររុក្ខជាតិ ជី ពូជសត្វ ឱសថ និងសម្ភារបសុពេទ្យ ដែលមានទឹកប្រាក់ចំនួន ៧៩ ៩៩០ ០០០រៀល របស់អង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ និង៣)គម្រោងលទ្ធកម្មចំណាយទិញស្បៀងអាហារ និងផលិតផលកសិកម្មដែលមានទឹកប្រាក់ចំនួន ៣៤ ៣៩០ ០០០រៀល របស់អង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាលនៅមិនទាន់អនុលោមតាមគោលការណ៍នៃកិច្ចលទ្ធកម្មសាធារណៈនៅឡើយ ដោយអង្គភាពថវិកាទាំង៣ខាងលើមិនមែនជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ និងមិនទាន់បានបង្កើតក្រុមលទ្ធកម្មដើម្បីអាចអនុវត្តកិច្ចលទ្ធកម្មជំនួសឱ្យអង្គភាពលទ្ធកម្មរបស់ក្រសួង ដែលជាអង្គភាពជំនាញ និងមានតួនាទីភារកិច្ចក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈទាំងអស់របស់ក្រសួង។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការពិនិត្យ និងណែនាំដល់អង្គភាពថវិកាទាំង៣ខាងលើឱ្យអនុវត្តការចំណាយតាមតួនាទីភារកិច្ចជាអង្គភាពថវិកាដែលមិនមែនជាអាណាប័កផ្ទេរសិទ្ធិ និងត្រឹមត្រូវតាមគោលការណ៍នៃចំណាយតាមកិច្ចលទ្ធកម្មសាធារណៈ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការបញ្ជាក់ ដូចខាងក្រោម៖

- នាយកដ្ឋានហិរញ្ញវត្ថុ សូមបញ្ជាក់ថា៖ ករណី ការបោះពុម្ពសៀវភៅដែលមានទឹកប្រាក់ចំនួន ៣៦ ០០០ ០០០រៀល ដោយសារជាតម្រូវការចាំបាច់ និងបន្ទាន់របស់ថ្នាក់ដឹកនាំ ទើបក្រសួងសុំអនុញ្ញាតគោលការណ៍ដោយឡែកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីអនុវត្តសកម្មភាព។ នាយកដ្ឋានហិរញ្ញវត្ថុនឹងពិនិត្យមើលកែសម្រួលឡើងវិញ។

- វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ សូមបញ្ជាក់ថា៖ វិទ្យាស្ថានបានស្នើសុំជាគោលការណ៍នីតិវិធីធានាចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់អនុគណនី៦០០១៥,

៦០០៣២, ៦០០៣៣, ៦០០៣៥, ៦០០៣៦, ៦១០៥១, ៦១០៥២និង៦១០៥៣ មានទឹកប្រាក់សរុបចំនួន៧៩ ៩៩០ ០០០រៀល (ចិតសិបប្រាំបួនលាន ប្រាំបួនរយកៅសិបពាន់រៀលគត់) សម្រាប់ទិញសម្ភារក្នុងកិច្ចដំណើរការរដ្ឋបាលបង្រៀន រៀន និងការជួសជុលជាប្រចាំ និងបន្តនិរន្តរភាពអង្គភាព។ ប៉ុន្តែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុញ្ញាតឱ្យវិទ្យាស្ថានបច្ចេកទេសកំពង់ស្ពឺអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។ ដោយសារវិទ្យាស្ថានមិនមែនជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ ហើយក៏មិនបានគ្រោងទុកក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំដែរ វិទ្យាស្ថានបានស្នើសុំយោបល់ទៅអង្គភាពជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា និងបានអនុវត្តកិច្ចលទ្ធកម្មនេះតាមរយៈនីតិវិធីស្ទង់តម្លៃជាមួយក្រុមហ៊ុនចំនួន៣។

- វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល សូមបញ្ជាក់ថា៖ វិទ្យាស្ថានបានស្នើសុំជាគោលការណ៍នីតិវិធីធានាចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់អនុគណនី ៦០០៣២, ៦០០៣៣, ៦០០៣៤, ៦០០៣៥, ៦០០៣៦, និង៦០០៣៧ មានទឹកប្រាក់សរុប ៤០ ០០០ ០០០រៀល (សែសិបលានរៀលគត់) សម្រាប់ទិញសម្ភារ និងស្បៀងកសិកម្មក្នុងកិច្ចដំណើរការបង្រៀន និងរៀនផ្នែកក្សេត្រសាស្ត្រ និងបសុវប្បកម្ម ព្រមទាំងទិញស្បៀងរដ្ឋបាលសម្រាប់កិច្ចដំណើរការអង្គភាព។ ជាលទ្ធផល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុញ្ញាតឱ្យវិទ្យាស្ថានបច្ចេកទេសកំពង់ឈើទាលអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។ ដោយសារវិទ្យាស្ថានមិនមែនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ហើយក៏មិនបានគ្រោងទុកក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំពីព្រោះទំហំថវិកាមានចំនួនតិច និងច្រើនអនុគណនីរួមគ្នា ដែលអនុគណនីនីមួយៗ មានឥណទានថវិកាតិចតួចពិបាកក្នុងការធ្វើកិច្ចលទ្ធកម្មសាធារណៈ។ ម្យ៉ាងទៀត កិច្ចដំណើរការលទ្ធកម្មសាធារណៈត្រូវប្រើនីតិវិធីច្រើនដំណាក់កាល និងប្រើពេលវេលាយូរ មិនទាន់តាមពេលវេលាដែលវិទ្យាស្ថានត្រូវការចំណីសត្វ ថ្នាំព្យាបាលសត្វ សម្ភារផ្នែកកសិកម្មផ្សេងៗ សម្រាប់ប្រើក្នុងកសិដ្ឋានរបស់ខ្លួន។ បន្ទាប់ពីទទួលបានលិខិតធានាចំណាយ ហើយអ្នកត្រូវទទួលអនុវត្តកិច្ចលទ្ធកម្មនេះ គឺអង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ប៉ុន្តែដោយសារអង្គភាពលទ្ធកម្មមានការងារមមាញឹកច្រើន ចំណែកថវិកាធានាចំណាយកិច្ចលទ្ធកម្ម ក៏មានចំនួនតិចពិបាកស្វែងរកក្រុមហ៊ុនចូលរួមដេញថ្លៃ ទើបអង្គភាពលទ្ធកម្មបានពិភាក្សាជាមួយនាយកដ្ឋានហិរញ្ញវត្ថុ និងភាគីវិទ្យាស្ថាន ដើម្បីស្វែងរកនីតិវិធីដំណើរការកិច្ចលទ្ធកម្មនេះឱ្យទទួលបានជោគជ័យ និងទាន់ពេលវេលានៃការប្រើប្រាស់។ ជាចុងក្រោយ អង្គភាពលទ្ធកម្មដោយមានការយល់ព្រមពីនាយកដ្ឋានហិរញ្ញវត្ថុបានសម្រេចធ្វើលិខិតបញ្ជូនប្រគល់សិទ្ធិជូនវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ជាអ្នកដំណើរការអនុវត្តកិច្ចលទ្ធកម្ម ដោយប្រើនីតិវិធីស្ទង់តម្លៃជាមួយក្រុមហ៊ុន ឬហាងផ្គត់ផ្គង់ចំនួន៣ដើម្បីស្វែងរកក្រុមហ៊ុន ឬហាងណាដែលមានតម្លៃទាបជាងគេធ្វើការផ្គត់ផ្គង់ចំនួន០៣ ដើម្បីស្វែងរកក្រុមហ៊ុន ឬហាងណាដែលមានតម្លៃទាបជាងគេសម្រាប់ធ្វើការផ្គត់ផ្គង់ ស្របតាមនីតិវិធីលទ្ធកម្មដែលមានទឹកប្រាក់មិនលើសពី៥០លានរៀល ហើយក្រៅពីនេះ រាល់ឯកសារដែលពាក់ព័ន្ធនឹងរបាយការណ៍នៃកិច្ចដំណើរការកិច្ចលទ្ធកម្មនេះ បានស្នើសុំការឯកភាពពីប្រធាន

កម្មវិធីទី២ និងអង្គភាពពាក់ព័ន្ធជានិច្ច។ អាស្រ័យដូចជម្រាបជូនខាងលើ វិទ្យាស្ថានបានដំណើរការកិច្ចលទ្ធកម្មបែបស្ទង់តម្លៃ ទោះបីជាវិទ្យាស្ថាននៅមិនទាន់ក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងមិនមានក្រុមលទ្ធកម្មប្រចាំវិទ្យាស្ថានក៏ដោយ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងអប់រំ យុវជន និងកីឡានឹងធ្វើការណែនាំដល់ អង្គភាពថវិកាក្រោមឱវាទរបស់ខ្លួនឱ្យធ្វើការអនុវត្តនីតិវិធីចំណាយថវិការដ្ឋឱ្យបានត្រឹមត្រូវ និងស្របតាមគោលការណ៍ណែនាំនៃការអនុវត្តចំណាយថវិកាចរន្ត។

**៣.១.១៥.ការអនុវត្តគម្រោងលទ្ធកម្មដែលមិនបានកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ**

ប្រកាសលេខ៨៥១សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ត្រង់ប្រការ១៧ បានចែងថា មូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ត្រូវមានលក្ខណៈច្បាស់លាស់ គ្រប់ជ្រុងជ្រោយ មានការទទួលខុសខុសត្រូវ និងអាចជឿទុកចិត្តបាន... តម្រូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្ត ឬអង្គភាពថវិកា" និងប្រការ៣៣ បានចែងថា "រាល់គម្រោងចំណាយ ដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយ ដែលមិនបានកត់ត្រាក្នុងផែនការលទ្ធកម្ម មិនអនុញ្ញាតឱ្យសុំ ឬផ្តល់ធានាចំណាយឡើយ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាៈ

- និយ័តករទូរគមនាគមន៍កម្ពុជា បានទូទាត់ចំណាយលើទិញផ្ទាល់ ឬចុះកិច្ចសន្យាផ្ទាល់ចំពោះរថយន្ត ម៉ូតូ សម្ភារបច្ចេកទេស សង្ហារឹម សេវាផ្នែកច្បាប់ និងការជួសជុល សរុបចំនួន ៧ ៦៣៩ ៣៥៧ ៦៤៥រៀលដោយពុំបានគ្រោងក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២១។
- អង្គភាពលទ្ធកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តគម្រោងលទ្ធកម្មចំនួន០៤ គឺ១.លទ្ធកម្មទិញចំណីសត្វ ពូជ និងរុក្ខជាតិ ផលិត ផល ការពារកូនរុក្ខជាតិ និងជីពូជសត្វ ឱសថ សម្ភារបសុពេទ្យ និងស្បៀងរដ្ឋបាលរបស់អង្គភាពថវិកាវិទ្យាស្ថានកំពង់ឈើទាល ២.លទ្ធកម្មទិញប្រេងសាំង ប្រេងម៉ាស៊ូត ចំណីសត្វ ពូជ និងកូនរុក្ខជាតិ ផលិតផលការពាររុក្ខជាតិ និងជី ពូជសត្វ ឱសថ និងសម្ភាបសុពេទ្យ និងសេវាកម្មរបស់អង្គភាពថវិកាវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ៣.បោះពុម្ពសៀវភៅចំនួន៤០០០ក្បាលរបស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ ៤.គម្រោងលទ្ធកម្មកែសម្រួលខ្លឹមសារ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធតេស្ត និងពង្រឹងសមត្ថភាពសិស្សថ្នាក់ទី១២(LMS) របស់អង្គភាពថវិកានាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានដោយពុំមានបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ឬផែនការលទ្ធកម្មកែតម្រូវ។

និយ័តករទូរគមនាគមន៍កម្ពុជា គួរបញ្ចូលតម្រូវការចំណាយទៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ និងក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើណែនាំដល់អង្គភាពលទ្ធកម្មឱ្យធ្វើការបញ្ចូលគម្រោងទាំងអស់ទៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ និយ័តករទូរគមនាគមន៍កម្ពុជា បានទទួលយកនូវការពិនិត្យឃើញរបស់អាជ្ញាធរសវនកម្មជាតិ។ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការបញ្ជាក់ថា ព្រោះតែអង្គភាពថវិកាបានអនុវត្តកិច្ចលទ្ធកម្មដោយផ្ទាល់ ជំនួស

អង្គភាពលទ្ធកម្ម និងគណៈកម្មាធិការលទ្ធកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមិនបានមកស្នើសុំឆ្លងអង្គភាពលទ្ធកម្មរបស់ក្រសួង។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការណែនាំដល់អង្គភាពថវិកា និងអង្គភាពលទ្ធកម្មរបស់ក្រសួងឱ្យធ្វើការបញ្ចូលគម្រោងលទ្ធកម្មទាំងអស់ចូលទៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យបានត្រឹមត្រូវមុននឹងធ្វើការអនុវត្តគម្រោងលទ្ធកម្ម។

**៣.១.១៦.ការអនុវត្តកិច្ចលទ្ធកម្មសំណង់មិនទាន់សមស្របទៅនឹងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យា**

សារាចរណែនាំលេខ០០២ សហវ.អលសរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុច១៩ បានកំណត់ថា "ការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារ ត្រូវប្រព្រឹត្តទៅតាមទីកន្លែង ពេលវេលា បរិមាណ ទំហំ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានកំណត់ក្នុងកិច្ចសន្យា..."។ លទ្ធផលនៃការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារ ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវនៅក្នុងកំណត់ហេតុប្រគល់ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងារ ហើយត្រូវមានការចុះហត្ថលេខាទទួលខុសត្រូវពីគ្រប់សមាជិកគណៈកម្មការប្រគល់ទទួល និងអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ...។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកានាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការជួសជុល និងបំពាក់នូវសម្ភារមួយចំនួននៅទីតាំងអគារមជ្ឈមណ្ឌលយុវជន ខេត្តកណ្តាល១ខ្នង កម្ពស់៣ជាន់បានអនុវត្តរួចរាល់ មានគុណភាពល្អ អាចទទួលយកបាន ប៉ុន្តែនៅមានចំណុចមួយដែលមានការកែប្រែ និងផ្លាស់ប្តូរមិនទាន់សមស្របទៅនឹងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យានៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំដល់អង្គភាពថវិកានាយកដ្ឋានសំណង់ឱ្យការអនុវត្តការជួសជុល កែប្រែ ផ្លាស់ប្តូរទីតាំង និងបំពាក់សម្ភារលើសំណង់ដែលបានជួសជុលឱ្យបាននត្រឹមត្រូវ និងស្របតាមតារាងឧបសម្ព័ន្ធលម្អិតលក្ខណៈបច្ចេកទេសនៃកិច្ចសន្យា។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការបញ្ជាក់ថា នាយកដ្ឋានសំណង់ធ្វើការផ្លាស់ប្តូរទីតាំងសម្ភារបំពាក់ជាការស្នើសុំរបស់អ្នកប្រើប្រាស់ ដើម្បីធានាបាននូវសុវត្ថិភាព និងភាពងាយស្រួលក្នុងការប្រើប្រាស់ស្របតាមស្ថានភាពជាក់ស្តែងនៃអគារទ្រុឌទ្រោម ដែលលេចឡើងក្នុងកំឡុងពេលជួសជុល។ អង្គភាពថវិកានាយកដ្ឋានសំណង់ពិតជាពុំទាន់បានកែសម្រួលតារាងឧបសម្ព័ន្ធឱ្យស្របទៅតាមស្ថានភាពជាក់ស្តែងរបស់អង្គភាពប្រើប្រាស់បានស្នើសុំ។ ម៉្យាងទៀត ដោយពេលវេលាខ្លី ការអនុវត្តគម្រោងចុងឆ្នាំ និងការស្នើសុំរបស់អង្គភាពប្រើប្រាស់មានតម្លៃលើសពីតារាងឧបសម្ព័ន្ធក៏នាយកដ្ឋានសំណង់បានឯកភាពធ្វើជូនតាមសំណើអង្គភាពប្រើប្រាស់ដោយផ្ទាល់។ ក្នុងនេះនាយកដ្ឋានសំណង់បានធ្វើការងារបន្ថែមជាច្រើនលើបញ្ហាជាច្រើនទៀត ទោះបីជាគ្មានក្នុង

តារាងឧបសម្ព័ន្ធក៏ដោយ គឺធ្វើក្នុងគោលបំណងធានាឱ្យបាននូវសុវត្ថិភាព ដោយមិនមានការកិបកេងបន្លំ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការណែនាំដល់អង្គភាពថវិកានាយកដ្ឋានសំណង់ឱ្យធ្វើការអនុវត្តលើការជួសជុល និងបំពាក់សម្ភារលើសំណង់ដែលបានជួសជុល ឱ្យបានត្រឹមត្រូវទៅតាមតារាងឧបសម្ព័ន្ធនៃកិច្ចសន្យា។

### ៣.១.១៧.ការជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃ និងក្រុមហ៊ុនទទួលការពុំស្របនឹងកម្មវត្ថុដែលត្រូវដេញថ្លៃ

ប្រកាសលេខ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៨ បានកំណត់ថា "ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះ"។

តាមការធ្វើតេស្តសំណុំឯកសារគម្រោងលទ្ធកម្មចំនួន០៦នៃគម្រោងសរុបចំនួន៥៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនចូលរួមដេញថ្លៃចំនួន៣ (១.ក្រុមហ៊ុនសូផល ហូលឌីង ខូអិលធីឌី ២. ក្រុមហ៊ុនសង្វាពេជ្រ ខូអិលធីឌី និង៣. ក្រុមហ៊ុនសំណង់ បុរីកម្មករ ខូអិលធីឌី) ហើយក្រុមហ៊ុនទទួលការបានប្រើប្រាស់ប័ណ្ណប៉ាតង់ ពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ ដែលទឹកប្រាក់សរុបនៃគម្រោង មានចំនួន ២ ២៨២ ៦២១ ០០០រៀល។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសខាងលើ។

ចំពោះចំណុចខាងលើ ក្រសួងបានទទួលយកនូវអនុសាសន៍ខាងលើ ខិតខំពង្រឹង និងណែនាំដល់អង្គភាពក្រោមឱវាទអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារប្រកាសខាងលើ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១៨.ការចំណាយមុនគោលការណ៍យល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសលេខ៥៨០ សហវ.ប្រក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅគោលការណ៍ណែនាំនីតិវិធីចំណាយថវិកា និងបែបបទត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់ថវិកាចរន្តថ្នាក់ជាតិត្រង់ចំណុច៤.២ បានកំណត់ថា "ថវិកាបុរេប្រទានគឺជាការបើកផ្តល់ថវិកាមួយចំនួនសម្រាប់ចំណាយដំណើរការចាំបាច់ និងបន្ទាន់ដែលអង្គភាពមិនអាចរកសក្ខីបត្រមកស្នើសុំធានាចំណាយជាមុនបាន..." និងសារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ ស្តីពីការកែលម្អនីតិវិធីអនុវត្តថវិកា ត្រង់ចំណុច០៦បានចែងថា "កិច្ច

ជម្រះបញ្ជីនេះត្រូវធ្វើឡើងក្រោយចំណាយទាំងឡាយរបស់រដ្ឋត្រូវបានបញ្ចប់ព្រមជាមួយនឹងការបញ្ជាក់ពីភាពត្រឹមត្រូវលើគ្រប់សក្ខីបត្រ...”។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រសួង២ បានអនុវត្តចំណាយមុនគោលការណ៍សម្រេចយល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានបង្ហាញខាងក្រោម៖

**១. ក្រសួងអប់រំ យុវជន និងកីឡា (អង្គភាពថវិកានាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងអង្គភាពថវិកានាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន)**

- ចំណាយរៀបចំទិវាអក្ខរកម្មជាតិ៨កញ្ញា ផ្តល់បុរេប្រទាននៅថ្ងៃទី១០/៩/២០២១ ទឹកប្រាក់ចំនួន៤៣ ៧០០ ០០០រៀល ចំណាយនៅថ្ងៃទី៣/៩/២០២១

- ចំណាយរៀបចំមហោស្រពពិព័ណ៌វិទ្យាសាស្ត្រកម្ពុជា ផ្តល់បុរេប្រទាននៅថ្ងៃទី៣០/០៣/២០២១ ទឹកប្រាក់ចំនួន១៩ ០០០ ០០០រៀល ចំណាយថ្ងៃទី១៤/១/២០២១

**២. ក្រសួងព័ត៌មាន**

- ចំណាយជាវសារព័ត៌មានAPប្រចាំឆ្នាំ២០២១ បុរេប្រទាននៅថ្ងៃទី១៩/៥/២០២១ ទឹកប្រាក់ចំនួន១១២ ៤៨០ ២០០រៀល ចំណាយថ្ងៃទី១/១/២០២១

- ចំណាយឧបត្ថម្ភនិងសំណេះសំណាលជាមួយមន្ត្រីនារីក្រសួងព័ត៌មាន ផ្តល់បុរេប្រទានថ្ងៃទី៣/៣/២០២១ ទឹកប្រាក់ចំនួន៣៩ ៣២០ ០០០រៀល ចំណាយនៅថ្ងៃទី១៨/២/២០២១

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងព័ត៌មាន គួរធ្វើការចំណាយថវិកាខាងលើឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីនៃការចំណាយ ស្របតាមប្រកាស និងសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការបញ្ជាក់ថា មូលហេតុដែលនាំឱ្យមានចំណុចខ្វះខាតនេះ ដោយសារកម្មវិធីមហោស្រពពិព័ណ៌វិទ្យាស្ថានកម្ពុជាឆ្នាំ២០២១ ចាប់ផ្តើមនៅដើមឆ្នាំ គឺពីថ្ងៃទី២៥ ដល់២៩ ខែមករាឆ្នាំ២០២១ និងដំណើរការឯកសារមានភាពយឺតយ៉ាវ មិនទាន់បានទទួលគោលការណ៍យល់ព្រមផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ដល់ថ្ងៃរៀបចំកម្មវិធី នាយកដ្ឋានបានចាប់ផ្តើមដំណើរការឯកសារ ដើម្បីរៀបចំកម្មវិធីនេះតាំងចុងឆ្នាំ២០២០មកដែរ ប៉ុន្តែនៅតែពុំទាន់ពេលវេលា។ ដូចនេះនាយដ្ឋានត្រូវអនុវត្តសកម្មភាព ដើម្បីសម្រេចនូវសូចនាករដែលបានគ្រោងក្នុងផែនការថវិកាប្រចាំឆ្នាំដែលនាំឱ្យការអនុវត្តចំណាយមិនបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

បន្ថែមពីនេះ ក្រសួងព័ត៌មាន សូមធ្វើការឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងព័ត៌មានសូមធ្វើការបញ្ជាក់ថា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុបានបំភ្លឺថាការចំណាយឧបត្ថម្ភសំណេះសំណាលជាមួយមន្ត្រីនារីក្រសួងព័ត៌មានក្នុងឱកាសទិវានារីអន្តរជាតិ៨មីនា ឆ្នាំ២០២១ បានអនុវត្តចំណាយថវិកាខាងលើមុនគោលការណ៍សម្រេចយល់

ព្រមធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះ ក្រសួងតម្រូវការចាំបាច់ក្នុងការចំណាយឱ្យបានទាន់ពេលវេលា មុននឹងទទួលគោលការណ៍ចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងព័ត៌មាន គួរធ្វើការណែនាំដល់អង្គភាពក្រោមឱវាទឱ្យធ្វើការចំណាយថវិកាបុរេប្រទានឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីនៃការចំណាយថវិកាបុរេប្រទាន។

**៣.១.១៩.ការចំណាយ និងការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ**

ប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ឧបសម្ព័ន្ធទី២ បានកំណត់ដូចខាងក្រោម៖

-អនុគណនី៦០០១២ បានកំណត់សម្រាប់ការចំណាយលើការទិញសម្ភារសម្រាប់ថែទាំ និងជួសជុលអគារ សួនច្បារ របង ចំណតរថយន្ត បន្ទប់ទឹក ឃ្លាំង ប្រាសាទ អាកាសយានដ្ឋាន កំពង់ផែ។ល។

-អនុគណនី ៦០០១១ ចំណាយលើការទិញសម្ភារសម្រាប់សម្អាត និងអនាម័យ

-អនុគណនី៦០០២១ បានកំណត់ពីការចំណាយទិញសម្ភារការិយាល័យ និងសម្ភារប្រឡង

-អនុគណនី ៦០០៥១ បានកំណត់ពីការចំណាយ ការទិញសម្ភារ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា

-អនុគណនី៦០០៥៣ បានកំណត់ចំពោះចំណាយទិញសម្ភារប្រើប្រាស់ ដូចជា៖ សម្ភារកីឡាគ្រប់ប្រភេទ ថ្មពិលគ្រប់ប្រភេទ ហ្វីលថត (អង្គចងចាំ) កាសែតថតសំលេង កាសែតវីដេអូ ញញួរ សោរចាក់ ម៉ាស៊ីនចោះ ឬខួង ម៉ាស៊ីនខាត់ ចប តង់កៅស៊ូ រណា រាំងនន។ល។

-អនុគណនី៦០០៥៤ សម្រាប់កត់ត្រាចំណាយលើការទិញសម្ភារ និងឧបករណ៍ដឹកជញ្ជូនដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយមូលធនដូចជា៖ រទេះដឹក រថយន្ត ម៉ូតូ កង់។ល។

-អនុគណនី ៦០០៥៥ ចំណាយការទិញសម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា

-អនុគណនី៦១០៥២ ចំណាយលើការថែទាំជួសជុលអគារផ្សេងៗ និងប្រាសាទដែលមានដូចជា ជួសជុលរបងអគារ ចំណតរថយន្ត បន្ទប់ទឹកឃ្លាំង អាកាសយានដ្ឋាន កំពង់ផែ ទីផ្សារ សតឃាតដ្ឋាន(សួនច្បារនិងទីធ្លា) ដែលមានការផ្គត់ផ្គង់លើសេវាខាងក្រៅ ព្រមទាំងចំណាយ លើការងារលាបថ្នាំ ការរៀបចំបណ្តាញឡើងវិញ ដែលបណ្តាលមកពីការជួសជុលអគារ លើកលែងតែចំណាយទូទាត់ថ្លៃទិញឧបករណ៍បំពាក់បន្ថែម ដែលត្រូវកត់ត្រាក្នុងជំពូក ៦០ (ការទិញ)។

-អនុគណនីលេខ ៦១០៥៣ ចំណាយលើការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ។

-អនុគណនី៦៤០៣៣ ចំណាយលើការផ្តល់រង្វាន់ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុជូនមន្ត្រីរាជការ។

-អនុគណនី៦៤០៣៨ ចំណាយផ្សេងៗក្រៅពីអនុគណនីខាងលើ ដូចជា៖ចំណាយឧបត្ថម្ភអ្នកនិពន្ធ អ្នកបកប្រែ អ្នកផ្ទៀងផ្ទាត់ អ្នករៀបចំចងក្រងឯកសារ អ្នកសរសេរសញ្ញាបត្រ អ្នកវាយកុំព្យូទ័រ អ្នកគូរូប។ល។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាក្រសួងមួយចំនួនដូចជាក្រសួងព័ត៌មាន ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអនុវត្តចំណាយ និងកត់ត្រាចំណាយមួយចំនួនមិនត្រឹមត្រូវស្របតាមខ្លឹមសារនៃប្រកាសខាងលើស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋនៅឡើយ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងព័ត៌មានបានចំណាយ និងកត់ត្រាចំណាយលើប្រាក់កម្រៃឧបត្ថម្ភស្នាដៃនិពន្ធ និងបកប្រែភាសាពីខែមករា ដល់ខែមេសាឆ្នាំ២០២១ ក្នុងទឹកប្រាក់ចំនួន ៩២ ៨៩៩ ០០០រៀល មិនទាន់បានត្រឹមត្រូវក្នុងអនុគណនីលេខ៦៤០៣៣ ដោយក្រសួងគួរកត់ត្រាចំណាយខាងលើក្នុងអនុគណនីលេខ ៦៤០៣៨ និងអង្គភាពថវិកាមួយចំនួនក្រោមឱវាទក្រសួងសុខាភិបាល ដូចជា៖ មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល និងវិទ្យាស្ថានជាតិសុខភាពសាធារណៈក៏បានកត់ត្រាការចំណាយលើការជួសជុលម៉ាស៊ីនភ្លើង ម៉ាស៊ីនត្រជាក់ និងបោះពុម្ពខ្លឹមសារសុខភាពសាធារណៈលើកាបូបស្ពាយខ្នង និងអាវយឺត ពុំទាន់ត្រឹមត្រូវស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៅឡើយផងដែរ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានកត់ត្រាពុំទាន់បានត្រឹមត្រូវចំពោះចំណាយលើការផ្គត់ផ្គង់ភេសជ្ជៈប្រើប្រាស់ប្រចាំឆ្នាំ២០២១ សរុបជាទឹកប្រាក់ចំនួន ៨៥១ ០៦៦ ០០០រៀល ដែលក្នុងនោះរួមមានចំណាយលើការទិញ Flash Drive និងHard Disk External ចំនួន២៧ ៤០០ ០០០រៀល បានកត់ត្រាក្នុងអនុគណនីលេខ៦០០២១ ប៉ុន្តែចំណាយនេះក្រសួងគួរកត់ត្រាក្នុងអនុគណនីលេខ៦០០៥៣ ចំណែកចំណាយទិញម៉ាស និងស្រោមដៃចំនួន ១១៨ ០៩៦ ០០០រៀល ក្នុងអនុគណនី៦០០៥៣ ក្រសួងគួរតែកត់ត្រាក្នុងអនុគណនីលេខ ៦០០១១ វិញ និងចំណាយលើប្រព័ន្ធកាមេរ៉ាសុវត្ថិភាព ប្រព័ន្ធទូរស័ព្ទ អ៊ីនធ័រណែត និងខ្សែកាប (បំពាក់ថ្មី) សម្រាប់វិទ្យាស្ថានការងារ និងអគារបណ្តុះបណ្តាលបច្ចេកទេស និងស្រាវជ្រាវបច្ចេកវិទ្យាផ្នែកអភិវឌ្ឍន៍ឧស្សាហកម្មចំនួន ៧០៥ ៥៧០ ០០០រៀល បានកត់ត្រាមិនត្រឹមត្រូវក្នុងអនុគណនីលេខ៦១០៥២។ ក្រសួងគួរកត់ត្រាចំណាយនេះក្នុងអនុគណនីលេខ៦០០៥៥។ ចំណែកឯក្រសួងសាធារណការ និងដឹកជញ្ជូន ក៏បានកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវក្នុងអនុគណនីលេខ ៦១០៥៣ សរុបជាទឹកប្រាក់ចំនួន ១៩៩ ៩០០ ០០០រៀល រួមមានចំណាយលើការទិញឧបករណ៍ពិសោធន៍ប្រភេទHMP LFG Pro Light Weight Deflectometer ចំនួន២គ្រឿង ក្នុងតម្លៃ ១៦១ ៩០០ ០០០រៀល ដើម្បីវាស់កម្រិតសម្រុត និងម៉ូឌុលអេឡា

ស្និករបស់ផ្លូវថ្នល់ ដែលក្រសួងគួរកត់ត្រាក្នុងអនុគណនីលេខ៦០០៥១ និងការចំណាយទិញម៉ាស៊ីន Drone សម្រាប់ថតសណ្ឋានដីពីលើអាកាសក្នុងតម្លៃ ៣៨ ០០០ ០០០រៀល (៩ ៥០០ ដុល្លារអាមេរិក) ដែលត្រូវកត់ត្រាក្នុងអនុគណនីលេខ៦០០៥៥ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈចំនួន១គម្រោង ក្នុងទឹកប្រាក់សរុបចំនួន ១១ ៩១៨ ០០០រៀល ដែលកត់ត្រាមិនត្រឹមត្រូវក្នុងអនុគណនីលេខ៦០០៥៣ ដែលក្នុងនោះមានចំណាយលើការទិញកន្ត្រៃសម្រាប់កាត់ស្មៅ មែកឈើ និងគ្រឿងបន្លាស់បន្ទប់ទឹកចំនួន ៨ ៧២២ ០០០រៀល ក្រសួងគួរកត់ត្រាក្នុងអនុគណនីលេខ៦០០១២ និងចំណាយទិញរទេះដឹកសម្ភារកង់បួនទឹកប្រាក់ចំនួន៣ ១៩៦ ០០០រៀល គួរត្រូវបានកត់ត្រាក្នុងអនុគណនី ៦០០៥៤ ស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងមាតិកាថវិកា។

អាស្រ័យហេតុនេះ ដើម្បីធានាឱ្យការចំណាយ និងកត់ត្រាចំណាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រសួង ឆ្លុះបញ្ចាំងពីភាពត្រឹមត្រូវនៃគោលការណ៍គណនេយ្យរបស់រដ្ឋាភិបាល ក្រសួងខាងលើ គួរធ្វើការណែនាំដល់មន្ត្រីហិរញ្ញវត្ថុនៃអង្គភាពថវិការបស់ខ្លួនឱ្យអនុវត្តការចំណាយ និងការកត់ត្រាឱ្យមានប្រសិទ្ធភាពស្របតាមខ្លឹមសារប្រកាសដែលមានចែងខាងលើឱ្យបានខ្ជាប់ខ្ជួន។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសាមីទាំងអស់ខាងលើ បានឯកភាពទទួលយកចំពោះការរកឃើញខាងលើ និងខិតខំកែលម្អចំណុចខ្វះខាតទាំងនោះតាមអនុសាសន៍សវនកម្មនៅឆ្នាំបន្ទាប់ទៀត។

អាជ្ញាធរសវនកម្មជាតិបានឃើញនូវការឆ្លើយបំភ្លឺរបស់សាមីក្រសួងនឹងបន្តតាមដាននូវវឌ្ឍនភាព។

**៣.១.២០.ភាពខ្វះចន្លោះក្នុងការរៀបចំរបាយការណ៍តាមដានការអនុវត្តចំណាយថវិការដ្ឋប្រចាំឆ្នាំ**

ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា ត្រង់ប្រការ២៧ បានកំណត់ថា "អង្គភាពថវិកានៃក្រសួង ស្ថាប័ន មានកាតព្វកិច្ចរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា ក្នុងនោះរបាយការណ៍ចំណូល-ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្មស្របតាមគោលការណ៍ និងទម្រង់ដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី និងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ" ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅមានភាពខ្វះចន្លោះក្នុងការរៀបចំរបាយការណ៍អនុវត្តថវិកា(របាយការណ៍ចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២១) និងរបាយការណ៍តារាងសម្រង់អាណត្តិបើកប្រាក់ចំណាយរួមប្រចាំឆ្នាំ២០២១ របស់អង្គភាពថវិកាអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការស្របទៅតាមគោលការណ៍ និងខ្លឹមសារនៃប្រកាសខាងលើនៅឡើយ។

កត្តានេះ អាចនាំឱ្យការគ្រប់គ្រង និងការតាមដានការអនុវត្តចំណាយថវិការដ្ឋប្រចាំឆ្នាំរបស់អង្គភាពថវិកាអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការមិនទាន់មានភាពច្បាស់លាស់ និងត្រឹមត្រូវស្របតាមគោលការណ៍ណែនាំនៃការអនុវត្តថវិការបស់អង្គភាពថវិកា។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើការណែនាំអង្គភាពថវិកាអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការឱ្យធ្វើការរៀបចំបូកសរុបរបាយការណ៍ស្តីពីការអនុវត្តថវិកាចំណាយប្រចាំឆ្នាំរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការបញ្ជាក់ថា អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការសូមឯកភាពលើរបាយការណ៍សវនកម្មដែលអាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញនូវចំណុចខ្វះខាត ដោយអង្គភាពថវិកាអគ្គគោលនយោបាយ និងផែនការពុំបានបូកសរុបរបាយការណ៍រួមទាំង៤នាយកដ្ឋានបញ្ចូលគ្នាប្រចាំឆ្នាំ២០២១។ បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការបានធ្វើការកែតម្រូវតាមការណែនាំរបស់អាជ្ញាធរសវនកម្មជាតិ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការណែនាំអង្គភាពថវិកាអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការឱ្យធ្វើការរៀបចំបូកសរុបរបាយការណ៍អនុវត្តចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

### ៣.១.២១.កង្វះខាតក្នុងការរៀបចំរបាយការណ៍អនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្មរបស់អង្គភាពថវិកា

ប្រកាសលេខ៥៤៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា ត្រង់ជំពូក**៣** ប្រការ**១១** ចំណុចទី**៣** ត្រេទី**២**បានកំណត់ថា "អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញមានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖ រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា (របាយការណ៍ចំណូល-ចំណាយ និងរបាយការណ៍សមិទ្ធកម្ម) ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ/ក្រុមការងារថវិកាក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន និងផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នតាមកាលបរិច្ឆេទដែលបានកំណត់"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាចំនួន៤ នៃក្រសួងព័ត៌មានមិនទាន់បានរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន ដើម្បីផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួងឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មានគួរធ្វើការណែនាំដល់អង្គភាពថវិកាទាំង៤ខាងលើឱ្យធ្វើការរៀបចំរបាយការណ៍អនុវត្តថវិកាប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មរបស់ខ្លួនឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងព័ត៌មានសូមធ្វើការបញ្ជាក់ថា យោងរបាយការណ៍របស់អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា និងអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៅមិនទាន់បានរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ។ អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជានឹងសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងរៀបចំរបាយការណ៍ខាងលើសម្រាប់ឆ្នាំ២០២២ និងបណ្តាឆ្នាំខាងមុខទៀត។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

**៣.១.២២.ការអនុវត្តថវិកាកម្មវិធីពុំទាន់បានពេញលេញ**

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុច III.២ កថាខណ្ឌទី២ បានចែងថា "ដើម្បីឱ្យអង្គភាពថវិកាទទួលខុសត្រូវលើការអនុវត្តថវិកា និងការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ពិសេសដើម្បីបង្កើនគណនេយ្យភាពចំណាយឱ្យកាន់តែប្រសើររដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុត្រូវវិភាជន៍ថវិកាជូនអង្គភាពថវិកាក្រោមឱវាទឱ្យបានទាន់ពេលវេលាស្របតាមការិយបរិច្ឆេទនៃឆ្នាំសារពើពន្ធនៃការអនុវត្តថវិកា"។

ប្រកាសអន្តរក្រសួងលេខ១២០០ ប្រក/ផក.ផ្កហ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ រវាងក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា ត្រង់ប្រការ១បានចែងថា "ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន៣០ (០៥រដ្ឋបាលកណ្តាល និង២៥ រាជធានី-ខេត្ត)ដូចខាងក្រោមៈ

១. អគ្គនាយកដ្ឋានផែនការ

២. វិទ្យាស្ថានជាតិស្ថិតិ

៣. អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ

៤. អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៥. នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

៦. មន្ទីរផែនការរាជធានី-ខេត្តទាំង២៥

តាមការពិនិត្យរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំឆ្នាំ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២១ ក្រសួងផែនការនៅពុំទាន់បានអនុវត្តថវិកាកម្មវិធីបានពេញលេញនៅឡើយទេ ដោយហេតុថារាល់ការអនុវត្តចំណាយរបស់អង្គភាពថវិកាត្រូវឆ្លងកាត់ការត្រួតពិនិត្យពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យហេតុនេះ ក្រសួងផែនការគួរអនុវត្តថវិកាកម្មវិធីឱ្យបានពេញលេញ និងស្របតាមប្រកាសខាងលើ។

ចំពោះចំណុចនេះ ក្រសួងសូមឆ្លើយបំភ្លឺថា អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុបានពិនិត្យសម្រាប់ចំណាយរបស់អង្គភាពថវិកានីមួយៗនៅមិនទាន់បានរៀបចំគ្រប់ជ្រុងជ្រោយ និងទៅតាមនីតិវិធីចំណាយថវិកា និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ ហេតុនេះទើបក្រសួងផែនការសម្រេចឱ្យអង្គភាពថវិកា (អគ្គនាយកដ្ឋានផែនការ វិទ្យាស្ថានជាតិស្ថិតិ អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ) អនុវត្តថវិកាកម្មវិធីពុំទាន់ពេញលេញ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.២៣.កង្វះខាតក្នុងការគ្រប់គ្រងលើការប្រើប្រាស់គ្រឿងចក្រ**

ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១២០/៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រង់មាត្រា៧៣ បានចែងថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិ ដែលកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ មានកាតព្វកិច្ចថែរក្សា និងការពារទ្រព្យសម្បត្តិរដ្ឋ ដោយត្រូវចាត់វិធានការគ្រប់រូបភាព ដើម្បីទប់ស្កាត់ ឬបង្ក្រាបសកម្មភាពកេងប្រវ័ញ្ច ក្លែងបន្លំ រំលោភកាន់កាប់ទ្រព្យសម្បត្តិដោយខុសច្បាប់ ឬអំពើដែលបង្កអន្តរាយដល់ទ្រព្យសម្បត្តិរដ្ឋ។

តាមការពិនិត្យលើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង និងថយចុះឆ្នាំ២០២១ របស់នាយកដ្ឋានគ្រឿងចក្រ និងស្ពានថ្នល់ និងការសាកសួរមន្ត្រីទទួលបន្ទុក អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា នាយកដ្ឋានមានគ្រឿងចក្រសរុបចំនួន៦៦ ប៉ុន្តែនៅពុំទាន់មានទីកន្លែងសមស្របសម្រាប់រក្សាទុកគ្រឿងចក្រទាំងនោះនៅឡើយ ដោយបច្ចុប្បន្នគ្រឿងចក្រមួយចំនួនដែលអាចប្រើប្រាស់បាន ត្រូវបានរក្សាទុកនៅតាមការដ្ឋាន។

កត្តានេះនាំឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋពុំទាន់មានប្រសិទ្ធភាព និងអាចឈានទៅរកការបាត់បង់ជាយថាហេតុ។ ក្រសួងសាធារណការ និងដឹកជញ្ជូនគួរពិចារណារៀបចំទីតាំងដែលមានទីធ្លាសមស្របសម្រាប់រក្សាទុកគ្រឿងចក្រទាំងនោះ។

ក្រសួងសាធារណការ និងដឹកជញ្ជូនបានបំភ្លឺថា គ្រឿងចក្រមួយចំនួនត្រូវបានចល័តទៅតាមបណ្តាការដ្ឋាន ដើម្បីប្រើប្រាស់ និងរក្សាទុកនៅទីនោះដោយមានមន្ត្រីថែរក្សាការពារ។ ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងខិតខំពិនិត្យលទ្ធភាពក្នុងការរៀបចំទីតាំងដែលមានទីធ្លាសមស្របសម្រាប់រក្សាទុកគ្រឿងចក្រឱ្យឆ្លើយតបតាមស្ថានភាពជាក់ស្តែង។

អាជ្ញាធរសវនកម្មជាតិបានឃើញការបំភ្លឺអំពីគម្រោងកែលម្អរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ ដូចនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានលើការអនុវត្តតាមអនុសាសន៍នេះជាបន្តទៀត។

**៣.១.២៤.ការអនុវត្តចំណាយថវិការជ្ជទេយ្យបុរេប្រទានពុំទាន់ត្រឹមត្រូវតាមនីតិវិធី**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចំណាយរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

ត្រង់ប្រការ១៨ រដ្ឋទេយ្យបុរេប្រទាន ឬរដ្ឋទេយ្យបុរេប្រទានរងត្រូវជៀសវាងដាច់ខាតនូវការបំបែកគោលការណ៍ចំណាយ ឬប័ណ្ណចំណាយទៅតាមទីកន្លែង គោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេសការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងប្រកាសលេខ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម ត្រង់ប្រការ១បានចែងថា ត្រូវកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញសំណង់ និងសេវានៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចក្នុងតារាងឧបសម្ព័ន្ធទី១នៃប្រកាសនេះ សម្រាប់ទឹកប្រាក់ក្រោម ២០លានរៀល ត្រូវអនុវត្តវិធីសាស្ត្រស្ទង់តម្លៃទឹកប្រាក់ចាប់ពី២០លានរៀល ដល់ក្រោម១០០លានរៀល អនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃ ចាប់ពី១០០លានរៀល ដល់ក្រោម៥០០០លានរៀល ត្រូវប្រើវិធីសាស្ត្រដេញថ្លៃក្នុងស្រុក និងចាប់ពី៥០០០លានរៀលឡើង ត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃលក្ខណៈអន្តរជាតិ។

តាមការធ្វើសវនកម្មនៅនាយកដ្ឋានកិច្ចការរដ្ឋបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការិយបរិច្ឆេទ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានកិច្ចការរដ្ឋបាលបានធ្វើការបំបែកប័ណ្ណចំណាយក្នុងថ្ងៃតែមួយលើការទិញសម្ភារសម្អាត និងអនាម័យដែលមានទឹកប្រាក់សរុបចំនួន ១២ ៦១៧ ០០០រៀល ដើម្បីគេចវេសពីនីតិវិធីលទ្ធកម្ម។

ដោយហេតុនេះ ដើម្បីឱ្យការអនុវត្តថវិការដ្ឋទេយ្យបុរេប្រទានបានត្រឹមត្រូវ និងស្របតាមបទប្បញ្ញត្តិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគួរណែនាំដល់នាយកដ្ឋានកិច្ចការរដ្ឋបាលឱ្យធ្វើការកែលម្អឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសខាងលើ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្លើយតបនូវការលើកឡើងខាងលើថា បើផ្អែកតែលើនីតិវិធីទាំងស្រុងដោះស្រាយចំណាយប្រចាំថ្ងៃមិនទាន់ពេលទេ។ ជាក់ស្តែង នាយកដ្ឋានកិច្ចការរដ្ឋបាល ជាអង្គភាពទទួលរ៉ាប់រងរាល់ការចំណាយរបស់ថ្នាក់ដឹកនាំក្រសួង គ្រប់គ្រងទីស្តីការក្រសួងដែលមានអគារច្រើន ការចំណាយត្រូវរហ័ស ទោះជាយ៉ាងណា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការណែនាំដល់នាយកដ្ឋានកិច្ចការរដ្ឋបាល។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.២៥.ការប្រគល់ទទួលសំណង់មុនកាលបរិច្ឆេទគណៈកម្មការអន្តរក្រសួងចូលរួម

សារាចរណែនាំលេខ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី១៩ បានបញ្ជាក់ថា ការប្រគល់ទទួលឬការវាយតម្លៃលទ្ធផលការងារត្រូវប្រព្រឹត្តទៅតាមទីកន្លែង ពេលវេលា បរិមាណ ទំហំ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានកំណត់ក្នុងកិច្ចសន្យា។ លទ្ធផលនៃការប្រគល់ទទួលឬការវាយតម្លៃលទ្ធផលការងារ ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវនៅក្នុងកំណត់ហេតុប្រគល់ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងារ ហើយត្រូវមានការ

ចុះហត្ថលេខាទទួលខុសត្រូវពីគ្រប់សមាជិកគណៈកម្មការប្រគល់ទទួល និងអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ។ ការប្រគល់ទទួលឬការវាយតម្លៃលទ្ធផលការងារ "ខ្យល់" (គ្មានទំនិញ សំណង់ ឬសេវា) ឬមានបរិមាណ ទំហំការងារ ឬសេវាមិនគ្រប់ចំនួន និង/ឬមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ឬអំពើយុបឃិតដែលត្រូវចៀសវាងឱ្យបានដាច់ខាត។

តាមការចុះធ្វើសវនកម្មនៅអគ្គនាយកដ្ឋានរដ្ឋបាល ការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានសម្រាប់ការិយបរិច្ឆេទ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋានរដ្ឋបាល ការពារ និងអភិរក្សធម្មជាតិបានធ្វើការវាយតម្លៃ និងការប្រគល់ទទួលសំណង់សាងសង់បង្គោលព្រំប្រទល់តំបន់ការពារទេសភាពអាងត្រពាំងថ្មជាមួយក្រុមហ៊ុនមុនកាលបរិច្ឆេទដែលគណៈកម្មការអន្តរក្រសួងចូលរួមប្រគល់ទទួលដែលមានទឹកប្រាក់ចំនួន១៦៥ ៤១៩ ៩០០រៀល។

ដោយហេតុនេះ ដើម្បីឱ្យការអនុវត្តកិច្ចលទ្ធកម្មបានត្រឹមត្រូវ និងស្របតាមបទប្បញ្ញត្តិ ក្រសួងបរិស្ថានគួរណែនាំអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឱ្យធ្វើការកែលម្អឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបនៅការលើកឡើងខាងលើនេះ ក្រុមការងារសូមធ្វើការបកស្រាយជូនដូចតទៅ៖ យោងសំណើសុំចាត់អញ្ជើញគណៈកម្មការអន្តរក្រសួងចូលរួមប្រគល់ទទួលការងារសាងសង់បង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិ បានបង្ហាញថា ការប្រគល់ទទួលការងារសាងសង់បង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិ មានចំនួន៥តំបន់ ដោយចាប់ផ្តើមពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២១។ ការប្រគល់ទទួលការងារសាងសង់បង្គោលព្រំប្រទល់ដូចមានជម្រាបជូនខាងលើ ត្រូវបានរៀបចំកំណត់ប្រគល់ទទួលដោយមានការបញ្ជាក់ពីកាលបរិច្ឆេទប្រគល់ទទួលច្បាស់លាស់រៀងៗខ្លួន។ ចំពោះករណីការប្រគល់ទទួលការងារសាងសង់បង្គោលព្រំប្រទល់តំបន់ការពារទេសភាពអាងត្រពាំងថ្ម គឺត្រូវប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ តាមពេលវេលាដែលបានកំណត់ ក៏ប៉ុន្តែដោយមានការធ្វេសប្រហែសលើការសរសេរ និងពិនិត្យលើកំណត់ហេតុប្រគល់ទទួលនៅទំព័រទី១ផ្នែកខាងលើ ត្រង់ចំណុចបញ្ជាក់ពីកាលបរិច្ឆេទប្រគល់ទទួល ទៅជាសរសេរកាលបរិច្ឆេទថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ទៅវិញ ក៏ប៉ុន្តែថ្ងៃខែឆ្នាំចុះ កន្លែងក្រុមការងារប្រគល់ទទួលអន្តរក្រសួងគឺចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១។ ដូចនេះ ភាពធ្វេសប្រហែសនេះកើតឡើងដោយសារការចម្លងកំណត់ហេតុប្រគល់ទទួលការងារសាងសង់បង្គោលព្រំប្រទល់តំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ភូមិសាស្ត្រខេត្តសៀមរាប ដែលបានប្រគល់ទទួលកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ មកធ្វើការកែសម្រួលជាកំណត់ហេតុប្រគល់ទទួលការងារសាងសង់បង្គោលព្រំប្រទល់តំបន់ទេសភាពអាងត្រពាំងថ្ម ភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ហើយធ្វើការកែសម្រួលមិនអស់ និងពិនិត្យមិនបានគ្រប់ជ្រុងជ្រោយ ដែលបណ្តាលឱ្យកើតមានកំហុសនេះឡើង។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.២៦.ការពុំទាន់បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ត្រង់ជំពូកទី១ បទប្បញ្ញត្តិទូទៅ មាត្រា១ បានចែងថា "អនុក្រឹត្យនេះមានគោលបំណងកំណត់យន្តការដឹកនាំ និងគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីធានាឱ្យការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សា ប្រព្រឹត្តទៅដោយរលូនប្រកបដោយតម្លាភាព គណនេយ្យភាព យុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេលវេលា ព្រមទាំងធានាបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅព្រះរាជាណាចក្រកម្ពុជា"។

សម្រាប់ការិយបរិច្ឆេទ ២០២១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" បានទទួលការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើផែនការប្រចាំឆ្នាំ និងបានចំណាយទិញកុំព្យូទ័រ ម៉ាស៊ីនថតចម្លង ឧបករណ៍តភ្ជាប់ប្រព័ន្ធកុំព្យូទ័រ (Server) គ្រឿងសង្ហារឹម សម្ភារការិយាល័យ សរុបទឹកប្រាក់ចំនួន ៦៨ ៨៤០ ៨៥០រៀល ដោយគ្រាន់តែធ្វើការប្រៀបធៀបវិក្កយបត្រចំនួន៣ ដែលទទួលបានពីអ្នកផ្គត់ផ្គង់ប៉ុណ្ណោះ ប៉ុន្តែក្រុមហ៊ុននេះពុំទាន់បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឱ្យស្របទៅតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

អាស្រ័យហេតុនេះ ដើម្បីងាយស្រួលគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" គួរអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវ។

ឆ្លើយតបនឹងការលើកឡើង ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" សូមទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ហើយនឹងធ្វើការពិនិត្យលើការងារនេះឡើងវិញ ដើម្បីពង្រឹងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈឱ្យបានពេញលេញ។

ផ្អែកតាមការបំភ្លឺនេះ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" បានទទួលយកអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

## ៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១.កង្វះខាតក្នុងការគ្រប់គ្រងចំណូល និងបំណុលភាស៊ី ផ្សារ ចំណត កំពង់ផ កំពង់ផែ

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ផ្នែកទី២ មាត្រា១០ បានចែងថា រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ ហើយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត បំពេញមុខងារជាសេនាធិការជូនរដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ និងបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រង

ចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ ចែងថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដាក់ចេញវិធានការជាមួយក្រសួង ស្ថាប័នសាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារបំណុលដែលផ្នែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋ ដូចជា បញ្ឈប់ការអនុញ្ញាតនាំចេញ នាំចូល បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាប័ណ្ណ និងមិនអនុញ្ញាតឱ្យចូលរួមលទ្ធកម្មសាធារណៈជាដើម។ ករណីការអនុវត្តតឹងទារបំណុលនេះមិនមានប្រសិទ្ធភាព ក្រសួង ស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការ។

តាមការធ្វើសវនកម្មនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃខេត្តឧត្តរមានជ័យ ក្រចេះ តាកែវ និងខេត្តបន្ទាយមានជ័យ ឃើញថា មន្ទីរទាំងនេះមានបំណុលមិនមែនសារពើពន្ធ ដោយពុំមានវិធានការទារ និងតឹងទារតាមបែបបទ និងនីតិវិធីគ្រប់គ្រាន់ឡើយ ជាក់ស្តែង៖

- ខេត្តឧត្តរមានជ័យ ពុំទាន់បានប្រមូលចំណូលភាស៊ីផ្សារចំនួន៣ គឺផ្សារស្រុកត្រពាំងប្រាសាទ ស្រុកបន្ទាយអំពិល និងផ្សារស្រុកចុងកាល ។
- ខេត្តក្រចេះពុំទាន់បានទារបំណុលភាស៊ីផ្សារចំនួន ៨ ២៣៥ ៥០០រៀល ភាស៊ីចំណតចំនួន ៥០ ៣៦១ ០០០ រៀល ភាស៊ីកំពង់ចម្លងចំនួន ៣៦ ០៣៨ ៥០០ រៀល និងកំពង់ផែចំនួន ២៥ ២០៩ ៩០០រៀល។
- ខេត្តតាកែវពុំទាន់បានប្រមូលចំណូលភាស៊ីផ្សារទន្លាប់ ផ្សារអង្គតាសោម ផ្សារអង្គរកា ផ្សារថ្នល់បត់ ផ្សារបុាំងកេសី និងភាស៊ីកំពង់ទូក (កំពង់ស្វែង)។
- ខេត្តបន្ទាយមានជ័យពុំបានទារបំណុលភាស៊ីចំណតទេសចរណ៍ចំនួន ៧៥៩ ២៦០ ០០០រៀល។

ដោយសារការពុំមានវិធានការប្រមូលចំណូល និងតឹងទារបំណុលមិនមែនសារពើពន្ធខាងលើ នាំឱ្យការគ្រប់គ្រងមិនបានល្អចំណូលខ្លះត្រូវបាត់បង់ និងចំណូលខ្លះទៀតក្លាយទៅជាបំណុលរ៉ាំរ៉ៃទារមិនបាន។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរជំរុញឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុវត្តឱ្យបានម៉ឺងម៉ាត់ឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យ និងបទបញ្ជាខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះបានលើកឡើងថា ផ្សារស្រុកខ្លះដែលដីជាសហកម្មសិទ្ធិឯកជន ពុំទាន់បានធ្វើច្បាប់វិនិយោគអាជីវកម្មសម្រាប់ប្រមូលភាស៊ីនៅឡើយ ផ្សារស្រុកខ្លះទៀតគ្រប់គ្រងដោយរដ្ឋបាលស្រុក ចំណូលប្រមូលបានគ្រាន់តែចំណាយលើការជួសជុលថែទាំ និងសម្អាតអនាម័យតែប៉ុណ្ណោះ។ រីឯផ្សារស្រុកខ្លះផ្សេងទៀត គឺជាផ្សារសហគមន៍ដែលសាងសង់ដោយគម្រោងGIZ ការលក់ដូរនៅមានកម្រិតតិចតួចនៅឡើយ។ រដ្ឋបាលខេត្តមួយផ្សេងទៀតថា កន្លងមក មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តធ្លាប់បានអញ្ជើញអ្នកវិនិយោគមកប្រជុំពិភាក្សារឿងការបង់ចំណូលនេះ ប៉ុន្តែពួកគាត់បានលើកឡើងតែបញ្ហាការរីករាលដាលជំងឺកូវីដ-១៩ និងគ្មានអាជីវករលក់ដូរទេ រកចំណូលពុំបានបង់ឡើយ។ ជាមួយនេះ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ធ្លាប់បានស្នើសុំទៅដល់អគ្គនាយកដ្ឋានគ្រប់គ្រង

ចំណូលមិនមែនសារពើពន្ធ និងលេខាធិការដ្ឋានអ្នកច្បាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជួយដោះស្រាយផងដែរ។ ករណីខ្លះកំពុងជាប់បណ្តឹងនៅតុលាការ ករណីខ្លះទៀតគាត់ក្ស័យធន និងអ្នកខ្លះទៀតបានដូរលំនៅដ្ឋានរកមិនឃើញ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនៅតែសូមឱ្យរដ្ឋបាលខេត្តអនុវត្តតាមអនុសាសន៍សវនកម្ម។ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

**៣.២.២.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព**

ប្រកាសអន្តរក្រសួងលេខ ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់ឧបសម្ព័ន្ធ ខ.I.១១.៤ បានបញ្ជាក់ថា "លិខិតអនុញ្ញាតបើកការដ្ឋានចំពោះផ្ទៃក្រឡាសំណង់ ចាប់ពី៣ ០០០ម$^{២}$ចុះក្រោម គិតយក១០ភាគរយនៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់"។

តាមការធ្វើសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តចំនួន៦ ឃើញថា សំណង់ស្ថិតក្រោមសមត្ថកិច្ចប្រមូលចំណូលតាមការិយាល័យច្រកចេញ-ចូលតែមួយនៅរដ្ឋបាលខេត្ត ដែលមន្ទីរជាអ្នកគ្រប់គ្រងលើបច្ចេកទេស។ មន្ទីរទាំងនោះបានផ្តល់លិខិតអនុញ្ញាតសាងសង់ជូនម្ចាស់សំណង់ និងបានប្រមូលចំណូលពីសេវានេះរួចហើយ។ ប៉ុន្តែមន្ទីរទាំងនោះមិនបានប្រមូលចំណូលពីសេវាបើក និងបិទការដ្ឋានឱ្យបានគ្រប់ចំនួនដូចមានបង្ហាញខាងក្រោម៖

១.ខេត្តព្រៃវែង បានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន១៦ ក្នុងនោះមានលិខិតបើកការដ្ឋានចំនួន៩ និងលិខិតបិទការដ្ឋានចំនួន១។

២.ខេត្តស្វាយរៀង បានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន១៦ ក្នុងនោះមានលិខិតបើកការដ្ឋានចំនួន១៦ និងគ្មានលិខិតបិទការដ្ឋានទេ។

៣.ខេត្តកំពង់ធំបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន១៣១ និងគ្មានលិខិតបិទការដ្ឋានទេ។

៤.ខេត្តកំពង់ស្ពឺ បានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន១៩ ក្នុងនោះមានលិខិតបើកការដ្ឋានចំនួន៣ និងពុំមានលិខិតបិទការដ្ឋានទេ។

៥.ខេត្តបន្ទាយមានជ័យ បានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន២១៥ ក្នុងនោះមានលិខិតបើកការដ្ឋានចំនួន២២ និងលិខិតបិទការដ្ឋានចំនួន១។

៦.ខេត្តស្ទឹងត្រែងបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន៧៥ ក្នុងនោះមានលិខិតបើកការដ្ឋានចំនួន៤ និងពុំមានលិខិតបិទការដ្ឋានទេ។

ដោយសារតែការខកខានពុំបានបំពេញកាតព្វកិច្ចបើកការដ្ឋាន និងបិទការដ្ឋានសំណង់ នាំឱ្យសំណង់ខ្លះសង់មិនគោរពតាមប្លង់ និងបទដ្ឋានបច្ចេកទេសនៃសំណង់ ព្រមទាំងធ្វើឱ្យបាត់ចំណូលគុណប្រយោជន៍ថវិកាខេត្តទៀតផង។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំដល់មន្ទីរ និងសមត្ថកិច្ចពាក់ព័ន្ធ ឱ្យយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសានៃប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះឯកភាពតាមការលើកឡើង និងសន្យាថាជួយជំរុញការងារនេះ។ រដ្ឋបាលខេត្តខ្លះទៀតបានលើកឡើងថា មកពីប្រជាពលរដ្ឋខ្វះការយល់ដឹងអំពីច្បាប់ ដោយមន្ទីរបានជំរុញឱ្យម្ចាស់សំណង់មកដាក់ពាក្យស្នើសុំធ្វើការបើកការដ្ឋាន និងបិទការដ្ឋាន នៅពេលមុនសាងសង់ និងពេញបញ្ចប់ការងារសាងសង់ តែម្ចាស់សំណង់នោះគាត់មិនមកសុំ។

រដ្ឋបាលខេត្តផ្សេងទៀតថា ម្ចាស់សំណង់ខ្លះបានសុំលិខិតសាងសង់រួចហើយ តែផ្អាកមិនសាងសង់វិញ។ ករណីខ្លះទៀតស្ថិតក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តឡើយ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនៅតែសូមឱ្យរដ្ឋបាលខេត្តខិតខំជំរុញការអនុវត្តកែលម្អលើការគ្រប់គ្រងវិស័យសំណង់ឱ្យបានកាន់តែប្រសើរ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដានរាល់ការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៣.កង្វះខាតក្នុងការចុះអធិការកិច្ចត្រួតពិនិត្យគុណភាព សុវត្ថិភាព និងទប់ស្កាត់សំណង់មិនប្រក្រតីខុសបច្ចេកទេស

ប្រកាសរួមលេខ ១២២៩ ប្រក.មផ.ដនស ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត ត្រង់ប្រការ៣ បានចែងថា "មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត មានភារកិច្ចចុះត្រួតពិនិត្យគ្រប់ការដ្ឋានសំណង់ជាប្រចាំ ទាំងសំណង់ ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយក្រសួង ទាំងសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយសាលារាជធានី ខេត្ត ក្នុងករណីពិនិត្យឃើញសំណង់មិនប្រក្រតី អនុវត្តខុសប្លង់បច្ចេកទេស ត្រូវរាយការណ៍ជាបន្ទាន់ មកសាលារាជធានី ខេត្ត និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីមានមូលដ្ឋានក្នុងការចេញលិខិតផ្អាកការដ្ឋានសំណង់ និងមានវិធានការតាមច្បាប់តាមគ្រប់រូបភាព" និងសេចក្តីណែនាំលេខ០០២ ដន/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ ស្តីពីការពង្រឹងគុណភាព និងសុវត្ថិភាពសំណង់ ត្រង់ចំណុច៤ (ដំណើរការការដ្ឋានសំណង់) បានចែងថា "...អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់មន្ត្រីត្រួតពិនិត្យសំណង់ឱ្យចុះបំពេញការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់មានមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ..."។

តាមការធ្វើសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ចំនួន៣ គឺខេត្តឧត្តរមានជ័យ រតនគិរី ខេត្តក្រចេះ ឃើញថា មន្ទីរខាងលើនេះពុំបានចាត់មន្ត្រីឱ្យត្រួតពិនិត្យកិច្ចការសំណង់ឱ្យចុះបំពេញការងារធ្វើអធិការកិច្ចត្រួតពិនិត្យគុណភាព សុវត្ថិភាពសំណង់ និងទប់ស្កាត់សំណង់សង់ខុសប្លង់ ខុសបច្ចេកទេសជាប្រចាំឡើយ។

ដោយសារកង្វះខាតក្នុងការចាត់ឱ្យមន្ត្រីចុះធ្វើអធិការកិច្ចត្រួតពិនិត្យគុណភាព សុវត្ថិភាព និងទប់ស្កាត់សំណង់មិនប្រក្រតី ខុសបច្ចេកទេសសំណង់ឱ្យបានគ្រប់ករណី នាំឱ្យសំណង់មួយចំនួនអាចសាងសង់ពុំស្របតាមប្លង់ ខុសបច្ចេកទេស គ្មានគុណភាព និងសុវត្ថិភាពគ្រប់គ្រាន់។

មូលហេតុនេះ រដ្ឋបាលខេត្តគួរណែនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីឱ្យអនុវត្តត្រឹមត្រូវតាមខ្លឹមសារនៃប្រកាស និងសេចក្តីណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះទទួលយកចំណុចខ្វះខាតនេះដោយសន្យាថានឹងណែនាំមន្ទីរជំនាញអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ។ រដ្ឋបាលខេត្តខ្លះទៀតថាដោយសារមន្ទីរនៅខ្វះមន្ត្រីបច្ចេកទេសសំណង់។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា កិច្ចការនេះនឹងបានល្អប្រសើរនាពេលខាងមុខ ហើយអាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៤.កង្វះខាតក្នុងការសម្រេចតែងតាំងសមាសភាពគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋខេត្ត

អនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧របស់រាជរដ្ឋាភិបាល ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់មាត្រា៩ បានបញ្ជាក់ថា គណៈកម្មការបញ្ជីសារពើភណ្ឌនៃរដ្ឋបាលរាជធានី ខេត្ត មានសមាសភាពដូចជា៖ អភិបាល ឬអភិបាលរងរាជធានី ខេត្ត ជាប្រធាន ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ជាអនុប្រធានប្រចាំការ ប្រធានអង្គភាពប្រើប្រាស់នីមួយៗ ជាសមាជិក។

តាមការធ្វើសវនកម្មនៅខេត្តចំនួន៤ សម្រាប់ការិយបរិច្ឆេទ២០២១ ឃើញថា ការចេញសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្ត មិនសមស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ៦៦ខាងលើឡើយដូចមានបង្ហាញជូនខាងក្រោម៖

- រដ្ឋបាលខេត្តកំពត៖ សេចក្តីសម្រេចលេខ០៦២/២១ សសរ ចុះថ្ងៃទី១២ ខែសីហាឆ្នាំ២០២១៖

(១)អភិបាលរង នៃគណៈអភិបាលខេត្តកំពត ជាប្រធាន

(២)នាយករដ្ឋបាលខេត្ត ជាអនុប្រធានទី១

(៣)នាយកទីចាត់ការហិរញ្ញវត្ថុខេត្ត ជាអនុប្រធានប្រចាំការ

(៤)ប្រធានការិយាល័យហិរញ្ញកិច្ច ជាសមាជិក

(៥)ប្រធានការិយាល័យទ្រព្យរដ្ឋ នៃទីចាត់ការហិរញ្ញវត្ថុ ជាសមាជិក

(៦)អនុប្រធានការិយាល័យទ្រព្យរដ្ឋ នៃទីចាត់ការហិរញ្ញវត្ថុ ជាលេខាកត់ត្រា

(៧)មន្ត្រីសាលាខេត្ត ជាលេខាកត់ត្រា។

• រដ្ឋបាលខេត្តរតនគិរី៖ សេចក្តីសម្រេចលេខ០០៦/២០ សសរ ចុះថ្ងៃទី១០ ខែកុម្ភៈឆ្នាំ២០២០៖

(១)នាយករដ្ឋបាលសាលាខេត្ត ១រូប ជាប្រធាន និងសមាជិកចំនួន ៨រូប។

• រដ្ឋបាលខេត្តកំពង់ចាម៖ សេចក្តីសម្រេចលេខ០២២/២១ សសរ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១៖

(១)អភិបាល នៃគណៈអភិបាលខេត្ត ជាប្រធាន

(២)អភិបាលរង នៃគណៈអភិបាលខេត្ត ជាអនុប្រធាន

(៣)នាយករដ្ឋបាលខេត្ត ជាអនុប្រធាន

(៤)នាយករងរដ្ឋបាល ជាអនុប្រធាន

(៥)នាយកទីចាត់ការហិរញ្ញវត្ថុ ជាអនុប្រធានប្រចាំការ

(៦)នាយកទីចាត់ការផែនការវិនិយោគ ជាសមាជិក

(៧)នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស ជាសមាជិក

(៨)នាយកទីចាត់ការអន្តរវិស័យ ជាសមាជិក

(៩)ប្រធានអង្គភាពច្រកចេញ ចូលតែមួយ ជាសមាជិក

(១០)នាយកទីចាត់ការរដ្ឋបាល ជាសមាជិក

(១១)ប្រធានអង្គភាពលទ្ធកម្មខេត្ត ជាសមាជិក

(១២)ប្រធានផ្នែកទទួលពាក្យបណ្តឹង និងកិច្ចការរដ្ឋបាល ជាសមាជិក

(១៣)ប្រធានការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិ ជាសមាជិក។

• រដ្ឋបាលខេត្តត្បូងឃ្មុំ៖ សេចក្តីសម្រេចលេខ០៣៧/១៩ សសរ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩៖

១.អភិបាលរង នៃគណៈអភិបាលខេត្ត ជាប្រធាន

២.នាយករដ្ឋបាលស្តីទី សាលាខេត្ត ជាអនុប្រធាន

៣.ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធាន

៤.ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ជាអនុប្រធាន

៥.ប្រធានអង្គភាពប្រដាប់អាវុធក្នុងខេត្ត ជាអនុប្រធាន

៦.ប្រធានមន្ទីរអង្គភាពជុំវិញខេត្ត ជាអនុប្រធាន

៧.អភិបាលនៃគណៈអភិបាលក្រុង ស្រុកទាំង៧ ក្នុងខេត្ត ជាអនុប្រធាន

៨.នាយករងរដ្ឋបាលសាលាខេត្ត ជាសមាជិក

៩.នាយកទីចាត់ការហិរញ្ញវត្ថុ សាលាខេត្ត ជាសមាជិក

១០.នាយករងទីចាត់ការហិរញ្ញវត្ថុ សាលាខេត្ត ជាសមាជិក

១១.អនុប្រធានអង្គភាពប្រដាប់អាវុធក្នុងខេត្ត០១រូប ក្នុងមួយអង្គភាព ជាសមាជិក

១២.អនុប្រធានមន្ទីរអង្គភាពជុំវិញខេត្ត ជាសមាជិក

១៣.អភិបាលរងក្រុង ស្រុកក្នុងខេត្ត០១រូប ក្នុងមួយក្រុង ស្រុក ជាសមាជិក

១៤.ប្រធាការិយាល័យទ្រព្យសម្បត្តិរដ្ឋ សាលាខេត្ត ជាសមាជិក

១៥.ប្រធានការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

១៦.មន្ត្រីការិយាល័យទ្រព្យសម្បត្តិរដ្ឋ សាលាខេត្ត ជាសមាជិក

១៧.មន្ត្រីការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

ដោយសារកង្វះខាតក្នុងការសម្រេចតែងតាំងសមាសភាពគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋខេត្ត មិនបានសមស្រប នាំឱ្យប៉ះពាល់ដល់ការអនុវត្តគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តទាំងអស់គួរបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌរបស់ខ្លួន ឱ្យបានសមស្របតាមមាត្រា៩ នៃអនុក្រឹត្យខាងលើ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តមួយចំនួនបានសន្យាថានឹងរៀបចំសមាសភាពគណៈកម្មការការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្មីឱ្យបានសមស្របតាមគោលការណ៍ខាងលើ និងរដ្ឋបាលខេត្តខ្លះទៀតថា បានដាក់នាយករដ្ឋបាលជាអនុប្រធានគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយសារតែរចនាសម្ព័ន្ធរដ្ឋបាលខេត្តមានទីចាត់ការដែលជាអង្គភាពប្រើប្រាស់ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋបាល។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត ហើយរំពឹងថា រដ្ឋបាលខេត្តខាងលើនឹងមានសមាសភាពគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមួយសមស្របនាពេលខាងមុខ។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២១ នាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

### ៤.១.ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២១

ដើម្បីប្រមូលពន្ធពីការខកខាន ឬការធ្វេសប្រហែលណាមួយពីអ្នកជាប់ពន្ធ ការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខេត្ត និងខណ្ឌមានភារកិច្ចរៀបចំកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើឯកសារ និងសវនកម្មមានកម្រិតលើអ្នកជាប់ពន្ធឱ្យបានទាន់ពេល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

តាមការពិនិត្យលើកម្មវិធីសវនកម្មរបស់សាខាពន្ធដារខណ្ឌ និងខេត្ត អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២១ សាខាពន្ធដារខណ្ឌ និងខេត្តបានលើកកម្មវិធីសវនកម្មសរុបចំនួន ២ ៥៩០សហគ្រាស ក្នុងនោះគិតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ សាខាពន្ធដារខណ្ឌ និងខេត្តបានអនុវត្តការងារសវនកម្មសម្រេចបានលទ្ធផលចំនួន ២ ២២៥ សហគ្រាស ស្មើនឹង៨៦%នៃកម្មវិធី ប៉ុន្តែសហគ្រាសមួយចំនួនទៀតមិនទាន់ត្រូវបានធ្វើសវនកម្មក្នុងឆ្នាំ២០២១ទេ។ មូលហេតុយឺតយ៉ាវនៅក្នុងការអនុវត្តសវនកម្មបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ នាំឱ្យមានផលវិបាកក្នុងការចុះធ្វើសវនកម្មពន្ធ និងជួបប្រាស្រ័យទាក់ទងជាមួយអ្នកជាប់ពន្ធ។ ក្នុងអំឡុងពេលនោះ អគ្គនាយកដ្ឋានពន្ធដារបានចាត់វិធានការឱ្យមន្ត្រីធ្វើការនៅផ្ទះជាប់ជាប្រចាំ ដើម្បីកុំឱ្យរាំងស្ទះដល់ការអនុវត្តការងារ។

### ៤.២.ក្រុមហ៊ុនសហគ្រាសមួយចំនួនតូចមិនបានមកធ្វើបច្ចុប្បន្នភាព

ដើម្បីគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ផ្តល់សេវាជូនអ្នកជាប់ពន្ធ និងប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានតម្រូវឱ្យអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មានដូចជា អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ឬសកម្មភាពអាជីវកម្ម ការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់ភាគហ៊ុន សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬសាខា ការបញ្ឈប់អាជីវកម្ម អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ព័ត៌មានគណនីធនាគារ ព័ត៌មានទំនាក់ទំនង លេខទូរសព្ទ សារអេឡិចត្រូនិក និងអ្នកជាប់ពន្ធដែលចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ មានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធក្នុងកំឡុងពេល១៥ថ្ងៃនៃថ្ងៃធ្វើការ។

តាមការពិនិត្យស្ថិតិសហគ្រាសមិនទាន់ធ្វើបច្ចុប្បន្នភាពគិតត្រឹមខែធ្នូ ឆ្នាំ២០២១ របស់សាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ ដោយមិនរាប់បញ្ចូលអង្គការ និងស្ថាប័នរដ្ឋ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅមានក្រុមហ៊ុនសហគ្រាសចំនួន៣ ៨៤២ មិន

ទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបន្តខិតខំពង្រឹងកិច្ចការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសឱ្យបានពេញលេញបន្ថែមទៀត។

**៤.៣.ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម**

ប្រកាសលេខ០០៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រង់ប្រការ៤ បានចែងថា "ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម និងពាណិជ្ជកម្ម។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបែងចែកជាបីប្រភេទ៖ អ្នកជាប់ពន្ធតូចគឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែលមានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល ដល់ ១ ០០០លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬមានផលរបរប្រចាំឆ្នាំចាប់ពី២៥០ លានរៀល ដល់ ១ ៦០០លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬមានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត អ្នកជាប់ពន្ធមធ្យមគឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ១ ០០០លានរៀល ដល់ ៤ ០០០លានរៀល"។

តាមការពិនិត្យលិខិតប្រកាសពន្ធប្រចាំខែរបស់អ្នកជាប់ពន្ធតូចចំនួន២៣១ នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្ត១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនសហគ្រាសមួយចំនួនតូច ដែលបានប្រកាសផលរបរលើសពី១ ០០០លានរៀល ក្នុងឆ្នាំ២០២១ ប៉ុន្តែសាខាពន្ធដារខេត្ត ខណ្ឌទាំងនោះដែលទទួលបន្ទុកពុំទាន់បានចាត់វិធានការផ្ទេរសហគ្រាសទាំងនោះទៅអ្នកជាប់ពន្ធមធ្យមនៅឡើយទេ។ ម្យ៉ាងទៀត អ្នកជាប់ពន្ធតូចមួយចំនួនមិនបានបង្កលក្ខណៈងាយស្រួលដល់ពន្ធដារ ដើម្បីធ្វើការចុះបញ្ជីពន្ធដារនោះទេ ដោយហេតុថា ចង់គេចវេសពីការធ្វើសវនកម្ម និងកាន់កាប់បញ្ជីគណនេយ្យងាយស្រួល។ ភាពយឺតយ៉ាវក្នុងផ្ទេរសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម ដោយសារមន្ត្រីពន្ធដារមានការលំបាកក្នុងការជួបជាមួយអ្នកជាប់ពន្ធ ដើម្បីធ្វើបច្ចុប្បន្នភាពទៅអ្នកជាប់ពន្ធមធ្យម។ ឆ្នាំ២០២១ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យមបានខិតខំធ្វើបណ្តើរៗហើយ តែនៅមិនទាន់អស់នៅឡើយ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាហេតុនាំឱ្យមានការយឺតយ៉ាវក្នុងការផ្ទេរ។ ជាងនេះទៀតអគ្គនាយកដ្ឋានពន្ធដារមានប្រព័ន្ធប្រកាសពន្ធអាជីវកម្មអនឡាញ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ការទិញទំនិញរបស់សហគ្រាសមួយចំនួនជាមួយនឹងអ្នកផ្គត់ផ្គង់ ប្រសិនអគ្គនាយដ្ឋានពន្ធដារពិនិត្យឃើញថា ការផ្គត់ផ្គង់ជាអ្នកជាប់ពន្ធតូច ហើយមានការផ្គត់ផ្គង់ទំនិញដែលមានតម្លៃរាប់លានដុល្លារអាម៉េរិក នោះអគ្គនាយកដ្ឋានពន្ធដារនឹងមានវិធានការផ្ទេរសហគ្រាសនោះ ប៉ុន្តែការផ្ទេរសហគ្រាសនេះ ត្រូវធ្វើជាបណ្តើរៗ។ អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តការងារផ្ទេរអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធ

មធ្យមដោយមាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យមជាអ្នកទទួលខុសត្រូវ ប៉ុន្តែការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យរាំងស្ទះដល់ការប្រតិបត្តិការងារព្រោះមន្ត្រីត្រូវចុះដល់ទីតាំងសហគ្រាសផ្ទាល់។ កន្លងមក នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម ព្រមទាំងសាខាពន្ធដារខេត្ត-ខណ្ឌ ក៏បានជំរុញការផ្ទេរអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យមជាប់ជាប្រចាំផងដែរ។ លើសពីនេះ ការដាក់ឱ្យប្រើប្រាស់នៃប្រព័ន្ធប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) បានជួយជំរុញអភិបាលកិច្ចល្អ តាមរយៈការផ្ទៀងផ្ទាត់វិក្កយបត្រអាករវវាងអ្នកទិញ និងអ្នកលក់ ដើម្បីចាត់វិធានការឱ្យបានទាន់ពេលវេលាលើសហគ្រាសដែលប្រកាសពន្ធមិនប្រក្រតី។ អគ្គនាយកដ្ឋានពន្ធដារជាអង្គភាពមួយដែលល្អជាងគេក្នុងការជួយទប់ស្កាត់ការលាងលុយក្នុងចំណោមស្ថាប័នរដ្ឋទាំងអស់។

### ៤.៤.ការប្រមូលពន្ធប៉ាតង់

ប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៥ បានតម្រូវឱ្យអ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ រោងជាងសម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។ ប្រការ៦ នៃប្រកាសខាងលើ បានចែងថា ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

តាមការធ្វើតេស្តអ្នកជាប់ពន្ធចំនួន៣ ៧១៧ ដែលបានធ្វើការប្រកាសបង់ពន្ធក្នុងឆ្នាំ ២០២១ នៅតាមបណ្តាសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអ្នកជាប់ពន្ធចំនួន៦៤២ពុំទាន់បានបង់ពន្ធប៉ាតង់ឆ្នាំ២០២១នៅឡើយ។ ចំពោះបញ្ហានេះកើតឡើងរៀងរាល់ឆ្នាំ និងការប្រមូលពន្ធប៉ាតង់ឱ្យបានពេញលេញជាកិច្ចការដែលពិបាកសម្រេចបាន ប៉ុន្តែជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងខិតខំបន្ថែមទៀត។

### ៤.៥.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមួយចំនួន ក៏បានផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានពន្ធដារផងដែរ។ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារពុំទាន់បានប្រមូលព័ត៌មានសហគ្រាសនៅតាមបណ្តាក្រសួងស្ថាប័នមួយចំនួនផ្សេងទៀត ឱ្យបានពេញលេញ

និងទាន់ពេលវេលានៅឡើយដោយសារក្រសួងមួយចំនួនពុំទាន់សហការ។ ចំពោះបញ្ហានេះកើតឡើងដោយសារស្ថាប័នពាក់ព័ន្ធមួយចំនួនពុំសហការផ្ដល់ព័ត៌មាន។ ជាក់ស្ដែងអ្នកលក់អនឡាញមួយចំនួនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារពុំបានទទួលព័ត៌មានទាំងនោះពីក្រសួងពាណិជ្ជកម្មឡើយ។

**៤.៦.ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន**

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់ផ្នែកទី៣ រដ្ឋបាលសារពើពន្ធ មាត្រា៩៨ បានចែងថា "អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់..." និងត្រង់មាត្រា១១៦ ចំណុច៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធនោះ អ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ..."។ អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រង់ជំពូកទី២ ផ្នែកទី១ អំពើល្មើស និងពិន័យអន្តរការណ៍សម្រាប់សហគ្រាស បានកំណត់ថា "...ការមិនកាន់បញ្ជីគណនេយ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០ ០០០ ០០០ (ដប់លាន)រៀល..."។

តាមការពិនិត្យសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន១០៦ ក្រុមហ៊ុនសហគ្រាស អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន៧៣ក្រុមហ៊ុនសហគ្រាស (ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន២៦ និងសាខាពន្ធដារខេត្តខណ្ឌចំនួន៤៧) ពុំទាន់បានកាន់កាប់ កត់ត្រា និងថែរក្សាទុកកិច្ចបញ្ជិកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធនៅឡើយ។ កន្លងមក ក្រសួងបានជំរុញដល់ក្រុមហ៊ុនឱ្យកាន់កាប់កិច្ចបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ ហើយអគ្គនាយកដ្ឋានពន្ធដារក៏បានចាត់វិធានការលើសហគ្រាសទាំងនោះតាមរយៈការធ្វើសវនកម្មពន្ធជាដើម។

**៤.៧.ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ**

ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រង់មាត្រា១០៤ថ្មី ចំណុច១ បានចែងថា "អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់"។ ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់មាត្រា១២៨ អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ចំណុច១ ចែងថា "ករណីដែលបុគ្គលមិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈ

ពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់កំណត់" និងមាត្រា១២៩ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារបានចែងថា "ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេះពន្ធ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា១២៨នៃច្បាប់ខាងលើ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ"។

តាមការពិនិត្យរបាយការណ៍ស្តីពីការគ្រប់គ្រង និងប្រមូលចំណូលពន្ធសម្រាប់ខែធ្នូ ឆ្នាំ២០២១ នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនសហគ្រាសចំនួន៣៨ ៤៨២ (អ្នកជាប់ពន្ធមធ្យមចំនួន២៣ ៩៧៤ និងអ្នកជាប់ពន្ធតូចចំនួន១៤ ៥០៨) ក្នុងចំណោមក្រុមហ៊ុនសហគ្រាសត្រូវដាក់លិខិតប្រកាសសរុបចំនួន៨០ ៥៥៧ ពុំបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែធ្នូក្នុងឆ្នាំ២០២១។ ករណីនេះសាខាពន្ធដារខ្លះបានចុះពិនិត្យដល់ទីតាំងសហគ្រាសបានមួយចំនួនផងដែរ។

**៤.៨.របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ**

សហគ្រាសវិនិយោគទាំងឡាយដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈ វិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំរបស់សហគ្រាសមានចំនួនចាប់ពីបួនពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីបីពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ។ ប្រកាសលេខ៥៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ត្រង់ប្រការ៥ បានចែងថា "ក្នុងលក្ខណៈវិនិច្ឆ័យយ៉ាងតិចពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបី៖ លក្ខណៈវិនិច្ឆ័យទី១ មានទឹកប្រាក់ផលរបរប្រចាំការិយបរិច្ឆេទគណនេយ្យចាប់ពី ៤ ០០០ ០០០ ០០០រៀល ឡើងទៅ, លក្ខណៈវិនិច្ឆ័យទី២ មានទ្រព្យសកម្មសរុបចាប់ពី ៣ ០០០ ០០០ ០០០រៀល ឡើងទៅ គិតត្រឹមថ្ងៃបិទការិយបរិច្ឆេទគណនេយ្យ, លក្ខណៈវិនិច្ឆ័យ៣ មានចំនួនកម្មករនិយោជិតបម្រើការងារចាប់ពី១០០ (មួយរយ)នាក់ ឡើងទៅ ដោយយោងទៅតាមចំនួនកម្មករនិយោជិតមធ្យមភាគដែលមានក្នុងឆ្នាំ"។

តាមការពិនិត្យសំណុំឯកសារសវនកម្មពេញលេញនៅនាយកដ្ឋានសវនកម្មសហគ្រាសចំនួន១០៦ ក្រុមហ៊ុនសហគ្រាស អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសចំនួន៤៦ មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗ

របស់ខ្លួនឱ្យសវនករឯករាជ្យធ្វើសវនកម្ម ក្នុងនោះមានតែក្រុមហ៊ុនចំនួន១៦ បានដាក់របាយការណ៍សវនកម្មពីសវនករឯករាជ្យ ចំណែកឯក្រុមហ៊ុនមួយចំនួនទៀត ពុំឃើញមានរបាយការណ៍សវនកម្មពីសវនករឯករាជ្យនៅឡើយ។

### ៤.៩.ការប្រើប្រាស់វិក្កយបត្រ

តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឱ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែមគឺត្រូវមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេស ដូចជា ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិត ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀតវិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។

តាមការធ្វើតេស្តលើលិខិតប្រកាសពន្ធ និងឯកសារភ្ជាប់ផ្សេងៗរបស់ក្រុមហ៊ុនសហគ្រាសមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២១ ក្រុមហ៊ុនសហគ្រាសមួយចំនួនបានប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់បានត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជា វិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ នាពេលថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យសាធារណៈជនប្រើប្រាស់នូវកម្មវិធីទូរសព្ទដៃ (GDT Lucky Draw) រួចរាល់ ដែលកម្មវិធីនេះមានសារប្រយោជន៍ច្រើនក្នុងការផ្ទៀងផ្ទាត់ព័ត៌មានវិក្កយបត្រ ការចាត់វិធានការចំពោះសហគ្រាស ពុំទាន់ចុះបញ្ជីពន្ធដារ និងការពង្រឹងវិធាននៃការប្រើប្រាស់វិក្កយបត្រឱ្យបានត្រឹមត្រូវដល់សហគ្រាស។

### ៤.១០.ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ

ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើតេស្តលើការត្រួតពិនិត្យលិខិតប្រកាសពន្ធប្រចាំខែ និងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ក្រុមហ៊ុនចំនួន៦១១ នៅអង្គភាពពន្ធចំនួន២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ដោយសារក្នុងឆ្នាំ២០២១ អគ្គនាយកដ្ឋានពន្ធដារមិនទាន់អនុញ្ញាតឱ្យមន្ត្រីទទួលបន្ទុកលិខិតប្រកាសប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មប្រចាំខែតាមអនឡាញ។ ដូច្នេះ មន្ត្រីចាត់ចែងលិខិតប្រកាសពុំអាចត្រួតពិនិត្យលើភាពត្រឹមត្រូវនៃលិខិតប្រកាសសារពើពន្ធ ដើម្បីធានាថា លិខិត

ប្រកាសត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស និងភាពមិនប្រក្រតីនៃលិខិតប្រកាសទេ។ ជាលទ្ធផលនៃការខកខាននេះ ឃើញមានលិខិតប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនចំនួន១៩៨ (អ្នកជាប់ពន្ធមធ្យមចំនួន៨៦ និងអ្នកជាប់ពន្ធតូចចំនួន១១២) ក្នុងចំណោមក្រុមហ៊ុនចំនួន៦១១ខាងលើ មានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ មិនប្រកាសពន្ធកាត់ទុកលើសេវាកម្ម១៥% និងប្រកាសពន្ធកាត់ទុកលើសេវាកម្ម១៥% មិនត្រឹមត្រូវ មិនមានប្រកាសបៀវត្សអ្នកគ្រប់គ្រង និងវិស្វករ គណនាអាករបំភ្លឺសាធារណៈមិនត្រឹមត្រូវ(លើស) ពេញមួយឆ្នាំ ដោយសហគ្រាសយកផលរបរលក់១០០% ជាមូលដ្ឋានគិតអាករបំភ្លឺសាធារណៈ ដោយមិនបានគុណនឹង២០% ប្រកាសចំណូលពីការលក់ប្រេងឥន្ធនៈ ប៉ុន្តែមិនប្រកាសចំណាយទិញប្រេងឥន្ធនៈ មិនប្រកាសពន្ធកាត់ទុកលើសេវាជួលជុលជាដើម។ អគ្គនាយកដ្ឋានពន្ធដារពុំទាន់ពិនិត្យលិខិតប្រកាសពន្ធឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយទេ ហើយក៏គ្មានប្រទេសណាអនុវត្តបានពេញលេញ១០០% នោះដែរ។ ទោះជាយ៉ាងណា អគ្គនាយកដ្ឋានពន្ធដារក៏បានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះសហគ្រាសដែលប្រកាសពន្ធមានភាពមិនប្រក្រតីដោយត្រូវទទួលរងពិន័យទោសទណ្ឌអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ។

**៤.១១.ការជម្រះបញ្ជីប្រាក់កក់ដែលបាននាំចូលតាមរបបប្រវេសន៍កាលិក**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីនិមុត្តិធានា ដោយបញ្ជាក់ថារដ្ឋបាលគយអាចតម្រូវឱ្យតម្កល់នូវនិមុត្តិធានា ដើម្បីធានានូវការបង់ពន្ធនិងអាករ ឬដើម្បីធានាថាប្រតិវេទន៍ករ និងភាគីទទួលខុសត្រូវផ្សេងៗទៀតបំពេញនូវកាតព្វកិច្ចតាមនីតិវិធីគយ ឬការអនុវត្តច្បាប់ផ្សេងៗទៀត និងរដ្ឋបាលគយត្រូវដោះបន្ទុកនិមុត្តិធានាឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្រោយពេលដែលមន្ត្រីគយមានសមត្ថកិច្ចពិនិត្យឃើញថា កាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់ រាប់បញ្ចូលទាំងការបង់ពន្ធ និងអាករ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ប្រាក់កក់មួយចំនួនមិនទាន់បានទូទាត់ដោយជំពាក់បែបបទនាំចូល និងប្រាក់កក់នាំចូលតាមរបបប្រវេសន៍កាលិករយៈពេលយូរឆ្នាំចាប់តាំងពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន នៅពុំទាន់បានសងបែបបទ និងពុំមានវិធានការសមស្របក្នុងការដោះស្រាយនៅឡើយទេ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា តួលេខសមតុល្យប្រាក់កក់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ នៅសល់ចំនួន ៧៦ ៥៦២ ៣១២ ១៣៩រៀល និង ៩ ៨៦៥ ០០៨ ដុល្លារ អាម៉េរិកក្នុងនោះរួមមាន៖

- ករណីប្រាក់កក់នាំចូលតាមរបបប្រវេសន៍កាលិក មានតែមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានរក្សាទុកយូរដោយសារម្ចាស់មិនចូលខ្លួនមកដោះស្រាយ។ ករណីនេះ អគរ បាននិងកំពុងចាត់វិធានការជាបន្តបន្ទាប់។ ជាលទ្ធផលក្នុងឆ្នាំ២០២១នេះ មានក្រុមហ៊ុនចំនួន៥ បានដោះស្រាយរួច និងបានបង្វែរប្រាក់កក់ចូលថវិការដ្ឋបានចំនួន ១៦៥ ២៣៩ ០៩២រៀល និង ៤២៦ ៩១១ដុល្លារអាម៉េរិក។

- ដោយឡែកការតម្កល់និមុត្តិធានាមួយចំនួនត្រូវបានរក្សាទុកយូរទៅតាមលក្ខខណ្ឌនៃនិមុត្តិធានា ដែលមិនតម្រូវឱ្យដកវិញក្នុងរយៈពេលខ្លីទេ ដូចជាការតម្កល់និមុត្តិធានាដើម្បីប្រកបធុរកិច្ចជើងសាគយ ប្រតិបត្តិករ ភណ្ឌាគារគយមានដែនកំណត់ ប្រតិបត្តិករទីកន្លែងសន្និធិគយបណ្ដោះអាសន្ន និងអាជីវកម្មអគារលក់ទំនិញរួចពន្ធជាដើម។
- ចំណែកឯនិមុត្តិធានាមួយចំនួនទៀត គឺជាប្រាក់កក់រថយន្តចង្កូតស្ដាំ បានមកពីយុទ្ធនាការប្រមូលពន្ធនិងអាករលើរថយន្តគ្មានពន្ធដែលមានស្រាប់ក្នុងប្រទេស ដោយអនុលោមតាមលិខិតជូនដំណឹងលេខ ១៩៨៣/២១ អគរ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

**៤.១២.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ**

នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងារដូចជា៖ ពិនិត្យកំណត់ហេតុល្មើសគយ លើកសំណើសម្រុះសម្រួល និងសម្រេចវិនិច្ឆ័យលើបទល្មើសគយ និងវិវាទផ្សេងទៀតជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពិនិត្យ និងសម្រេច។ ប្រកាសលេខ ៦១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ស្ដីពីការសម្រុះសម្រួលបទល្មើសគយ ត្រង់ប្រការ៤ បានបញ្ជាក់ថា ប្រសិនបើក្នុងរយៈពេលកៅសិប(៩០)ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្ដីសម្រេចជាផ្លូវការស្ដីពីការសម្រុះសម្រួលនូវបទល្មើសគយមិនអាចទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ មានកំណត់ហេតុល្មើសច្បាប់គយចំនួន៥០២ ក្នុងនោះកំណត់ហេតុចំនួន៥១៥ ត្រូវបានធ្វើសេចក្ដីសម្រេចវិនិច្ឆ័យរួច (បូករួមកំណត់ហេតុសល់ឆ្នាំចាស់) ចំណែកឯកំណត់ហេតុចំនួន១៧២ផ្សេងទៀតពុំទាន់ត្រូវបានធ្វើការដោះស្រាយ និងមានវិធានការឱ្យសមស្របនៅឡើយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា រៀងរាល់ដំណាច់ឆ្នាំនីមួយៗ កំណត់ហេតុល្មើសច្បាប់គយរមែងមាននៅសល់ជាកត្តាសត្យានុម័ត ដែលនាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាពុំអាចដោះស្រាយសម្រុះសម្រួលនូវបទល្មើសគយបានអស់ ដើម្បីឱ្យអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិគយ។

ក្រៅពីយន្តការនិងវិធានការដោះស្រាយដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិគយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានចាត់វិធានការចំពោះមុខដូចជា៖ ផ្ដល់សិទ្ធិសម្រុះសម្រួលបទល្មើសគយបន្ថែមទៀតជូននាយកដ្ឋាន និងសាខាគយនិងរដ្ឋាករសម្រាប់ទំនិញគ្រប់ប្រភេទដែលមានតម្លៃមិនលើសពី ៣ ០០០ ដុល្លារអាម៉េរិក បានបង្កើតគណៈកម្មការចំពោះកិច្ច ដើម្បីដោះស្រាយទំនិញល្មើសនឹងច្បាប់ស្ដីពីគយ ដែលមានយន្តការនិងនីតិវិធី

ដោះស្រាយដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចលេខ ១៤៩១/២០ អគរ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២០ បានណែនាំម្ចាស់រថយន្តដែលបានចាប់ឃាត់កន្លងមកមិនទាន់ដោះស្រាយ ជាពិសេសរថយន្តចង្កូតស្តាំឱ្យចូលខ្លួនមកចុះបញ្ជីកក់ប្រាក់ពន្ធ និងអាករ ក្នុងការកែចង្កូត ឬមិនកែ ដើម្បីរួសរាន់មកបង់ពន្ធអាករនិងពិន័យ តាមបញ្ញត្តិច្បាប់ជាធរមាន (លិខិតលេខ ២០០០/២២ អគរ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២) ជំរុញអង្គភាពក្រោមឱវាទឱ្យបន្តរៀបចំសំណុំរឿងទៅតុលាការ ចំពោះកំណត់ហេតុបទល្មើសគយណាដែលហួសរយៈពេលសម្រុះសម្រួល។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននឹងកំពុងពិនិត្យលទ្ធភាពនៃការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិគយមួយចំនួន ដើម្បីឱ្យទាន់ការវិវឌ្ឍនៃតម្រូវការនៃការអនុវត្តច្បាប់ក្នុងអង្គភាពគយ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

**៤.១៣.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ**

សារាចរណែនាំលេខ០១០ សហវ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២១ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ ដូចនេះ **ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ជាកំហិត។**

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) មានសមតុល្យនៅសល់តួលេខចំណូលមិនមែនសារពើពន្ធ (រដ្ឋបាលកណ្តាល) ចុងឆ្នាំ២០២១ ចំនួន ៤ ៣០០ លានរៀល ដោយមិនទាន់បានបង្វែរចូលថវិកាជាតិបានទាន់ពេល***វេលា***នៅឡើយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា នៅក្នុងឆ្នាំ២០២១ ក្រសួងស្ថាប័នបង់ចំណូលខ្វះសរុបចំនួន ៤ ៣០០ ៣៤៤ ១០៥ រៀល ដែលក្នុងនោះ រួមមាន៖

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖ មិនទាន់បង់ចំណូលចំនួន៤ ០៥១ ៤៧០ ០០០ រៀល។ ប៉ុន្តែនៅក្នុងឆ្នាំ២០២២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបង់ចំណូលនេះចំនួន ៣៥៧ ០១៦ ០០០រៀល (យោងបណ្ណបង់ប្រាក់លេខ FJB2203400 674127) នៅសល់ចំនួន ៣ ៦៩៤ ៤៥៤ ០០០រៀល។ ករណីនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានស្នើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទូទាត់ថវិកាចំនួន ៣ ៦៩៤ ៤៥៤ ០០០ រៀល ដើម្បីបង្វែរប្រាក់ចូលជាចំណូលថវិកាជាតិវិញតាមរយៈលិខិតលេខ ១១៦២/២២ ក.អ.ក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។ ប្រតិបត្តិតាមចំណារដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្រ្តី អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងពិនិត្យ និងទូទាត់

ថវិកាចំនួន ៣ ៦៩៤ ៨៥៤ ០០០ រៀល ទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ដើម្បីបង្វែរប្រាក់ចូលជាចំណូលថវិកាជាតិវិញ។

- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលៈ មិនទាន់បង់ចំណូលចំនួន ២៤៨ ៨៧៤ ១០៥ រៀល។ ប៉ុន្តែ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបង់ចំណូលនេះគ្រប់ចំនួន (យោងបណ្ណបង់ប្រាក់លេខ FJB22011 00660822 និងលេខ FJB2201100660819) និងកត់ត្រាជាចំណូលថវិកាជាតិក្នុងឆ្នាំ២០២២។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

## ៤.១៤.ការកត់ត្រាប្រាក់ពន្ធតែមប្រ៊ីសារពើពន្ធ

ដើម្បីផ្តល់លទ្ធភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលបានផ្តល់ប្រភពចំណូលបន្ថែមជូនសាលារាជធានី ខេត្ត ដោយផ្ទេរគណនី៧០០៨១ "ពន្ធតែមប្រ៊ីសារពើពន្ធ" ពីថវិកាជាតិមកថវិកាថ្នាក់ក្រោមជាតិ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ត្រង់មាត្រា១០ ចំណុច១ ចែងថា ពន្ធតែមប្រ៊ីសារពើពន្ធដែលជាគុណប្រយោជន៍ថវិកាថ្នាក់ជាតិ ត្រូវបានផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត។

តាមការពិនិត្យស្ថិតិលើប្រាក់ពន្ធតែមប្រ៊ីសារពើពន្ធប្រចាំខែ និងសំណុំឯកសារផ្សេងៗរបស់សាខាពន្ធដារខេត្តមួយចំនួន និងតាមការធ្វើតេស្តលើស្លាកយីហោរបស់សាខាក្រុមហ៊ុនដែលប្រកបអាជីវកម្មនៅតាមខេត្តមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនមេ ឬទីស្នាក់ការកណ្តាលបានប្រកាស និងបង់ប្រាក់ពន្ធតែមប្រ៊ីសារពើពន្ធជូនដល់អង្គភាពពន្ធ ដែលក្រុមហ៊ុននោះបានចុះបញ្ជី។ ប៉ុន្តែអង្គភាពពន្ធ ដែលទទួលបានចំណូលពីពន្ធតែមប្រ៊ីសារពើពន្ធនោះ មិនទាន់បានបង្វែរប្រាក់ពន្ធតែមប្រ៊ីសារពើពន្ធខាងលើទៅអង្គភាពពន្ធដែលស្លាកយីហោរបស់សាខាក្រុមហ៊ុនទាំងនោះស្ថិតនៅតាមទីតាំងជាក់ស្តែងនៅឡើយទេ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាត់វិធានការនៅក្នុងឆ្នាំ២០២២ រួចរាល់ហើយផងដែរ។

## ៤.១៥.ការប្រមូលពន្ធអចលនទ្រព្យ

គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យ បានតម្រូវឱ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ តាមការធ្វើតេស្តនៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តចំនួន១៤ ឃើញថា អចលនទ្រព្យមួយចំនួនតូចមិនទាន់បានបង់ពន្ធអចលនទ្រព្យសម្រាប់ឆ្នាំ២០២១។ ក្រសួងបានធ្វើការណែនាំនិងជំរុញឱ្យអាជ្ញាធរមូលដ្ឋាននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការពង្រឹងយន្តការនៃការប្រមូលចំណូលពន្ធលើអចលនទ្រព្យ តាមរយៈសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់ការគាំទ្រឱ្យ

អាជ្ញាធរមូលដ្ឋាននៃរដ្ឋបាលរាជធានី ខេត្ត ពង្រឹងយន្តការប្រមូលពន្ធអចលនទ្រព្យ ដើម្បីបង្កើននូវប្រភពចំណូលផ្ទាល់នៅមូលដ្ឋានរបស់រដ្ឋបាលរាជធានី ខេត្តសាមី ឱ្យស្របតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

### ៤.១៦.ក្រសួងស្ថាប័នមួយចំនួនពុំបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា២៣ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២៤ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១នៃខែមេសា ខែកក្កដា ខែតុលា និងខែមករា។ ការខកខានដោយមិនបានផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មតាមកាលកំណត់នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិចារណាផ្អាកការផ្តល់ធានាចំណាយសម្រាប់គម្រោងលទ្ធកម្មបន្តបន្ទាប់។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនបានផ្ញើ និងមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០២១ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | ស្ថាប័នអនុវត្តលទ្ធកម្ម | របាយការណ៍អនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០២១ | | |
|---|---|---|---|---|
| | | បានផ្ញើ | មិនបានផ្ញើ | សរុប |
| ១ | ក្រសួង ស្ថាប័ន | ៥៤ | ០ | **៥៤** |
| | អង្គភាពថវិកាក្រោមចំណុះ | ៤២២ | ២១៧ | **៦៣៩** |
| ២ | រាជធានី ខេត្ត | ២៥ | ០ | **២៥** |
| ៣ | សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ | ៤១ | ០ | **៤១** |

កត្តានេះ នាំឱ្យការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មពុំទាន់បានគ្រប់ជ្រុងជ្រោយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំស្ថាប័នអនុវត្តកិច្ចលទ្ធកម្មទាំងនោះឱ្យរៀបចំរបាយការណ៍លទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់ និងទាន់ពេលវេលា ឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យ និងសារាចរណែនាំខាងលើ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា ក្រសួង បានធ្វើការណែនាំ និងក្រើនរំលឹក ព្រមទាំងបានរៀបចំផ្ញើលិខិតជូនស្ថាប័នអនុវត្តលទ្ធកម្ម ដែលមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០២១ និងឧបសម្ព័ន្ធរបាយការណ៍របស់អង្គភាពថវិកា

តាមរយៈលិខិតលេខ២៨៣១,២៨៣២,២៨៣៣ និង២៨៣៤សហវ-អលសា ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៤.១៧.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់**

ដើម្បីធានាបាននូវការទទួលខុសត្រូវក្នុងការអនុវត្តចំណាយថវិការដ្ឋ អគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ។ ការអនុវត្តតួនាទីនេះបានគត់មុត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តិការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ចំណាយ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ដូចជា៖ កិច្ចសន្យាលទ្ធកម្ម ដែលមានពន្ធប្រថាប់ត្រា និងបណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ជាដើម។ល។

តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់មួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ខ្លះមិនបានភ្ជាប់នូវឯកសារគាំទ្រត្រឹមត្រូវដូចជា៖ ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនសមស្របតាមកម្មវត្ថុនៃការចំណាយ (សកម្មភាពអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនត្រូវតាមកម្មវត្ថុនៃការផ្គត់ផ្គង់) និងបានប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្មក្រោយការិយបរិច្ឆេទ២០២១។ អាស្រ័យដោយនៅកៀកដំណាច់ឆ្នាំថវិកា២០២១ មានការបញ្ជូនអាណត្តិបើកប្រាក់គំហុកច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយក្នុងនោះអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្មមួយចំនួនមានបញ្ហាខ្វះចន្លោះមិនត្រឹមត្រូវតាមនីតិវិធីនៃការទូទាត់។ ផ្អែកតាមសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តការយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្ម ដើម្បីមានមូលដ្ឋានក្នុងការទូទាត់ចំណាយថវិកា ដោយផ្អែកលើកំណត់ហេតុប្រគល់ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងាររបស់គណៈកម្មការលទ្ធកម្ម ដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងច្បាស់លាស់លើទំនិញ ឬសេវាដែលបានបំពេញរួច។ ប៉ុន្តែ អាស្រ័យដោយសារកត្តាពេលវេលា និងការមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ពីដើមទី បញ្ហាខ្វះចន្លោះមួយចំនួនដែលតម្រូវឱ្យមានកិច្ចសហការចូលរួមពង្រឹងបន្ថែមពីក្រសួង ស្ថាប័នសាមី និងអង្គភាពពាក់ព័ន្ធចាប់ពីដើមទីនៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្ម និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តណែនាំដល់ក្រសួង ស្ថាប័ន ក៏ដូចជាអ្នកផ្គត់ផ្គង់ឱ្យបំពេញបន្ថែមនូវសក្ខីបត្រចំណាយ ដូចជា៖ ការបង់ពន្ធប៉ាតង់បន្ថែមឱ្យស្របតាមប្រភេទអាជីវកម្ម

និងការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្មមួយចំនួនទើបនាំឱ្យមានករណីហួសកាលបរិច្ឆេទឆ្នាំ២០២១ ជាដើម។ ករណីនេះ ក៏បានរួមចំណែកក្នុងការប្រមូលពន្ធបង់ចូលថវិការដ្ឋផងដែរ។ ម្យ៉ាងទៀត ផ្អែកលើការត្រួតពិនិត្យចំណាយ គឺមានប័ណ្ណប៉ាតង់តិចតួចបំផុតដែលមានកម្មវត្ថុចំណាយជាលក្ខណៈផ្គត់ផ្គង់ទូទៅ ដោយបរិយាយមិនបានជាក់លាក់អំពីប្រភេទអាជីវកម្ម មានករណីដូចជា "ក្រុមហ៊ុន នីហរ័ណ-អាហរ័ណ" ជាដើម។ ការណ៍នេះ ធ្វើឱ្យអគ្គនាយកដ្ឋានថវិកាមានការលំបាកក្នុងការចាប់យកជម្រើសបដិសេធ ឬមិនផ្តល់ការឯកភាព។ ចំពោះករណីកាលបរិច្ឆេទប្រថាប់ត្រាពន្ធដារនៅលើកិច្ចសន្យាផ្គត់ផ្គង់ គឺមានករណីខ្លះក្រុមហ៊ុនបានដាក់កិច្ចសន្យាទៅអង្គភាពពន្ធដាររង់ចាំការប្រថាប់ត្រា ស្របពេលរៀបចំបញ្ជូនអាណត្តិបើកប្រាក់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទូទាត់ និងករណីខ្លះទៀតនៅពេលចុងឆ្នាំដែលមានការបោះផ្សាយអាណត្តិតម្កល់មួយចំនួន ដែលកិច្ចសន្យាតម្រូវឱ្យមានការប្រថាប់ត្រាពន្ធដារ នៅពុំទាន់មានភ្ជាប់នៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងការត្រួតពិនិត្យលិខិតយុត្តិការចំណាយ និងទូទាត់ចំណាយថវិកាឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា ជាពិសេសពង្រឹងកិច្ចសហការរវាងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ព្រមទាំងក្រសួង ស្ថាប័នសាមី ដែលជាអង្គភាពពាក់ព័ន្ធពីដើមទីឱ្យចូលរួមក្នុងការពង្រឹងនិងដោះស្រាយបញ្ហាប្រឈមទាំងនេះនៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់ ដើម្បីឱ្យសំណើសុំទូទាត់ភ្ជាប់ឯកសារគ្រាប់គ្រាន់ និងត្រឹមត្រូវ។

### ៤.១៨.ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈនៅមានកម្រិត

ប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ ត្រង់ប្រការ៣ បានចែងថា បុគ្គលដែលអាចបង្កើតស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ បានត្រូវមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយពីក្រសួងរ៉ែ និងថាមពល។ បុគ្គល ដែលអាចដំណើរការស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈត្រូវមានលិខិតអនុញ្ញាតដំណើរការស្ថានីយពីក្រសួងរ៉ែ និងថាមពល។

តាមការធ្វើសវនកម្មនៅមន្ទីររ៉ែ និងថាមពលនៃខេត្តចំនួន៩ ឃើញថា ការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់មន្ទីរនៅពុំទាន់បានល្អនៅឡើយ។ ជាក់ស្តែងមានស្ថានីយ និងកន្លែងស្តុកប្រេងឥន្ធនៈ និងហ្គាសមួយចំនួនកំពុងដំណើរការអាជីវកម្មដោយពុំមានលិខិតអនុញ្ញាតឱ្យដំណើរការ និងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពនៅឡើយ ហើយក៏ពុំទាន់បានចាត់ឱ្យអនុវត្តវិធានការគ្រប់ជ្រុងជ្រោយនៅឡើយផងដែរ ក្នុងនោះមាន៖

១.ខេត្តកំពតមានស្ថានីយឥន្ធនៈ ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័ន និងស្ថានីយរួមប្រេងសរុបមានចំនួន៣៤៨ ក្នុងនោះស្ថានីយចំនួន២៨៦មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ស្ថានីយចំនួន៧៨មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព រីឯស្ថានីយចំនួន៦២ទៀត មិនទាន់មានវិញ្ញាបនបត្រនៅឡើយ។

២.ខេត្តឧត្តរមានជ័យ មានស្ថានីយសរុបចំនួន១២៦ ក្នុងនោះ ស្ថានីយប្រេងឥន្ធនៈចំនួន១មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពមាន និងស្ថានីយប្រេងឥន្ធនៈចំនួន៥៤មានលិខិតអនុញ្ញាតឱ្យដំណើរការពីក្រសួងរ៉ែ និងថាមពល។

៣.ខេត្តសៀមរាប មានស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងរួមប្រេងឥន្ធនៈ មានចំនួន៣៨០ ក្នុងនោះស្ថានីយចំនួន២៥៣មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងលិខិតអនុញ្ញាតដំណើរការ រីឯស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងរួមប្រេងឥន្ធនៈចំនួន១២៧ទៀតពុំទាន់មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងលិខិតអនុញ្ញាតដំណើរការស្ថានីយនៅឡើយ។

៤.ខេត្តស្វាយរៀង មានស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នសរុបចំនួន១៥៨ ក្នុងនោះស្ថានីយចំនួន៤៨មានលិខិតអនុញ្ញាតដំណើរការ និងស្ថានីយចំនួន១៣មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេស។

៥.ខេត្តរតនគីរី មានស្ថានីយប្រេងឥន្ធនៈសរុបចំនួន៩២ ក្នុងនោះស្ថានីយចំនួន៥៨មានលិខិតអនុញ្ញាតឱ្យដំណើរការ រីឯស្ថានីយចំនួន៣៤ផ្សេងទៀត ពុំទាន់មានលិខិតអនុញ្ញាត ដំណើរការស្ថានីយពីក្រសួងរ៉ែ និងថាមពលនៅឡើយ។

៦.ខេត្តក្រចេះមានស្ថានីយប្រេងឥន្ធនៈសរុបចំនួន៩១ ក្នុងនោះមានស្ថានីយចំនួន៤២ទីតាំង មានលិខិតអនុញ្ញាតឱ្យដំណើរការ រីឯស្ថានីយចំនួន៤៩ទីតាំងផ្សេងទៀត ពុំទាន់មានលិខិតអនុញ្ញាតដំណើរការស្ថានីយពីក្រសួងរ៉ែ និងថាមពលនៅឡើយ។

៧.ខេត្តកំពង់ចាមមានស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈសរុបចំនួន៣០៥ ក្នុងនោះមានស្ថានីយចំនួន១៣០មានច្បាប់អនុញ្ញាត (ស្ថានីយចំនួន២៤មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងស្ថានីយចំនួន១០៦មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ)។

៨.ខេត្តតាកែវមានស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ សរុបចំនួន៣១៥ ក្នុងនោះមានតែស្ថានីយចំនួន១១៤មានវិញ្ញាបនបត្រអនុញ្ញាតប៉ុណ្ណោះ។

៩.ខេត្តត្បូងឃ្មុំ មានស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈសរុបចំនួន២៤២ និងកន្លែងស្តុកប្រេង និងឧស្ម័នចំនួន១ ក្នុងស្ថានីយចំនួន៨មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងស្ថានីយចំនួន១៣៨មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ។

ដោយសារការខ្វះវិធានការគ្រប់គ្រាន់ចំពោះស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ ដែលគ្មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ និងគ្មានលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពអាច នាំឱ្យស្ថានីយទាំងនោះពុំមានរបៀបរៀបរយ និងលក្ខណៈបច្ចេកទេសសុវត្ថិភាពគ្រប់គ្រាន់ ព្រមទាំងធ្វើឱ្យបាត់បង់ចំណូលថវិកា។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំ មន្ទីររ៉ែ និងថាមពលឱ្យមានវិធានការម៉ឺង ម៉ាត់និងជំរុញដល់ម្ចាស់ស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈរួសរាន់មកដាក់ពាក្យស្នើសុំចុះ បញ្ជីឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះបានលើកឡើងថា ក្រោយពីមានការ ចុះផ្សព្វផ្សាយអំពីច្បាប់ និងបទដ្ឋានបច្ចេកទេសរបស់អង្គភាពជំនាញរួចមក មានការមកដាក់ ពាក្យសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការនិងលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពកើនឡើង។ រដ្ឋបាលខេត្តខ្លះទៀតបានឯកភាពតាមអនុសាសន៍សវនកម្ម ដោយសន្យាថានឹងជំរុញមន្ទីរ ជំនាញអនុវត្តកិច្ចការនេះឱ្យបានល្អ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងទុកថាកិច្ចការនេះនឹងទទួលបាននូវ លទ្ធផលប្រសើរជាងពេលកន្លងមក។ អាជ្ញាធរសវនកម្មជាតិនឹងនៅតែតាមដានការអនុវត្ត ការងារនេះបន្តទៀត។

**៤.១៩.ការបំបែកគម្រោងចំណាយដើម្បីគម្រូវតាមសិទ្ធិសម្រេច**

ប្រកាសលេខ ០១០ សហវ ប្រក.ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រង់ប្រការ១ បានប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈជូនក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាព ថវិកាក្នុងកម្រិតទឹកប្រាក់ជានាចំណាយ ក្រោមទឹកប្រាក់៣០០លាន រៀលសម្រាប់ថវិកាមន្ទីរ ជំនាញរាជធានី ខេត្ត និងក្រោមទឹកប្រាក់ ៥០០លានរៀល សម្រាប់ថវិការដ្ឋបាលខេត្ត និង ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ជំពូកទី៥ ប្រការ២១ បានចែងថា "មិនអនុ ញ្ញាតឱ្យមានការបំបែកគម្រោងទៅជាគម្រោងតូចៗ ដើម្បីបញ្ចៀសការដេញថ្លៃជាសាធារណៈ បំពានវិធីសាស្ត្រលទ្ធកម្ម ឬគម្រូវតាមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាព ថវិកាឡើយ"។

តាមរយៈការធ្វើសវនកម្មលើឯកសារលទ្ធកម្មសាធារណៈនៅបណ្តាមន្ទីរជំនាញមួយ ចំនួន និងនៅរដ្ឋបាលខេត្តចំនួន៥ ឃើញថា មានការបំបែកគម្រោងចំណាយតូចៗ ដើម្បី គម្រូវតាមសិទ្ធិសម្រេច ក្នុងនោះមាន៖

១. ខេត្តកំពង់ធំ មាន១ករណីនៅមន្ទីរធនធានទឹក និងឧតុនិយម ស្តីពីការងារជួស ជុលសំណង់ មានទឹកប្រាក់សរុប ៥៩២ ៩៩០ ០០០រៀល ដោយបានបំបែកជា២ គម្រោងកិច្ចសន្យា។

២. ខេត្តរតនគីរី មាន១ករណីនៅមន្ទីរធនធានទឹក និងឧតុនិយម ស្តីពីការងារជួសជុលសំណង់ធារាសាស្ត្រសរុបទឹកប្រាក់ ៤៩៧ ៤១០ ០០០រៀល ដោយបានបំបែកជា២គម្រោងកិច្ចសន្យា។

៣. ខេត្តក្រចេះ មាន១ករណីនៅមន្ទីរធនធានទឹក និងឧតុនិយម ស្តីពីការងារជួសជុលសំណង់ធារាសាស្ត្រ សរុបទឹកប្រាក់ ៤៨៣ ៣១១ ៣០០រៀល ដោយបានបំបែកចេញជា៣គម្រោងកិច្ចសន្យា។

៤. ខេត្តកំពង់ចាម មាន១ករណីនៅមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្តីពីការងារជួសជុលសំណង់អគារ មានទឹកប្រាក់សរុប ៤១៨ ០០០ ០០០រៀល ដោយបានបំបែកជា២គម្រោងកិច្ចសន្យា។

៥. ខេត្តត្បូងឃ្មុំ មាន៣ករណីស្តីពីការងារជួសជុលសំណង់អគារ របងនិងចាក់សាបស្ថិតនៅក្នុងបរិវេណតែមួយក្នុងនោះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានទឹកប្រាក់សរុបចំនួន៤៨៩ ០០០ ០០០រៀលបានបំបែកជា២គម្រោងកិច្ចសន្យា។ មន្ទីរសុខាភិបាលសរុបទឹកប្រាក់ចំនួន៤៣៣ ៤៦០ ០០០រៀល បានបំបែកចេញជា២គម្រោងកិច្ចសន្យា។

ដោយសារការបំបែកគម្រោងចំណាយទៅជាតូចៗនាំឱ្យកាន់តែចំណាយពេលវេលា និងសម្ភារក្នុងការធ្វើលទ្ធកម្ម ព្រមទាំងប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍លទ្ធកម្មសាធារណៈ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំមន្ទីរខាងលើអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំស្តីពីលទ្ធកម្មសាធារណៈ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះបានលើកឡើងថា មកពីគម្រោងស្ថិតនៅទីតាំងដាច់ឆ្ងាយពីគ្នា រដ្ឋបាលខេត្តខ្លះទៀតថា សូមទទួលយកអនុសាសន៍សវនកម្ម និងជំរុញណែនាំអង្គភាពលទ្ធកម្ម អនុវត្តឱ្យបានល្អ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងថាការងារនេះនឹងត្រូវបានអនុវត្តបានល្អប្រសើរនាពេលខាងមុខ ហើយអាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៤.២០.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២១

រដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥(ប្រាំ)ឆ្នាំនៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុង

ឆ្នាំនីមួយៗដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំដែលរៀបចំរួច ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន២ (ពីរ) ច្បាប់ យ៉ាងយូរនៅដំណាច់ត្រីមាសទី១នៃឆ្នាំបន្ទាប់ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង ស្ថាប័នថ្នាក់កណ្តាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងមិនបានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០២១ រួមមាន៖

| ល.រ | អង្គភាព | បញ្ជីសារពើភណ្ឌឆ្នាំ២០២១ | | |
|---|---|---|---|---|
| | | បានផ្ញើ | មិនបានផ្ញើ | សរុប |
| ១ | ក្រសួង-ស្ថាប័ន (ថ្នាក់កណ្តាល) | ៣១ | ៣៥៦ | ៣៨៧ |
| ២ | រាជធានី ខេត្ត ក្រុង ស្រុក | ១២៤ | ១០៥ | ២២៩ |
| ៣ | មន្ទីរជំនាញ(ថ្នាក់មូលដ្ឋាន) | ៦០៣ | ១៧៩ | ៧៨២ |
| ៤ | រដ្ឋបាលឃុំ សង្កាត់ | ៧៩១ | ៨៥៧ | ១ ៦៤៨ |

### ៤.២១.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្រសួង ស្ថាប័នថ្នាក់កណ្តាល ដែលមានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន៣៣៨ មានទីតាំងអចលនទ្រព្យចំនួន១ ២១២កន្លែង ក្នុងនោះអចលនទ្រព្យដែលមានបណ្ណកម្មសិទ្ធិត្រឹមត្រូវមានចំនួន៦២០កន្លែង ប៉ុន្តែទីតាំងអចលនទ្រព្យចំនួន៥៩២ កន្លែងទៀត នៅមិនទាន់បានធ្វើបណ្ណកម្មសិទ្ធនៅឡើយទេ។ មន្ទីររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គភាពជុំវិញខេត្ត ដែលមានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន២ ៦៤៧អង្គភាព មានទីតាំងអចលនទ្រព្យចំនួន២៧ ៣៤៨ កន្លែង ក្នុងនោះទីតាំងអចលនទ្រព្យដែលមានបណ្ណកម្មសិទ្ធិត្រឹមត្រូវមានចំនួន១៧ ១៤៤ កន្លែង ចំណែកទីតាំងអចលនទ្រព្យចំនួន១០ ២០៤កន្លែងផ្សេងទៀត នៅមិនទាន់បានធ្វើបណ្ណកម្មសិទ្ធិនៅឡើយទេ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ បានបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងពុះពាររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន បន្តប្តេជ្ញាជំរុញវឌ្ឍនភាពក្នុងការដ្ឋានកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ព្រមជាមួយនឹងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និងវិស័យអាទិភាពផ្សេងទៀត ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ពិសេសដើម្បីគោលដៅនៃការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវ**កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣**របស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិ និងការកសាងជាតិមួយដ៏រស់រវើក មានអនាគតដ៏រុងរឿងភ្លឺស្វាងត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួនតាមគោលការណ៍ប្រជាធិបតេយ្យនិងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យយ៉ាងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាព ឯករាជ្យជាតិ និងអធិបតេយ្យភាព ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល ចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និង

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។